## ក្រសួងមហាផ្ទៃ

## អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

# កម្រងឯកសារ

# ស្ដីពី

# របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន

ដោយ៖ នាយកដ្ឋានអត្រានុកូលដ្ឋាន

# ជំពូកទី១

# ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន

## ១.១. ទិដ្ឋភាពច្បាប់ក្នុងក្របខ័ណ្ឌអត្រានុកូលដ្ឋាន

### ១.១.១. រូបវន្តបុគ្គល បុគ្គលិកលក្ខណៈគតិយុត្ត និងព្រឹត្តិការណ៍គតិយុត្ត

- មនុស្សគ្រប់រូប គឺជារូបវន្តបុគ្គល
- គ្រប់រូបវន្តបុគ្គលសុទ្ធតែមានបុគ្គលិកលក្ខណៈគតិយុត្ត
- បុគ្គលិកលក្ខណៈគតិយុត្ត គឺជាលក្ខណៈសម្បត្តិដែលអាចទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់
- អត្ថិភាពនៃបុគ្គលិកលក្ខណៈគតិយុត្តរបស់មនុស្សម្នាក់ត្រូវបានផ្តល់ដោយច្បាប់ដែលចាប់ផ្តើមមានពីពេលចាប់កំណើតរហូតដល់បញ្ចប់ទៅវិញ នៅពេលមរណភាព
- មនុស្សគ្រប់រូបចាប់តាំងពីកើតរហូតដល់ស្លាប់ទៅវិញ ត្រូវបានច្បាប់កំណត់ឱ្យកត់ត្រានូវព្រឹត្តិការណ៍សំខាន់ ៣ គឺកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ដែលហៅថាព្រឹត្តិការណ៍គតិយុត្ត
- ព្រឹត្តិការណ៍គតិយុត្ត គឺជាអំពើ ឬព្រឹត្តិហេតុដែលនាំឱ្យកើត ឬបង្អង់ ឬរំលត់នូវសិទ្ធិ និងកាតព្វកិច្ចរបស់រូបវន្តបុគ្គល ។

| |
|---|
| ការកត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ និងមរណភាព ត្រូវបានរដ្ឋរៀបចំជាប្រព័ន្ធកត់ត្រាផ្លូវការមានលក្ខណៈឯកភាពទូទាំងប្រទេស ដែលហៅថា ការចុះបញ្ជីអត្រានុកូលដ្ឋាន ។ |

### ១.១.២.និយមន័យនៃកំណើត អាពាហ៍ពិពាហ៍ និងមរណភាព

អត្រានុកូលដ្ឋានរបស់បុគ្គលម្នាក់ សំដៅលើស្ថានភាពបី គឺកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។

#### ក). កំណើត

កំណើតជាព្រឹត្តិការណ៍គតិយុត្តដែលនាំឱ្យកើតមាននូវរូបវន្តបុគ្គល ពោលគឺជាការចាប់ផ្តើមកកើតនូវសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប។ ដើម្បីឱ្យបានក្លាយជារូបវន្តបុគ្គលត្រូវមានល័ក្ខខ័ណ្ឌពីរយ៉ាងគឺ ៖

- កើតមកជាមនុស្ស
- កើតមករស់ ហើយអាចនឹងរស់បាន។

#### ខ). អាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និង នារីម្នាក់ដែលប្តេជ្ញាថារួមសមគ្គ-សង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់។ អាពាហ៍ពិពាហ៍អាចនឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែអាពាហ៍-ពិពាហ៍នោះ ធ្វើឡើងស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិមួយចំនួនជាធរមាននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។ ការរៀបអាពាហ៍ពិពាហ៍ត្រូវអនុវត្តតាមគោលការណ៍ និងល័ក្ខខ័ណ្ឌមួយចំនួនដូចខាងក្រោម ៖

- ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ជាមុននៅសាលាឃុំ សង្កាត់ ខាងលំនៅឋានរបស់ភាគីខាងនារី
- កិច្ចសន្យាអាពាហ៍ពិពាហ៍ត្រូវធ្វើនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់ភាគីខាងនារី

- ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ត្រូវដាក់ពាក្យសុំនៅសាលាឃុំ សង្កាត់ខាងលំនៅឋានរបស់ភាគីពលរដ្ឋខ្មែរ
- ជូនដំណឹងជាសាធារណៈអំពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យភាគីដែលពាក់ព័ន្ធអាចប្ដឹងតវ៉ាបាន
- ភាគីទាំងពីរត្រូវមានភេទខុសគ្នា តាមគោលការណ៍ស្ម័គ្រចិត្តប្ដីមួយប្រពន្ធមួយ
- បុរស និងនារី អាចរៀបអាពាហ៍ពិពាហ៍បានចាប់ពីអាយុ ១៨ឆ្នាំឡើង
- ក្នុងករណីភាគីម្ខាងមានអាយុចាប់ពី១៨ឆ្នាំឡើង ហើយភាគីម្ខាងទៀតមិនទាន់ដល់អាយុ១៨ឆ្នាំ ប៉ុន្តែមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលរបស់ភាគី ដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ
- អាពាហ៍ពិពាហ៍ត្រូវហាមឃាត់រវាងសាខាញាតិ ទោះជាសាខាញាតិនោះ មានខាន់ស្លា ឬឥតខាន់ស្លាក្ដី រហូតដល់ខ្សែលោហិតទីបី រាប់ទាំងខ្សែទីបីនេះផងដែរ
- សហព័ទ្ធអាចរៀបអាពាហ៍ពិពាហ៍ជាថ្មីបាន បើចំណងអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយដោយអំណាចសាលក្រម ឬដោយភាគីម្ខាងទទួលមរណភាព។ ក្រោយពីអាពាហ៍ពិពាហ៍រំលាយដោយមូលហេតុប្ដីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬលែងលះគ្នា នារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធវភាព (ភាពមេម៉ាយ) ចំនួន១២០ថ្ងៃ គិតពីថ្ងៃដែលប្ដីស្លាប់ ឬពីថ្ងៃប្រកាសសាលក្រមស្ថាពរ
- ចំពោះអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរដែលរស់នៅបរទេស បើមានបំណងរៀបអាពាហ៍ពិពាហ៍រវាងគ្នាពលរដ្ឋខ្មែរដែលរស់នៅបរទេស អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជូនដំណឹងជាសាធារណៈ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងចុះបញ្ជីអាពាហ៍ពិពាហ៍នោះ នៅចំពោះមុខឯកអគ្គរាជទូត ភារធារី ឬកុងស៊ុល របស់ព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ។

### គ). មរណភាព

មរណភាពរបស់បុគ្គលម្នាក់ជាព្រឹត្តិការណ៍គតិយុត្ត ដែលនាំឱ្យបុគ្គលិកលក្ខណៈគតិយុត្តរបស់រូបវ័ន្តបុគ្គលនោះត្រូវបញ្ចប់។ ទោះជាបុគ្គលិកលក្ខណៈគតិយុត្ត ត្រូវបានបញ្ចប់នៅពេលមរណភាពក៏ដោយ ក៏ច្បាប់បានកំណត់ទទួលស្គាល់ និងបានផ្ដល់នូវអានុភាពខាងផ្លូវច្បាប់ខ្លះ ដូចជាបណ្ដាំសាសន៍ជាដើម។

នឹងចាត់ទុកថាមរណភាព ក្នុងករណីមានបុគ្គលណាម្នាក់បានបាត់ខ្លួន ឬអវត្តមានក្នុងថេរវេលាមួយដែលច្បាប់បានកំណត់ ហើយគ្មាននរណាដឹងថាជននោះស្លាប់ ឬរស់ ហើយមានញាតិលោហិត ឬអ្នកមានផលប្រយោជន៍ពាក់ព័ន្ធបានប្ដឹងសុំឱ្យតុលាការប្រកាសពីការបាត់ខ្លួន ឬអវត្តមានរបស់ជននោះ ហើយប្រសិនបើតុលាការចេញសាលក្រមថាការបាត់ខ្លួន ឬអវត្តមាន ថាជាមរណភាព។

## ១.១.៣. ធាតុផ្សំអត្តសញ្ញាណកម្មនៃរូបវន្តបុគ្គល

### ក). ឈ្មោះ

មនុស្សគ្រប់រូបកើតមកត្រូវតែមានឈ្មោះ។ ឈ្មោះមានលក្ខណៈមិនប្រែប្រួល មានលក្ខណៈជាប់លាប់ និងគ្មានអាជ្ញាយុកាល។ មនុស្សកើតមកត្រូវបានគេដាក់ឈ្មោះ ដោយកំណត់តាមពីររបៀបគឺ ៖

☞ តាមបុត្តភាព ៖ ទារកកើតមកត្រូវតែដាក់ឈ្មោះឱ្យទារកនោះជាចាំបាច់ ដោយយកនាមត្រកូលតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

- កូនមានខាន់ស្លា ៖ នាមត្រកូលអាចយកត្រកូលដែលក្រុមគ្រួសារបានកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬយកឈ្មោះជីតាខាងឪពុក ឬឈ្មោះឪពុក ។
- កូនឥតខាន់ស្លា ៖ បើឪពុកម្តាយទទួលស្គាល់ទាំងពីរ គឺយកនាមត្រកូលខាងឪពុក។ បើមានតែឪពុក ឬម្តាយទទួលស្គាល់តែម្នាក់ឯង នាមត្រកូលត្រូវយកតាមនាមត្រកូលអ្នកដែលទទួលស្គាល់ថាជាកូន។
- កូនសុំពេញលេញ ៖ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន។

☞ តាមរយៈអាពាហ៍ពិពាហ៍ ៖ នៅពេលរៀបអាពាហ៍ពិពាហ៍ ឬក្រោយពេលរៀបអាពាហ៍ពិពាហ៍ ប្តីប្រពន្ធអាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀង១ខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍-ពិពាហ៍បាន ។

ខ). **លំនៅឋាន**

**អត្ថន័យនៃលំនៅឋាន** ៖ កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន

**ទីសំណាក់**៖ ក្នុងករណីកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន ។

**ករណីដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា**៖ ចំពោះបុគ្គលដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលច្បាប់នៃលំនៅឋានត្រូវបានយកមកអនុវត្ត ។

លំនៅឋានរបស់មនុស្សម្នាក់ គឺជាកន្លែងដែលអ្នកនោះបានកំណត់ការស្នាក់នៅរបស់ខ្លួនជាទម្លាប់របស់គេ ហើយជាទីតាំងដ៏សំខាន់នៃកិច្ចការ និងជីវភាពរស់នៅរបស់គេជាប្រចាំ។ លំនៅឋានត្រូវកំណត់យកតែមួយគត់ ព្រោះជាកន្លែងដែលភ្ជាប់បុគ្គលិកលក្ខណៈគតិយុត្តនៃរូបវន្តបុគ្គលទៅនឹងលំនៅឋាននោះ។

ក្នុងករណីដែលគេមិនអាចកំណត់លំនៅឋានរបស់បុគ្គលណាម្នាក់បានច្បាស់លាស់ទេ នោះគេត្រូវកំណត់យកទីសំណាក់ ឬនិវេសនដ្ឋានណាមួយរបស់អ្នកនោះ ថាជាលំនៅឋានរបស់បុគ្គលនោះ។

ការកំណត់លំនៅឋានច្បាស់លាស់របស់បុគ្គលម្នាក់ គឺបានផ្តល់ភាពងាយស្រួលក្នុងរឿងក្តីរដ្ឋប្បវេណី។

**ឧទាហរណ៍** ៖ ដូចជាតុលាការមានសមត្ថកិច្ច គឺតុលាការនៃទីលំនៅរបស់ចុងចម្លើយ។ ចំពោះអាពាហ៍ពិពាហ៍ត្រូវរៀបចំឡើងនៅខាងលំនៅឋានរបស់ភាគីខាងនារី។

### គ). សញ្ជាតិ

សញ្ជាតិ គឺជាចំណងគតិយុត្ត និងនយោបាយ ដែលផ្សារភ្ជាប់រូបវន្តបុគ្គល ឬនីតិបុគ្គលទៅនឹងរដ្ឋអធិបតេយ្យមួយ ។ សញ្ជាតិខ្មែរ គឺជាចំណងខាងផ្លូវចិត្ត ខាងផ្លូវច្បាប់ និងខាងផ្លូវនយោបាយ ដែលភ្ជាប់រូបវន្តបុគ្គល ឬនីតិបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា ។

☞ ត្រូវបានសញ្ជាតិខ្មែរ ទោះកើតនៅទីណាក៏ដោយ ៖

- កូនមានខាន់ស្លាដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ
- កូនឥតខាន់ស្លាដែលកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរទទួលស្គាល់ ឬ
- កូនដែលឪពុក ឬម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្តាយមានសញ្ជាតិខ្មែរ ។

☞ ត្រូវបានសញ្ជាតិខ្មែរ ដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៖

- កូនដែលកើតពីឪពុក និងម្តាយបរទេសដែលកើត និងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- កូនដែលកើតពីឪពុក ម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

☞ ត្រូវបានសញ្ជាតិខ្មែរដោយការរៀបអាពាហ៍ពិពាហ៍ ។ ស្ត្រី ឬបុរសបរទេសណាដែលយកប្តី ឬប្រពន្ធខ្មែរ ដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះរស់នៅជាមួយគ្នារយៈពេលបីឆ្នាំក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ។ បែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ ។ ការផ្តល់សញ្ជាតិខ្មែរតាមករណីទាមទារសញ្ជាតិ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

☞ ត្រូវបានសញ្ជាតិខ្មែរ ដោយសញ្ជាតិតូបនីយកម្ម (ដែលសម្រេចដោយព្រះរាជក្រឹត្យ) ។

## ១.១.៤. ជនបរទេស និងជនអន្តោប្រវេសន្ត

### ក). ជនបរទេស

ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានរើសអើងទោះបីជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ ។

### ខ). ជនបរទេសកំពុងស្ថិតនៅ ឬស្នាក់នៅកម្ពុជា

អនុលោមតាមមាត្រា ៤ នៃច្បាប់ស្តីពីអន្តោប្រវេស្ត របស់ព្រះរាជាណាចក្រកម្ពុជា ជនបរទេសត្រូវចែកចេញជាបីប្រភេទគឺ:

- ជនបរទេសមិនមែនអន្តោប្រវេសន្ត
- ជនបរទេសអន្តោប្រវេសន្ត
- ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន

### ខ-១). ជនបរទេសមិនមែនអន្តោប្រវេសន្ត

ជនបរទេសមិនមែនអន្តោប្រវេសន្ត គឺ ៖

- ភ្នាក់ងារដែលបម្រើការនៅស្ថានទូតបរទេស ឬស្ថានកុងស៊ុលបរទេស ឬស្ថានតំណាងបេសកកម្មបរទេស អ្នកជំនាញការអន្តរជាតិ និងជនផ្សេងៗទៀត ដែលចូលមកព្រះរាជាណាចក្រកម្ពុជាតាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល ដោយរាប់ទាំងក្រុមគ្រួសារ និងបុគ្គលិករបស់គេក្នុងរយៈពេលដែលគេស្នាក់អាស្រ័យនៅ។
- ទាហាន មន្ត្រី អ្នករដ្ឋការ និយោជិក និងភ្នាក់ងារបរទេស និស្សិត ព្រមទាំងគ្រួសារដែលចូលមកព្រះរាជាណាចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។
- អ្នកធ្វើដំណើរឆ្លងកាត់ ជាអ្នករង់ចាំមធ្យោបាយធ្វើដំណើរមុនពេលចេញដំណើរឆ្ពោះទៅកាន់ទីដៅចុងក្រោយរបស់ខ្លួន។ ក្នុងករណីនេះ ការស្នាក់អាស្រ័យនៅមិនត្រូវលើសពីមួយសប្តាហ៍ លើកលែងតែក្នុងករណីប្រធានសក្តិ។
- អ្នកទេសចរណ៍ដែលមានសំបុត្រត្រឡប់ទៅវិញ ហើយរយៈពេលស្នាក់អាស្រ័យត្រូវកំណត់ដោយអនុក្រឹត្យ
- អ្នកតំណាងពាណិជ្ជកម្ម ធនាគារ អ្នកប្រកបមុខរបរផ្សេងៗទៀតដែលចូលមកព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងបង្កើតទំនាក់ទំនងអំពីកិច្ចការខាងលើ។ ក្នុងករណីនេះ ការស្នាក់អាស្រ័យមិនអាចលើសពី៣ខែ។ ក្នុងករណីមានហេតុផលចាំបាច់ ការស្នាក់អាស្រ័យនៅនេះ អាចបន្តទៀតបានរយៈពេល៣ខែជាអតិបរមា តាមការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។
- ជនបរទេសរស់នៅតាមព្រំប្រទល់ជាប់នឹងខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការអនុញ្ញាតឱ្យឆ្លងកាត់ព្រំប្រទល់ច្រើនដង ឬមួយដងមួយកាល។ ល័ក្ខខ័ណ្ឌផ្សេងៗក្នុងការអនុវត្តចំណុចទី៦នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។
- អ្នកធ្វើដំណើរ កងនាវិក និងយានិក ដែលមកសំចតយកស្បៀងនៅតាមកំពង់ផែសមុទ្រ និងតាមព្រលានយន្តហោះ។
- ជនបរទេសដែលមកធ្វើការនេសាទនៅតាមឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

### ខ-២). ជនបរទេសអន្តោប្រវេសន្ត

ជនបរទេសដែលចាត់ទុកជាអន្តោប្រវេសន្ត គឺជនបរទេសដែលមកដល់ព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ដើម្បីស្នាក់នៅរយៈពេលយូរ ឬ ដើម្បីប្រកបវិជ្ជាជីវៈ ឬ ធ្វើសកម្មភាពផ្សេងៗដែលទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម សេវា ឬកសិកម្ម។

### ខ-៣). ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន គឺជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីវិនិយោគក្នុងក្របខ័ណ្ឌនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ចែកចេញពីរប្រភេទគឺ ៖

- ជនបរទេសដែលចូលមកកម្ពុជា ដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ

- ជនបរទេសដែលបានទទួលលិខិតអនុញ្ញាតឱ្យវិនិយោគ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួចហើយ ។

**គ). ការចេញ ចូល និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរទេស**

**គ-១). ជនបរទេសមិនមែនអន្តោប្រវេសន្ត**

ជនបរទេសមិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលមានបំណងចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈអាជ្ញាធរទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬតាមអាជ្ញាធរបរទេសណាមួយដែលតំណាងឱ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេស ។ តែចំពោះអ្នកទេសចរណ៍ យានិក នាវិក អ្នកដំណើរឆ្លងកាត់ អាចធ្វើពាក្យសុំនៅនឹងចំណុចច្រកទ្វារអន្តរជាតិណាមួយដែលកំណត់ដោយរាជរដ្ឋាភិបាល ។

| |
|---|
| ចំពោះរយៈពេលស្នាក់នៅរបស់ជនបរទេសមិនមែនអន្តោប្រវេសន្តក្នុងព្រះរាជាណាចក្រកម្ពុជា អាស្រ័យលើប្រភេទទិដ្ឋាការ និងរយៈពេលដែលមានកំណត់នៅក្នុងទិដ្ឋាការនោះ ។ |

**គ-២). ជនបរទេសអន្តោប្រវេសន្ត**

ជនបរទេសអន្តោប្រវេសន្តដែលមានបំណងមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យសុំមកក្រសួងមហាផ្ទៃបាន តាមរយៈអាជ្ញាធរទូត ឬ កុងស៊ុល ឬ តាមរយៈអាជ្ញាធរបរទេសណាមួយ ដែលតំណាងឱ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេស ។

ការទទួលស្គាល់ជនបរទេសណាមួយ ជាជនបរទេសអន្តោប្រវេសន្ត ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

| |
|---|
| ជនបរទេសដែលត្រូវទទួលស្គាល់ ជាជនបរទេសអន្តោប្រវេសន្តដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ត្រូវសុំប័ណ្ណស្នាក់នៅនៅការិយាល័យជនបរទេសនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីបានមកដល់ព្រះរាជាណាចក្រកម្ពុជា ។ |

**គ-៣). ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគ**

ជនបរទេសអន្តោប្រវេសន្ត គឺជាអ្នកវិនិយោគដែលបានទទួលលិខិតអនុញ្ញាតឱ្យវិនិយោគពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬពីស្ថាប័នមានសមត្ថកិច្ចកម្ពុជា មានបំណងចូលមកស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យសុំទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា ដោយផ្ទាល់មកក្រសួងមហាផ្ទៃ ឬតាមរយៈអាជ្ញាធរទូត ឬកុងស៊ុល ឬអាជ្ញាធរបរទេសណាមួយដែលតំណាងឱ្យផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ។

ការទទួលស្គាល់ជនបរទេសណាមួយថា ជាជនបរទេសអន្តោប្រវេសន្ត ជាអ្នកវិនិយោគ ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

| |
|---|
| ជនបរទេសដែលបានទទួលលក្ខណសម្បត្តិជាជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគ ព្រមទាំងគ្រួសារផ្ទាល់អាចស្នាក់នៅជាអចិន្ត្រៃយ៍ ឬតាមរយៈពេលដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបានទទួលប័ណ្ណស្នាក់នៅចេញឱ្យដោយក្រសួងមហាផ្ទៃ ។ |

## ឃ). ការគ្រប់គ្រងធ្វើប័ណ្ណស្នាក់នៅសម្រាប់ជនបរទេស

### ឃ-១). ប្រភេទប័ណ្ណស្នាក់នៅ

ប័ណ្ណស្នាក់នៅសម្រាប់ជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមាន ២ប្រភេទ ៖

☞ ប័ណ្ណស្នាក់នៅបណ្ដោះអាសន្ន សម្រាប់ផ្ដល់ឱ្យជនបរទេសជា ៖

- បុគ្គលិក និងអ្នកជំនាញខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ
- អ្នកលក់សេវា ឬពលកម្មផ្សេងៗ ។

☞ ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សំរាប់ផ្ដល់ឱ្យជនបរទេសជា ៖

- ជនបរទេសអន្តោប្រវេសន្តដែលទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។
- ជនបរទេសជាអ្នកវិនិយោគឯកជន សហព័ទ្ធ និងអ្នកក្នុងបន្ទុកដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ប័ណ្ណស្នាក់នៅទាំងពីរប្រភេទ មិនត្រូវផ្ដល់ឱ្យកុមារទាំងពីរភេទដែលមានអាយុក្រោម ១៨ឆ្នាំទេ ។ កុមារត្រូវចុះឈ្មោះនៅលើប័ណ្ណស្នាក់នៅរបស់ឪពុកម្ដាយ ឬអាណាព្យាបាល ។

### ឃ-២). សមត្ថកិច្ចចេញប័ណ្ណស្នាក់នៅ

ស្នងការនគរបាលរាជធានី ខេត្ត មានភារកិច្ចចេញបង្កាន់ដៃទទួលពាក្យសុំប័ណ្ណស្នាក់នៅ ហើយបញ្ជូនសំណុំលិខិតស្នើសុំប័ណ្ណស្នាក់នៅនេះមកក្រសួងមហាផ្ទៃតាមរយៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេចផ្ដល់ប័ណ្ណស្នាក់នៅ ។

### ឃ-៣). សុពលភាពនៃប័ណ្ណស្នាក់នៅ

ប័ណ្ណស្នាក់នៅបណ្ដោះអាសន្ន មានសុពលភាពមិនលើសពីសុពលភាពនៃទិដ្ឋាការដែលបានផ្ដល់ឱ្យ ។ ប័ណ្ណស្នាក់នៅជាអចិន្ត្រៃយ៍ផ្ដល់ឱ្យលើកដំបូងមានសុពលភាព២ឆ្នាំ ។ ប័ណ្ណស្នាក់នៅនេះអាចសុំបន្តសុពលភាពបានរាល់២ឆ្នាំម្ដង ។

រយៈពេល៣ខែមុនអស់សុពលភាពរបស់ប័ណ្ណស្នាក់នៅ អ្នកកាន់ប័ណ្ណស្នាក់នៅត្រូវប្ដឹងសុំប្ដូរប័ណ្ណស្នាក់នៅថ្មីទៅក្រសួងមហាផ្ទៃតាមរយៈស្នងការនគរបាលរាជធានី ខេត្ត ដែលខ្លួនស្នាក់នៅ ។

ក្នុងករណីបាត់ប័ណ្ណស្នាក់នៅ ម្ចាស់ប័ណ្ណស្នាក់នៅត្រូវប្ដឹងទៅស្នងការនគរបាលរាជធានី ខេត្ត ដោយបញ្ជាក់ហេតុការណ៍ ហើយសុំប័ណ្ណស្នាក់នៅទុតិយតា ។ ស្នងការនគរបាលរាជធានី ខេត្ត ចេញបង្កាន់ដៃទទួលពាក្យសុំប័ណ្ណស្នាក់នៅទុតិយតា ហើយបញ្ជូនសំណុំលិខិតមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងសម្រេច ។

ម្ចាស់ប័ណ្ណស្នាក់នៅដែលមិនបានសុំបន្ត នៅពេលប័ណ្ណស្នាក់នៅផុតកំណត់ ឬសុំប័ណ្ណស្នាក់នៅទុតិយតានៅពេលដែលមានការបាត់បង់ប័ណ្ណស្នាក់នៅ ត្រូវចាត់ថាស្ថិតនៅក្នុងស្ថានភាពមិនត្រឹមត្រូវតាមច្បាប់ ។ អ្នកសុំបន្តសុពលភាពប័ណ្ណស្នាក់នៅ ឬសុំប័ណ្ណស្នាក់នៅទុតិយតា ត្រូវបង់អាករតាមការកំណត់នៃអនុក្រឹត្យ ។

### ឃ-៤). ការផ្លាស់ប្តូរប័ណ្ណស្នាក់នៅ

ក្នុងករណីមានការផ្លាស់ប្តូរលំនៅដ្ឋាន អ្នកកាន់ប័ណ្ណស្នាក់នៅត្រូវសុំការបញ្ជាក់នៅលើប័ណ្ណស្នាក់នៅរបស់ខ្លួន នៅការិយាល័យជនបរទេសនៃស្នងការនគរបាលរាជធានី ខេត្ត ដែលខ្លួនមានលំនៅដ្ឋានមុនពេលចេញដំណើរ។ អ្នកកាន់ប័ណ្ណស្នាក់នៅត្រូវបង្ហាញខ្លួនក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីបានទៅដល់លំនៅដ្ឋានថ្មី។

### ឃ-៥). ការដកហូតយកប័ណ្ណស្នាក់នៅ

ប័ណ្ណស្នាក់នៅទាំងពីរប្រភេទនេះ អាចដកហូតបានក្នុងករណី ៖

- មិនគោរពច្បាប់ស្តីពីអន្តោប្រវេសន៍ ឬ
- មិនគោរពច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ឬ
- ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិផលប្រយោជន៍ជាតិ ឬ
- ធ្វើឱ្យខូចសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

## ១.១.៥. ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើ

ការបោះពុម្ពសៀវភៅអត្រានុកូលដ្ឋាន សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលអំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេស ត្រូវស្ថិតនៅក្នុងបន្ទុកថវិការដ្ឋ។

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅអត្រានុកូលដ្ឋាន សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន។

ការសុំសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើមមួយសន្លឹក នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីទារកប្រសូត និងការសុំសំបុត្រអត្រានុកូលដ្ឋានមរណភាពច្បាប់ដើមមួយសន្លឹកនៅក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីស្លាប់ អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងសុំសំបុត្រអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អ្នកសុំត្រូវបង់ថ្លៃក្រដាសអត្រានុកូលដ្ឋានតាមការកំណត់។

រាល់ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋាន អ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រើ។ ថវិកាដែលបានមកពីការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅឃុំ សង្កាត់ ត្រូវបង់ចូលថវិកាឃុំ សង្កាត់។ ថវិកាដែលបានមកពីការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើ ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ សំបុត្រអាពាហ៍ពិពាហ៍ និងសេចក្តីចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទមួយសន្លឹក អ្នកសុំត្រូវបង់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើទៅតាមការកំណត់ដូចខាងក្រោម ៖

ក). ចំពោះខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ

| ក្រដាសអត្រានុកូលដ្ឋាន | ថ្លៃជាវ (រ) | ថ្លៃតែមប្រឹ (រ) | សរុប (រ) |
|---|---|---|---|
| ពាក្យសុំរៀបអាពាហ៍ពិពាហ៍ | | ១.០០០ | ១.០០០ |
| ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | ២០០ | | ២០០ |
| សំបុត្រអាពាហ៍ពិពាហ៍ | ១០០ | | ១០០ |
| សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត និង សំបុត្របញ្ជាក់ កំណើត | ១០០ | ៣០០ | ៤០០ |
| សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ១០០ | ១.៥០០ | ១.៦០០ |
| សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព | ១០០ | ៤០០ | ៥០០ |

ខ). ចំពោះរាជធានី ខេត្ត ក្រៅពីខេត្តទាំង៥ខាងលើ

| ក្រដាសអត្រានុកូលដ្ឋាន | ថ្លៃជាវ (រ) | ថ្លៃតែមប្រឹ (រ) | សរុប (រ) |
|---|---|---|---|
| ពាក្យសុំរៀបអាពាហ៍ពិពាហ៍ | | ១.០០០ | ១.០០០ |
| ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | ៤០០ | | ៤០០ |
| សំបុត្រអាពាហ៍ពិពាហ៍ | ៤០០ | | ៤០០ |
| សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត និង សំបុត្របញ្ជាក់ កំណើត | ៤០០ | ៣០០ | ៧០០ |
| សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ៤០០ | ១.៥០០ | ១.៩០០ |
| សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព | ៤០០ | ៤០០ | ៨០០ |

### ១.១.៦. បំរាម និងការទទួលខុសត្រូវចំពោះមុខច្បាប់អំពីការងារអត្រានុកូលដ្ឋាន

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង (ហ្វូតូកូពី) មិនមានតម្លៃប្រើប្រាស់ជាផ្លូវការទេ ទោះបីមានការបញ្ជាក់នីត្យានុកូលភាពក៏ដោយ ។

មន្ត្រីអត្រានុកូលដ្ឋាន អាជ្ញាធរក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លង (ហ្វូតូកូពី) នោះទេ ។

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជនណាម្នាក់ផ្សេងទៀត ពីព្រោះសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាមួយជាកម្មសិទ្ធិសម្រាប់តែជននោះប៉ុណ្ណោះ មិនអាចអនុញ្ញាតឱ្យជនដទៃយកទៅប្រើប្រាស់បានឡើយ ។

មិនត្រូវធ្វើការកែតម្រូវបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក ដោយមិនអនុវត្តតាមអំណាច

សាលក្រមស្ថាពររបស់តុលាការ ឬតាមបញ្ញត្តិច្បាប់ ឬដោយគ្មានអំណាចសាលក្រមស្ថាពររបស់តុលាការ

មិនត្រូវធ្វើការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋខុសពីទិន្នន័យដែលមាននៅក្នុងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក ។

មិនត្រូវធ្វើការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ដោយពុំបានយកសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មកធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក

មិនត្រូវធ្វើការថតចម្លងលើក្រដាសសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ដែលក្រសួងមហាផ្ទៃបានផ្តល់ជូនយកទៅថតចម្លងរួចចុះហត្ថលេខាបោះត្រាចម្លងចេញជូនប្រជាពលរដ្ឋប្រើប្រាស់

មិនត្រូវឱ្យបង់ថ្លៃក្រដាស និងតែមប្រ៊ីលើសពីការកំណត់

មិនត្រូវធ្វើការកោស ឆូត លុប ដោយប្រើទឹកលុប ហើយសរសេរជ្រៀតបន្ថែម ឬកែទិន្នន័យនៅលើបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន ឬលើសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ។

ក្នុងករណីដែលពិនិត្យឃើញសំបុត្រអត្រានុកូលដ្ឋានចាស់ពីមុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ណាមួយដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋាននោះមកវិញ រួចណែនាំឱ្យសាមីខ្លួនបំពេញបែបបទសុំចុះសៀវភៅអត្រានុកូលដ្ឋានថ្មី ។

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗលើសពី០១ដង និងនៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន **ដែលមានកោស ឆូត លុប សរសេរជ្រៀតថែម** មិនមានតំលៃប្រើប្រាស់ជាផ្លូវការនោះទេ ។

ហាមយកអនីតិជន (អ្នកមានអាយុតិចជាង១៨ឆ្នាំ) ធ្វើជាសាក្សី ។

អនីតិជន មិនត្រូវបានអនុញ្ញាតឱ្យផ្តិតមេដៃនៅលើបញ្ជីអត្រានុកូលដ្ឋានឡើយ ។

មានតែក្រដាសអត្រានុកូលដ្ឋានដែលផ្តល់ជូនដោយក្រសួងមហាផ្ទៃប៉ុណ្ណោះ ដែលមានតម្លៃប្រើប្រាស់ជាផ្លូវការ ។ ហាមបកប្រែជាភាសាបរទេស នៅលើក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលផ្តល់ជូនដោយក្រសួងមហាផ្ទៃ

ហាមមន្ត្រីអត្រានុកូលដ្ឋាន អនុវត្តការសរសេរចុះសៀវភៅអត្រានុកូលដ្ឋាន សំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ខុសពីនីតិវិធីដែលបានកំណត់ ។

សាមីខ្លួន និងឬ អ្នករាយការណ៍ និងឬសាក្សីត្រូវសំដែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬឃើញផ្ទាល់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្តីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

ជនណារាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬយកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬរាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពី០១ដង នៅទីកន្លែងដដែល ឬទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ឬបានទារប្រាក់លើស

ច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។ សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ នឹងប្តឹងទៅតុលាការ ដើម្បីបដិសេធ និងសុំផ្តន្ទាទោសតាមច្បាប់។

### ១.១.៧. ការដាក់ពិន័យ

ក). ប្រជាពលរដ្ឋខ្មែរដែលបានកើតហើយទុកឱ្យហួសរយៈពេល៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតនៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីចំនួន០២រូបជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដមកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតសាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ត្រូវបង់ថ្លៃ១.០០០រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និងបង់ថ្លៃ ៤.០០០រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ។

ខ). ករណីមានអ្នកស្លាប់ទុកឱ្យហួសដែលមានរយៈពេលដែលកំណត់ដោយច្បាប់ ត្រូវអនុវត្តដូចខាងក្រោម៖

ខ-១). បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល១៥ថ្ងៃនៅក្នុងឆ្នាំ ពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវដាក់ពាក្យប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់ នៃលំនៅឋានពិតប្រាកដរបស់អ្នកស្លាប់។ ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៃអ្នកស្លាប់ ត្រូវបង់ថ្លៃ ១.០០០ រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ឧត្តរមានជ័យ ព្រះវិហារ និងបង់ថ្លៃ ៤.០០០រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ។

ខ-២). បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូដ្ឋានមរណភាពទេ ក្រុម-គ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសាលក្រមពីសាលាដំបូងរាជធានី ខេត្ត រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។

**បញ្ជាក់** ៖

☞ ចំពោះអ្នកស្លាប់នៅចុងខែធ្នូនៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល១៥ថ្ងៃអាចឆ្លងចូលដល់ឆ្នាំបន្ទាប់ ក្រុមគ្រួសារនៃអ្នកស្លាប់អាចប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅក្នុងឆ្នាំកំពុងអនុវត្ត ឬនៅឆ្នាំបន្ទាប់បាន។

☞ ចំពោះអ្នកស្លាប់នៅចុងខែធ្នូនៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល១៥ថ្ងៃឆ្លងចូលដល់ឆ្នាំបន្ទាប់ តែទុកឱ្យហួសរយៈពេល១៥ថ្ងៃ ក្រុមគ្រួសារនៃអ្នកស្លាប់អាចប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឆ្នាំបន្ទាប់បាន ដោយត្រូវអនុវត្តតាមបែបបទចំណុច “ខ” (ខ-១, ខ-២)។

## ១.២. និយមន័យអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែងដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និង ដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់នៃច្បាប់ព្រះរាជាណាចក្រកម្ពុជា។

សំបុត្រអត្រានុកូលដ្ឋានរួមមាន ៖ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។

## ១.៣. សារប្រយោជន៍អត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន ជាសេវាមូលដ្ឋានរបស់រដ្ឋដែលផ្តល់ប្រយោជន៍ចំពោះប្រជាពលរដ្ឋផង និង ចំពោះសង្គមជាតិផង។ អត្រានុកូលដ្ឋានជាកត្តាមួយចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសង្គមមានភាពសុខសាន្ត និងសុវត្ថិភាពដ៏រឹងមាំ។ សៀវភៅអត្រានុកូលដ្ឋានបានតម្កល់ទុកជាសក្ខីកម្មដែលមានប្រយោជន៍សម្រាប់ទិន្នន័យវិភាគនូវឯកសារសុខភាព អប់រំ និងសេវាសង្គមគ្រប់ប្រភេទ ដូចជា សម្រាប់ធ្វើបញ្ជីបោះឆ្នោត ទិញលក់ដីធ្លី ទិញលក់ចលនទ្រព្យ និងអចលនទ្រព្យ និងសម្រាប់ទារពន្ធដារ ជាដើម។

អត្រានុកូលដ្ឋានផ្តល់នូវសារប្រយោជន៍សំខាន់ពីរយ៉ាង គឺចំពោះសង្គមជាតិ និងចំពោះខ្លួនយើង។

### ១.៣.១. ចំពោះសង្គមជាតិ

☞ ជួយពង្រឹងនីតិរដ្ឋ និងអភិវឌ្ឍប្រទេសជាតិៈ មានន័យថា អត្រានុកូលដ្ឋានជាយុទ្ធសាស្ត្ររួមក្នុងការធានានូវការអនុវត្តច្បាប់ ពីព្រោះថាបើប្រជាពលរដ្ឋមានឯកសារអត្រានុលដ្ឋានគ្រប់ៗគ្នានោះ ការប្រតិបត្តិច្បាប់ និងដំណើរការស្ថាប័ននានា អាចប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

**ឧទាហរណ៍** បើប្រជាពលរដ្ឋបានបំពេញកាតព្វកិច្ចចុះអត្រានុកូលដ្ឋានគ្រប់ៗរូប នោះវានឹងផ្តល់លទ្ធភាពងាយស្រួលដល់រដ្ឋក្នុងការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ ងាយស្រួលក្នុងការលើកផែនការអភិវឌ្ឍន៍។

**ឧទាហរណ៍** បើរដ្ឋឃើញថា តំបន់ណាមួយ ឬខេត្តណាមួយមានអត្រាកំណើតខ្ពស់ រដ្ឋត្រូវត្រៀមសាលារៀន និងគ្រូបង្រៀន។ ផ្ទុយទៅវិញ បើអត្រាមរណភាពខ្ពស់ ត្រូវរកវិធានការដើម្បីទប់ទល់ ដោយលើកតម្កើងការផ្តល់សេវាសន្តិសុខ និងសុខភាព។

ម្យ៉ាងទៀតក្នុងការលើកស្ទួយសិទ្ធិមនុស្ស ការចុះសៀវភៅអាពាហ៍ពិពាហ៍នាំឱ្យសហព័ទ្ធត្រូវគោរពសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដូចជា ជួយទប់ស្កាត់ប្តី ឬប្រពន្ធមិនឱ្យទៅរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលផ្សេងទៀតតាមទំនើងចិត្តបាន។

☞ លើកកម្ពស់កិត្យានុភាពជាតិ ៖ បើប្រជាពលរដ្ឋយើងមានសំណុំឯកសារផ្ទាល់ខ្លួនគ្រប់ៗគ្នានោះ មានន័យថាពលរដ្ឋយើងបានបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយតម្រូវឱ្យខ្លួនមានករណីយកិច្ចក្នុងសង្គម ដែលជាហេតុធ្វើឱ្យសង្គមមានការអភិវឌ្ឍតាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។ ទាំងនេះហើយជាភាពថ្លៃថ្នូរ និងកិត្តិយសរបស់ប្រទេសជាតិ។

☞ ជួយពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រោះថាឯកសារអត្រានុកូលដ្ឋានបានបង្ហាញប្រាប់នូវអត្តសញ្ញាណនៃរូបវន្តបុគ្គលក្នុងទំនាក់ទំនងគតិយុត្ត (សកម្មភាពទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ច)។ ហេតុដូចនេះឯកសារអត្រានុកូលដ្ឋានមានប្រយោជន៍ជាសំណុំលិខិតយុត្តិកម្មដែលត្រូវយកជាភស្តុតាងក្នុងនីតិវិធីតុលាការ ។

### ១.៣.២. ចំពោះពលរដ្ឋ

- សម្រាប់បញ្ជាក់ពីស្ថានភាព ឋានៈ និងសិទ្ធិនៅក្នុងរង្វង់គ្រួសារ
- សម្រាប់សុំលិខិតឆ្លងដែន
- សម្រាប់សុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងចេញសៀវភៅគ្រួសារ និងប័ណ្ណស្នាក់នៅ

- សម្រាប់សុំចូលបម្រើការងារផ្សេងៗ ដើម្បីបញ្ជាក់ថា បុគ្គលម្នាក់មានអាយុអាចបំពេញការងារបាន
- សម្រាប់ចុះឈ្មោះចូលរៀនតាមគ្រឹះស្ថានសិក្សានានារបស់ស្ថាប័នរដ្ឋ និងឯកជន (គ្រប់អាយុចូលរៀន)
- សម្រាប់ចុះឈ្មោះបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត
- សម្រាប់ការពារនូវសិទ្ធិរបស់បុគ្គលម្នាក់ ជាពិសេស ស្ត្រី និងកុមារ
- សម្រាប់ពេលសវនាការ ឬពេលដោះស្រាយវិវាទ ។

| |
|---|
| ការមិនបានចុះសៀវភៅអត្រានុកូលដ្ឋាននាំឱ្យពលរដ្ឋបាត់បង់អត្តសញ្ញាណផ្ទាល់ខ្លួន ។ ការបាត់បង់នេះអាចនឹងបង្កការលំបាកក្នុងសង្គមពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួនពលរដ្ឋ និងខកខានមិនបានបំពេញករណីយកិច្ចចំពោះគ្រួសារ ក៏ដូចជាចំពោះប្រទេសជាតិ ជាពិសេសពាក់ព័ន្ធក្នុងនីតិវិធីរដ្ឋបាលក៏ដូចជានីតិវិធីតុលាការដែរ គេត្រូវការភស្តុតាងជាសំអាងនៅចំពោះមុខច្បាប់ ។ |

## ១.៤. តួនាទី និងភារកិច្ចរបស់សមត្ថកិច្ចអនុវត្តការងារអត្រានុកូលដ្ឋាន

ការសុំចុះអត្រានុកូលដ្ឋាន ក្នុងសៀវភៅអត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។ ដូច្នេះ រដ្ឋបានរៀបចំយន្តការដើម្បីធានានូវការបម្រើសេវានេះឱ្យមានប្រសិទ្ធភាព ដោយបែងចែកសមត្ថកិច្ច និងការទទួលខុសត្រូវ ដើម្បីអនុវត្តការងារនេះ ដូចខាងក្រោម ៖

### ១.៤.១. តួនាទី និងភារកិច្ចរបស់សមត្ថកិច្ចក្នុងប្រទេស

**ក). ថ្នាក់ក្រសួង ៖**

នាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួងលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន និងមានភារកិច្ចដូចខាងក្រោម ៖

១. សិក្សាស្រាវជ្រាវរៀបចំលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន ។

២. ណែនាំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ ។

៣. ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងប្រទេស ។

៤. បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅគ្រប់រាជធានី ខេត្តទូទាំងប្រទេស រួចហើយរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ។

៥. លើកផែនការស្នើសុំបោះពុម្ពសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់ផ្តល់ជូនដល់រាជធានី ខេត្តឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។

៦. រៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការអប់រំសាធារណជនអំពីការងារអត្រានុកូលដ្ឋាន ។

៧. រៀបចំអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន ។

៨. បញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រព័ន្ធព័ត៌មានវិទ្យា ។

៩. អនុវត្តការងារចាំបាច់ផ្សេងៗទៀតដែលទាក់ទងនឹងការងារស្ថិតិ និងអត្រានុកូលដ្ឋាន ។

| |
|---|
| **បញ្ជាក់** ៖ ករណីពុំមានសៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ក្រសួងត្រូវឆ្លើយតបជាលាយល័ក្ខណ៍អក្សរទៅរាជធានី ខេត្តវិញ នៅក្នុងអំឡុងពេល១០ថ្ងៃការងារ បន្ទាប់ពីទទួលបានសំណើសុំរបស់រាជធានី ខេត្ត ។ |

**ខ). ថ្នាក់រាជធានី ខេត្ត ៖**

អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន នៅរាជធានី ខេត្តរបស់ខ្លួន ដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃទីចាត់ការរដ្ឋបាលសាលារាជធានី ខេត្តជាសេនាធិការ និងមានភារកិច្ចដូចខាងក្រោម ៖

១. ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងរាជធានី ខេត្ត និងផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃតាមការកំណត់។

២. ត្រួតពិនិត្យការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

៣. បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែ និង ផ្ញើរបាយការណ៍ទៅក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ) រៀងរាល់ថ្ងៃទី១៥ នៃខែបន្ទាប់នីមួយៗ។

៤. លើកគម្រោងទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់ផ្តល់ឱ្យក្រុង ស្រុក ខណ្ឌ ធ្វើការបែងចែកដល់ឃុំ សង្កាត់ និងផ្ញើរបាយការណ៍បូកសរុបការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានឱ្យទាន់ពេលកំណត់។

៥. សហការរៀបចំការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងការអប់រំសាធារណជនអំពីការងារអត្រា-នុកូលដ្ឋាន។

៦. ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំអំពីការងារអត្រានុកូលដ្ឋានដល់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ចំណុះ។

៧. ធ្វើការវាយតម្លៃការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋានក្នុងរាជធានី ខេត្តរបស់ខ្លួន។

៨. អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និងអត្រានុកូលដ្ឋាន។

**បញ្ជាក់** ៖

- នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានរាជធានី ខេត្តត្រូវធ្វើសំណើសុំទៅក្រសួងមហាផ្ទៃដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ។
- ករណីពុំមានសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានរាជធានី ខេត្តត្រូវឆ្លើយតបជាលាយល័ក្ខណ៍អក្សរទៅក្រុង ស្រុក ខណ្ឌវិញ នៅក្នុងអំឡុងពេល១០ថ្ងៃការងារ បន្ទាប់ពីទទួលបានសំណើសុំរបស់ក្រុង ស្រុក ខណ្ឌ ។

គ). ថ្នាក់ក្រុង ស្រុក ខណ្ឌ ៖

អភិបាលក្រុង ស្រុក ខណ្ឌទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌរបស់ខ្លួន ដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានភារកិច្ចដូចខាងក្រោម ៖

១. ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងក្រុង ស្រុក ខណ្ឌ និងផ្ញើរបាយការណ៍មករាជធានី ខេត្ត តាមការកំណត់ ។

២. បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែនីមួយៗ តាមឃុំ សង្កាត់ចំណុះ និងផ្ញើទៅការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃទីចាត់ការរដ្ឋបាលសាលារាជធានី ខេត្ត រៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់នីមួយៗ ។

៣. លើកគម្រោងទៅសាលារាជធានី ខេត្ត ដើម្បីស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់បែងចែកជូនឃុំ សង្កាត់ និងបូកសរុបការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ផ្ញើមករាជធានី ខេត្ត តាមការកំណត់ ។

៤. មុននឹងបញ្ជូនសៀវភៅអត្រានុកូលដ្ឋានទៅឱ្យឃុំ សង្កាត់យកទៅប្រើប្រាស់ត្រូវ ៖
- បំពេញសន្លឹកដើមដំបូងបំផុត
- ចុះលេខរៀងសន្លឹកនៃសៀវភៅអត្រានុកូលដ្ឋាន
- ដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីចុះហត្ថលេខា (ហត្ថលេខាពេញ និងសង្ខេប) និងបោះត្រា ។

៥. ត្រួតពិនិត្យជាប្រចាំ ការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមឃុំ សង្កាត់ ។

៦. ត្រួតពិនិត្យរាល់បញ្ជីក្នុងសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលឃុំ សង្កាត់ផ្ញើមកក្រុង ស្រុក ខណ្ឌ ពេលដាច់ឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងមហាផ្ទៃ ។

៧. រក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋានឱ្យបានគត់មត់នៅសាលាក្រុង ស្រុក ខណ្ឌមួយច្បាប់ តាមប្រភេទនីមួយៗ និងមួយច្បាប់ទៀតដូចគ្នាផ្ញើទៅរក្សាទុកនៅសាលារាជធានី ខេត្តសាមី ។

៨. ចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋានគ្រប់ប្រភេទ ជូនដល់ប្រជាពលរដ្ឋដែលមកសុំចម្លងនៅឆ្នាំដែលកន្លងផុត (ឆ្នាំដាច់ទៅ) ។

៩. ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំអំពីការងារអត្រានុកូលដ្ឋានដល់ឃុំ សង្កាត់ចំណុះ ។

១០. ធ្វើការវាយតម្លៃការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋានក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួន ។

១១. ត្រូវធ្វើសំណើសុំទៅអភិបាលរាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ។

១២. អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និងអត្រានុកូលដ្ឋាន ។

**បញ្ជាក់ ៖**

- នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ក្រុង ស្រុក ខណ្ឌត្រូវធ្វើសំណើសុំទៅរាជធានី ខេត្តដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ។
- ករណីពុំមានសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌត្រូវឆ្លើយតបជាលាយល័ក្ខណ៍អក្សរ ទៅឃុំ សង្កាត់វិញ នៅក្នុងអំឡុងពេល១០ថ្ងៃការងារ បន្ទាប់ពីទទួលបានសំណើសុំរបស់ឃុំ សង្កាត់ ។

☞ នៅពេលទទួលបានសាលក្រមស្ថាពររបស់តុលាការ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវសរសេរយោង នៅរឹមទំព័រខាងឆ្វេងនៃបញ្ជីអត្រានុកូលដ្ឋាន ដូចខាងក្រោម ៖

បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព

យោងសាលក្រម-------------- លេខ------- ចុះថ្ងៃទី----- ខែ------- ឆ្នាំ-------

របស់តុលាការ--------------------------------- ។

ថ្ងៃទី------ ខែ-------- ឆ្នាំ------

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន

(ហត្ថលេខា និងឈ្មោះ)

☞ នៅពេលទទួលបានសាលក្រមស្ថាពររបស់តុលាការ មន្ត្រីរក្សាអត្រានុកូលដ្ឋានត្រូវចេញសំបុត្រអត្រានុកូល-ដ្ឋានជាថ្មីឱ្យទៅសាមីខ្លួន ដោយយោងតាមខ្លឹមសារនៃ សាលក្រមស្ថាពររបស់តុលាការ ។

### ឃ). ថ្នាក់ឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ដែលខ្លួនគ្រប់គ្រង ។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។ មន្ត្រីអត្រានុកូលដ្ឋាន មានភារកិច្ចដូចខាងក្រោម ៖

១. លើកគម្រោងស្នើសុំសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានមកសាលាក្រុង ស្រុក ខណ្ឌ សម្រាប់ប្រើប្រាស់ នៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

២. ចលនាប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យមកចុះសៀវភៅអត្រានុកូលដ្ឋានឱ្យបានគ្រប់ៗគ្នា និងទាន់ពេលវេលា ។

៣. ទទួលពិនិត្យ និងកត់ត្រារឿងហេតុសំខាន់ៗទាក់ទងទៅនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាព នៃជនទាំងឡាយ ចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

៤. ចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋាន ទៅតាមការស្នើសុំរបស់ប្រជាពលរដ្ឋ នៅឆ្នាំដែលមិនទាន់ដាច់ ។

៥. អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសព ។

៦. ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្ត ។

៧. ចុះហត្ថលេខា និងបោះត្រាលើបញ្ជី និងសំបុត្រអត្រានុកូលដ្ឋាន ។

៨. កែតម្រូវ ឬបដិសេធសំបុត្រអត្រានុកូលដ្ឋានតាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទ-បញ្ញត្តិនៃច្បាប់ ។

៩. ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋានតាមប្រភេទឱ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង ។

១០. បិទសៀវភៅអត្រានុកូលដ្ឋាន នៅពេលប្រើប្រាស់អស់បញ្ជី និងនៅដំណាច់ឆ្នាំនីមួយៗ ក្រោយពីបានពិនិត្យត្រឹមត្រូវរួចរាល់អស់ហើយ ។

១១. បញ្ជូនសៀវភៅអត្រានុកូលដ្ឋានដែលបិទបញ្ជីរួចទៅសាលាក្រុង ស្រុក ខណ្ឌ នៅដើមខែមករានៃឆ្នាំបន្ទាប់ ដើម្បីយកទៅតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌផ្ទាល់មួយច្បាប់ និងនៅសាលារាជធានី ខេត្តសាមីមួយច្បាប់ ។

១២. ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ឱ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមកទំនាក់ទំនងពីការងារអត្រានុកូលដ្ឋាន ។

១៣. ផ្ញើរបាយការណ៍អំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ជារៀងរាល់ខែនាថ្ងៃទី០៥នៃខែបន្ទាប់ និងរាល់ដំណាច់ឆ្នាំនីមួយៗផ្ញើទៅសាលាក្រុង ស្រុក ខណ្ឌសាមី ។

១៤. សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋានអំពីការងារអត្រានុកូលដ្ឋាន ក្នុងករណីចាំបាច់ ។

១៥. មេឃុំ ចៅសង្កាត់អាចប្រើប្រាស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីជួយក្នុងការផ្សព្វផ្សាយអំពីសារៈប្រយោជន៍អត្រានុកូលដ្ឋាន ឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ ដូចខាងក្រោម ៖

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវជំរុញការផ្សព្វផ្សាយជូនប្រជា-ពលរដ្ឋឱ្យយល់ជ្រួតជ្រាបអំពីសិទ្ធិនារី និងកុមារ ពិសេសផលប្រយោជន៍នៃការចុះបញ្ជីអត្រានុ-កូលដ្ឋាន រួមមាន កំណើត អាពាហ៍ពិពាហ៍ និងមរណភាព និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចុះសៀវភៅអត្រានុកូលដ្ឋាន ។
- មេឃុំ ចៅសង្កាត់ ជំទប់ទី២ ឬចៅសង្កាត់រងទី២ ត្រូវចលនានៅតាមវត្តអារាម ដើម្បីសំណូមពរដល់ព្រះសង្ឃ អាចារ្យវត្ត នៅពេលមានបុណ្យទាន ឬពេលមានពិធីរៀបអាពាហ៍ពិពាហ៍ ឬពិធីបុណ្យសព សូមជួយផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋអញ្ជើញទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ពេលមានទារកកើត ទៅចុះសៀវភៅអាពាហ៍ពិពាហ៍ពេលមានរៀបអាពាហ៍ពិពាហ៍ និងទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ពេលមានអ្នកស្លាប់ ។
- សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវចុះផ្សព្វផ្សាយផ្ទាល់នៅតាមភូមិ ឬតាមផ្ទះប្រជាពលរដ្ឋ ដើម្បីជម្រាបអំពីសារប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ។
- សមាជិកនៃគណៈកម្មាធិការទ្រទ្រង់មណ្ឌលសុខភាពដែលតំណាងឱ្យឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយផ្ទាល់នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យរដ្ឋ និងឯកជន ពេលមាននារីមកសម្រាលកូននៅមណ្ឌល-

សុខភាព ឬមន្ទីរពេទ្យ ពេលចេញទៅវិញត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យទារកនៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកកុំឱ្យហួសពី៣០ថ្ងៃ បន្ទាប់ពីប្រសូតទារក និងនៅពេលមានអ្នកស្លាប់នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យត្រូវជម្រាបដល់ក្រុម-គ្រួសារ ឬ សាច់ញាតិសន្តាននៃសពឱ្យទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពក្នុងរយៈពេល ១៥ថ្ងៃ នៅឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកស្លាប់ ដោយមណ្ឌលសុខភាព ឬមន្ទីរពេទ្យចេញនូវលិខិតបញ្ជាក់អំពីកំណើតទារកជូនឪពុកម្តាយទារក ឬលិខិតបញ្ជាក់អំពីមរណភាពជូនទៅក្រុមគ្រួសារ ឬសាច់ញាតិសន្តាននៃអ្នកស្លាប់។

- សមាជិកនៃគណៈកម្មាធិការដែលតំណាងឱ្យគ្រូបង្រៀនត្រូវចលនាជម្រាបជូនលោកគ្រូ អ្នកគ្រូនៅតាមសាលារៀន សំណូមពរឱ្យជួយផ្សព្វផ្សាយជាប្រចាំក្នុងពីរសប្តាហ៍ម្តងដល់សិស្ស ដើម្បីជម្រាបទៅឪពុក ម្តាយនៃសិស្សទាំងនោះបានជ្រាបពីសារប្រយោជន៍នៃការចុះសៀវភៅអត្រានុកូលដ្ឋាន។

១៦. មេឃុំ ចៅសង្កាត់អាចស្នើឱ្យអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជួយផ្សព្វផ្សាយអំពីសារប្រយោជន៍អត្រានុកូលដ្ឋាន និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋចំពោះការចុះសៀវភៅអត្រានុកូលដ្ឋានដូចខាងក្រោម ៖

- ពេលមានទារកកើត ឪពុក ម្តាយត្រូវទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត កុំឱ្យហួសពី៣០ថ្ងៃ បន្ទាប់ពីប្រសូតទារកនៅសាលាឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារក។
- ពេលបុរស នារីសុំរៀបអាពាហ៍ពិពាហ៍ ត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណី និងបទបញ្ញត្តិមួយចំនួនដែលនៅជាធរមាន នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ហើយត្រូវទៅសុំចុះសៀវភៅអត្រានុ-កូលដ្ឋានអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ នៃលំនៅឋាននារី ទើបអាពាហ៍ពិពាហ៍នោះចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់។
- ពេលមានអ្នកស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាននៃអ្នកស្លាប់ ត្រូវទៅចុះសៀវភៅអត្រានុកូល-ដ្ឋានមរណភាព ក្នុងរយៈពេល១៥ថ្ងៃ នៅឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកស្លាប់។

**បញ្ជាក់** ៖

- មន្ត្រីអត្រានុកូលដ្ឋាន មានសិទ្ធិមិនចុះអត្រានុកូលដ្ឋានឱ្យទៅជនណាមួយដែលខ្លួនយល់ឃើញថា ជននោះមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមិនមែនជាប្រជាពលរដ្ឋខ្មែរ ។
- នៅពេលជិតអស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ឃុំ សង្កាត់ត្រូវធ្វើសំណើសុំទៅអភិបាលក្រុង ស្រុក ខណ្ឌ ដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន។ លិខិតស្នើសុំនេះ ត្រូវចម្លងជូនរាជធានី ខេត្ត ដើម្បីជូនជ្រាប។

**នីតិវិធីបន្ទាប់ពីទទួលបានសាលក្រមស្ថាពររបស់តុលាការ ចំពោះឆ្នាំដែលមិនទាន់ដាច់**

☞ នៅពេលទទួលបានសាលក្រមស្ថាពររបស់តុលាការ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរយោងនៅរឹមទំព័រខាងឆ្វេងនៃបញ្ជីអត្រានុកូលដ្ឋានដែលបានចុះរួចហើយ ដូចខាងក្រោម ៖

| |
|---|
| បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព |
| យោងសាលក្រម-------------- លេខ------- ចុះថ្ងៃទី----- ខែ------- ឆ្នាំ------- |
| របស់តុលាការ------------------------------- ។ |
| ថ្ងៃទី------ ខែ-------- ឆ្នាំ------ |
| មន្ត្រីអត្រានុកូលដ្ឋាន |
| (ហត្ថលេខា និងត្រា) |
| (ឈ្មោះ) |

☞ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋាន ត្រូវចុះបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន និងឬចេញសំបុត្រអត្រានុកូលដ្ឋានជាថ្មីឱ្យទៅសាមីខ្លួន ដោយយោងតាមខ្លឹមសារនៃសាលក្រមស្ថាពររបស់តុលាការ ។

**ង). ថ្នាក់ភូមិ ៖**

១. មេភូមិត្រូវចលនាឱ្យប្រជាពលរដ្ឋទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងមរណភាព ឱ្យបានទាន់ពេលវេលា និងចលនាអ្នកដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ដើម្បីឱ្យស្របទៅតាមច្បាប់ ត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ នៅសាលាឃុំ សង្កាត់ខាងលំនៅឋាននារី ស្របតាមក្រមរដ្ឋប្បវេណី និងបទបញ្ញត្តិមួយចំនួនដែលនៅជាធរមាននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ។

២. មេភូមិត្រូវចេញលិខិតបញ្ជាក់ទទួលស្គាល់កំណើតទារកឱ្យឪពុកម្តាយទារក បើទារកកើតនៅផ្ទះ ដើម្បីឱ្យឪពុកម្តាយទារកមានឯកសារភស្តុតាងសម្រាប់ទៅសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៅលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឱ្យកូន ។

៣. មេភូមិត្រូវកត់ត្រាប្រចាំខែនីមួយៗ ឱ្យបានច្បាស់លាស់នូវស្ថិតិ ៖

- ទារកដែលទើបកើត
- ទារកដែលទើបកើត ហើយស្លាប់
- អ្នកដែលបានរៀបអាពាហ៍ពិពាហ៍ និងអ្នកដែលរួមរស់ជាមួយគ្នាក្នុងស្ថានភាពប្តី ប្រពន្ធ
- អ្នកដែលទទួលមរណភាព ។

៤. មេភូមិត្រូវស្រង់ស្ថិតិ និងផ្ញើស្ថិតិនេះទៅសាលាឃុំ សង្កាត់ នៅថ្ងៃទី០៣នៃខែបន្ទាប់ ដើម្បីធ្វើការបូកសរុប ។ ស្ថិតិដែលមេភូមិត្រូវស្រង់ ៖

- ទារកដែលបានសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតទាន់ពេលកំណត់៣០ថ្ងៃរួចហើយ និងទារកដែលមិនទាន់បានសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតហួសពេលកំណត់ ៣០ ថ្ងៃ

- អ្នកទទួលមរណភាពដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទាន់ពេលកំណត់១៥ថ្ងៃ និង អ្នកទទួលមរណភាពទុកឱ្យហួស១៥ថ្ងៃ ពុំបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព
- អ្នកដែលបានរៀបអាពាហ៍ពិពាហ៍ខាងស៊ីវិល (បានសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រួច) និងអ្នកដែលបានអាពាហ៍ពិពាហ៍តាមប្រពៃណី តែមិនទាន់បានរៀបចំអាពាហ៍ពិពាហ៍ខាងស៊ីវិល (ពុំទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍) ។

៥. ផ្អែកលើស្ថិតិដែលបានស្រង់នេះ មេភូមិត្រូវជំរុញ ៖

- ឪពុក ម្ដាយ ឬអាណាព្យាបាលទារកដែលទើបនឹងកើត ទៅចុះបញ្ជីកំណើតឱ្យទារកនៅសាលាឃុំ សង្កាត់ ឱ្យបានទាន់ពេលវេលា គឺកុំឱ្យហួសរយៈពេល៣០ថ្ងៃ បន្ទាប់ពីទារកប្រសូត ។
- ក្រុមគ្រួសារនៃអ្នកស្លាប់ ទៅចុះបញ្ជីអត្រានុកូលដ្ឋានមរណភាពនៅសាលាឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា គឺកុំឱ្យហួសរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលមរណភាព ។
- អ្នកដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួច ទៅចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅសាលាឃុំ សង្កាត់ ។

### ១.៤.២. តួនាទី និងភារកិច្ចរបស់សមត្ថកិច្ចក្រៅប្រទេស

រាល់ការអនុវត្តការងារអត្រានុកូលដ្ឋាននៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រ-កម្ពុជាប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន ដូចការងារអត្រានុកូលដ្ឋានដែលបានអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើសេចក្ដីណែនាំបន្ថែមដោយប្រកាសរួម ។

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី ០១រូបនៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឱ្យទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្ដីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយជូនព័ត៌មានទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ១.៥. សៀវភៅអត្រានុកូលដ្ឋាន

### ១.៥.១. ប្រភេទសៀវភៅអត្រានុកូលដ្ឋាន

☞ សៀវភៅអត្រានុកូលដ្ឋាន រួមមាន ៖

- សៀវភៅអត្រានុកូលដ្ឋានកំណើត
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ (បានអនុវត្តក្នុងអំឡុងឆ្នាំ២០០២-២០០៧)

- សៀវភៅអត្រានុកូលដ្ឋានមរណភាព
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព (បានអនុវត្តក្នុងអំឡុងឆ្នាំ២០០២-២០០៧)
- សៀវភៅអត្រានុកូលដ្ឋានកំណើតជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានមរណភាពជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់

☞ សៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវសរសេរជា២ក្បាល (សៀវភៅភ្លោះ) មានខ្លឹមសារដូចគ្នាទាំងស្រុងតាមប្រភេទនីមួយៗ។

☞ សៀវភៅទាំងនេះ សាលាក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនទៅឱ្យឃុំ សង្កាត់ក្នុងអំឡុងខែធ្នូនៃឆ្នាំនីមួយៗ។ ក្នុងឆ្នាំនៅពេលដែលប្រើប្រាស់ជិតអស់ ឃុំ សង្កាត់ត្រូវទៅសុំពីសាលាក្រុង ស្រុក ខណ្ឌ ដើម្បីត្រៀមទុកអនុវត្តបន្ត។

☞ សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែមករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ។

☞ នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនសៀវភៅអត្រានុកូលដ្ឋាននៃប្រភេទនីមួយៗ ដែលបានកត់ត្រារួច ៖

- ០១ច្បាប់ ទៅសាលាក្រុង ស្រុក ខណ្ឌសាមី ដើម្បីត្រួតពិនិត្យ និងតម្កល់ទុកនៅទីនោះ និង
- ០១ច្បាប់ទៀត ទៅតម្កល់ទុកនៅសាលារាជធានី ខេត្តសាមី ។

☞ សៀវភៅអត្រានុកូលដ្ឋានដែលបានប្រើប្រាស់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅខែមករា ឆ្នាំបន្ទាប់ មកតម្កល់ទុក០១ច្បាប់នៅក្រសួងមហាផ្ទៃ និង០១ច្បាប់ទៀតនៅក្រសួងយុត្តិធម៌។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំទុកដាក់សៀវភៅអត្រានុកូលដ្ឋាន និងសំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានឱ្យបានគង់វង្ស។

☞ មន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវរក្សាការសម្ងាត់របស់បុគ្គលម្នាក់ៗ គឺមិនត្រូវនិយាយឱ្យអ្នកផ្សេងដឹងឮ ឬអនុញ្ញាតឱ្យអ្នកដែលគ្មានភារកិច្ចបើកមើលឡើយ។

☞ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់សៀវភៅអត្រានុកូលដ្ឋានដែលឃុំ សង្កាត់ផ្ញើមក ដោយតម្កល់ទុកឱ្យបានគង់វង្សតាមប្រភេទនីមួយៗតាមឃុំ សង្កាត់ តាមលំដាប់ឆ្នាំ និងតាមលេខរៀងសៀវភៅឱ្យបានត្រឹមត្រូវ។

☞ ករណីបាត់បង់ ឬខូចខាតសៀវភៅអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានត្រូវធ្វើកំណត់ហេតុត្រឹមត្រូវស្តីពីការបាត់បង់ ឬខូចខាតនេះ ផ្ញើទៅក្រសួងមហាផ្ទៃ និងឬក្រសួងយុត្តិធម៌ជាបន្ទាន់ ដោយបញ្ជូនតាមរយៈសាលាក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តសាមី។ ក្រោយពីមានសេចក្តីណែនាំអន្តរក្រសួង ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ទើបធ្វើការចម្លង ឬសម្រង់ចេញពីសំបុត្រអត្រានុកូលដ្ឋាន ឬសំបុត្របញ្ជាក់អត្រានុកូលដ្ឋានដែលសាមីខ្លួនអ្នកសុំមាន រួចប្រគល់ឱ្យយកទៅប្រើប្រាស់តាមផ្លូវច្បាប់។

**គំរូសៀវភៅអត្រានុកូលដ្ឋាន ÷**

ក្របមុខ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** ------------------- **សៀវភៅកំណើតលេខ**---------------

**ស្រុក ខណ្ឌ** ------------------- **ឆ្នាំ**-----------------------------------

**ឃុំ សង្កាត់** -------------------

# សៀវភៅ
# អត្រានុកូលដ្ឋាន
# កំណើត

**លេខរៀងបញ្ជី**----------------------- **ដល់លេខរៀងបញ្ជី**---------------------------

សន្លឹកដើមដំបូងបំផុត

**បានប្រគល់សៀវភៅអត្រានុកូលដ្ឋាននេះ**

**ឱ្យប្រើប្រាស់ចំនួន-------------------------------------------------សន្លឹក២**

**ថ្ងៃទី--------   ខែ------------------- ឆ្នាំ----------**

**អភិបាលក្រុង ស្រុក   ខណ្ឌ----------------**

## សន្លឹកទីមួយ

**ខេត្ត ក្រុង** ................................... **លេខ** ...... ០១............................

**ស្រុក ខណ្ឌ** .................................. **សៀវភៅកំណើតលេខ** .............

**ឃុំ សង្កាត់** .................................. **ឆ្នាំ** ............................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល | | | ភេទ | សញ្ជាតិ |
| នាមខ្លួនទារក | | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | កូនទី | មាន ឬឥតខាន់ស្លា |
| | នាមខ្លួនទារក | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃ ទី ខែ | ឆ្នាំ | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ..................................................<br>.................................................. | | |

| **ឪពុក ម្តាយទារក** | **ឪពុក** | | **ម្តាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន | | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង | | | | |
| សញ្ជាតិ | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ..............................<br>..............................<br>.............................. | | ..............................<br>..............................<br>.............................. | |
| មុខរបរពេលទារកកើត | | | | |
| ទីលំនៅពេលទារកកើត | | | | |
| លេខ អត្តសញ្ញាណប័ណ្ណ | | | | |

| | | | | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍ កំណើតទារក | | ភេទ | ឆ្នាំកំណើត | សញ្ជាតិ |
| ត្រូវជាអ្វីនឹងទារក | | | | |
| មុខរបរបច្ចុប្បន្ន | | | | |
| ទីលំនៅបច្ចុប្បន្ន | | | | |
| លេខអត្តសញ្ញាណប័ណ្ណ | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

ធ្វើនៅ...................... ថ្ងៃទី........... ខែ................... ឆ្នាំ...........

**ស្នាមមេដៃស្តាំអ្នករាយការណ៍** **មន្ត្រីអត្រានុកូលដ្ឋាន**

## សន្លឹកទី២

**ខេត្ត ក្រុង** .................................... **លេខ** ....... ០២..........................

**ស្រុក ខណ្ឌ** .................................. **សៀវភៅកំណើតលេខ** .............

**ឃុំ សង្កាត់** ................................... **ឆ្នាំ** ............................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល | | | ភេទ | សញ្ជាតិ |
| នាមខ្លួនទារក | | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | កូនទី | មាន ឬឥតខាន់ស្លា |
| | នាមខ្លួនទារក | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃ ទី ខែ ឆ្នាំ | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង<br>ប្រទេស | | ......................................................................................................................<br>...................................................................................................................... | | |

| **ឪពុក ម្តាយទារក** | **ឪពុក** | | **ម្តាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន | | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង | | | | |
| សញ្ជាតិ | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង<br>ប្រទេស | ...........................................................<br>...........................................................<br>........................................................... | | ...........................................................<br>...........................................................<br>........................................................... | |
| មុខរបរពេលទារកកើត | | | | |
| ទីលំនៅពេលទារកកើត | | | | |
| លេខ អត្តសញ្ញាណប័ណ្ណ | | | | |

| | | | | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍កំណើតទារក | | ភេទ | ឆ្នាំកំណើត | សញ្ជាតិ |
| ត្រូវជាអ្វីនឹងទារក | | | | |
| មុខរបរបច្ចុប្បន្ន | | | | |
| ទីលំនៅបច្ចុប្បន្ន | | | | |
| លេខអត្តសញ្ញាណប័ណ្ណ | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

ធ្វើនៅ...................... ថ្ងៃទី........... ខែ.................... ឆ្នាំ...........

**ស្នាមមេដៃស្តាំអ្នករាយការណ៍** **មន្ត្រីអត្រានុកូលដ្ឋាន**

**ខេត្ត ក្រុង** ....................................  **លេខ** ...... ០៣ ............................

**ស្រុក ខណ្ឌ** ..................................  **សៀវភៅកំណើតលេខ** .............

**ឃុំ សង្កាត់** ...................................  **ឆ្នាំ** .............................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល | | | ភេទ | សញ្ជាតិ |
| នាមខ្លួនទារក | | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | កូនទី | មាន ឬឥតខាន់ស្លា |
| | នាមខ្លួនទារក | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃ ទី | ខែ | ឆ្នាំ | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ..................................................<br>.................................................. | | | |

| **ឪពុក ម្ដាយទារក** | **ឪពុក** | | **ម្ដាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន | | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង | | | | |
| សញ្ជាតិ | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ...............................<br>...............................<br>............................... | | ...............................<br>...............................<br>............................... | |
| មុខរបរពេលទារកកើត | | | | |
| ទីលំនៅពេលទារកកើត | | | | |
| លេខ អត្តសញ្ញាណប័ណ្ណ | | | | |

| | | | | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍ កំណើតទារក | | ភេទ | ឆ្នាំកំណើត | សញ្ជាតិ |
| ត្រូវជាអ្វីនឹងទារក | | | | |
| មុខរបរបច្ចុប្បន្ន | | | | |
| ទីលំនៅបច្ចុប្បន្ន | | | | |
| លេខអត្តសញ្ញាណប័ណ្ណ | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

ធ្វើនៅ...................... ថ្ងៃទី........... ខែ..................... ឆ្នាំ...........

**ស្នាមមេដៃស្ដាំអ្នករាយការណ៍** **មន្ត្រីអត្រានុកូលដ្ឋាន**

## សន្លឹកទី៣

**ខេត្ត ក្រុង** .................................... **លេខ** ...... ០៤ ..........................

**ស្រុក ខណ្ឌ** .................................. **សៀវភៅកំណើតលេខ** .............

**ឃុំ សង្កាត់** .................................. **ឆ្នាំ** ............................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល | | | ភេទ | សញ្ជាតិ |
| នាមខ្លួនទារក | | | | |
| ជាអក្សរឡាតាំង | នាមត្រកូល | | កូនទី | មាន ឬឥតខាន់ស្លា |
| | នាមខ្លួនទារក | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃ ទី ខែ ឆ្នាំ | | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ............................................<br>............................................ | | | |

| **ឪពុក ម្ដាយទារក** | **ឪពុក** | | **ម្ដាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន | | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង | | | | |
| សញ្ជាតិ | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | | |
| ទីកន្លែងកំណើត ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ....................<br>....................<br>.................... | | ....................<br>....................<br>.................... | |
ថ្ងៃទី ........ ខែ ............. ឆ្នាំ២០...

**អភិបាលរាជធានី ខេត្ត**

បានឃើញ និងឯកភាព
ថ្ងៃទី ........ ខែ ............. ឆ្នាំ២០...

**នាយករដ្ឋបាល**

*ធ្វើនៅ......................., ថ្ងៃទី ....... ខែ ............. ឆ្នាំ២០ ...*

**ប្រធានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន**

សាលារាជធានី ខេត្ត ..........................

សាលាក្រុង ស្រុក ខណ្ឌ ..........................

លេខ : ........................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍

## ស្តីពីការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ

**ប្រចាំខែ ............ (ចាប់ពីថ្ងៃទី ........ ខែ ............. ដល់ថ្ងៃទី ........ ខែ ............. ឆ្នាំ២០....)**

| ល.រ | រាយមុខប្រភេទអត្រានុកូលដ្ឋាន | ឯកតា | ដើមគ្រា | បានទទួល | សរុប | ប្រើប្រាស់ | ខូចខាត | នៅសល់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ១ | សំបុត្រកំណើត (២ពណ៌) | សន្លឹក | | | | | | | |
| ២ | សេចក្តីចម្លងសំបុត្រកំណើត (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ៤ | សំបុត្របញ្ជាក់កំណើត (២ពណ៌) | សន្លឹក | | | | | | | |
| ៥ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ៦ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ៧ | សំបុត្រអាពាហ៍ពិពាហ៍ (២ពណ៌) | សន្លឹក | | | | | | | |
| ៨ | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | សន្លឹក | | | | | | | |
| ៩ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ១០ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ១១ | សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | សន្លឹក | | | | | | | |
| ១២ | សំបុត្រមរណភាព (២ពណ៌) | សន្លឹក | | | | | | | |
| ១៣ | សេចក្តីចម្លងសំបុត្រមរណភាព (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ១៤ | សេចក្តីចម្លងសំបុត្រមរណភាព (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ១៥ | សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព | សន្លឹក | | | | | | | |
| ១៦ | សៀវភៅកំណើត | ក្បាល | | | | | | | |
| ១៧ | សៀវភៅបញ្ជាក់កំណើត | ក្បាល | | | | | | | |
| ១៨ | សៀវភៅចម្លងកំណើត និង បញ្ជាក់កំណើត | ក្បាល | | | | | | | |
| ១៩ | សៀវភៅអាពាហ៍ពិពាហ៍ | ក្បាល | | | | | | | |
| ២០ | សៀវភៅចម្លងអាពាហ៍ពិពាហ៍ និង ប.អាពាហ៍ពិពាហ៍ | ក្បាល | | | | | | | |
| ២១ | សៀវភៅមរណភាព | ក្បាល | | | | | | | |
| ២២ | សៀវភៅចម្លងមរណភាព និង ប.មរណភាព | ក្បាល | | | | | | | |

***សំគាល់ :*** *របាយការណ៍នេះត្រូវផ្ញើមកសាលារាជធានី ខេត្ត នៅរៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ និងភ្ជាប់មកជាមួយនូវរបាយការណ៍ផតចម្លងរបស់ឃុំ សង្កាត់*

បានឃើញ និងឯកភាព
ថ្ងៃទី ........ ខែ ............ ឆ្នាំ២០...

**អភិបាលក្រុង ស្រុក ខណ្ឌ**

បានឃើញ និងឯកភាព
ថ្ងៃទី ........ ខែ ............ ឆ្នាំ២០...

**នាយករដ្ឋបាល**

*ធ្វើនៅ......................., ថ្ងៃទី ...... ខែ ............ ឆ្នាំ២០ ...*

**មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**

សាលារាជធានី ខេត្ត ........................ **ព្រះរាជាណាចក្រកម្ពុជា**

សាលាក្រុង ស្រុក ខណ្ឌ ...................... **ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឃុំ សង្កាត់ .................................

លេខ : ........................

# របាយការណ៍

## ស្តីពីការប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ

ប្រចាំខែ ............ (ចាប់ពីថ្ងៃទី ........ ខែ ............. ដល់ថ្ងៃទី ........ ខែ ............. ឆ្នាំ២០....)

| ល.រ | វាយមុខប្រភេទអត្រានុកូលដ្ឋាន | ឯកត្តា | ដើមគ្រា | បានទទួល | សរុប | ប្រើប្រាស់ | ខូចខាត | នៅសល់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| ១ | សំបុត្រកំណើត (២ពណ៌) | សន្លឹក | | | | | | | |
| ២ | សេចក្តីចម្លងសំបុត្រកំណើត (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ៤ | សំបុត្របញ្ជាក់កំណើត (២ពណ៌) | សន្លឹក | | | | | | | |
| ៥ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ៦ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ៧ | សំបុត្រអាពាហ៍ពិពាហ៍ (២ពណ៌) | សន្លឹក | | | | | | | |
| ៨ | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | សន្លឹក | | | | | | | |
| ៩ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ១០ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ១១ | សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | សន្លឹក | | | | | | | |
| ១២ | សំបុត្រមរណភាព (២ពណ៌) | សន្លឹក | | | | | | | |
| ១៣ | សេចក្តីចម្លងសំបុត្រមរណភាព (ក្នុងឆ្នាំ) | សន្លឹក | | | | | | | |
| ១៤ | សេចក្តីចម្លងសំបុត្រមរណភាព (ឆ្លងឆ្នាំ) | សន្លឹក | | | | | | | |
| ១៥ | សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព | សន្លឹក | | | | | | | |
| ១៦ | សៀវភៅកំណើត | ក្បាល | | | | | | | |
| ១៧ | សៀវភៅបញ្ជាក់កំណើត | ក្បាល | | | | | | | |
| ១៨ | សៀវភៅចម្លងកំណើត និង បញ្ជាក់កំណើត | ក្បាល | | | | | | | |
| ១៩ | សៀវភៅអាពាហ៍ពិពាហ៍ | ក្បាល | | | | | | | |
| ២០ | សៀវភៅចម្លងអាពាហ៍ពិពាហ៍ | ក្បាល | | | | | | | |
| ២១ | សៀវភៅមរណភាព | ក្បាល | | | | | | | |
| ២២ | សៀវភៅចម្លងមរណភាព | ក្បាល | | | | | | | |

***សំគាល់*** : *របាយការណ៍នេះត្រូវផ្ញើមកសាលាក្រុង ស្រុក ខណ្ឌ នៅរៀងរាល់ថ្ងៃទី ០៥ នៃខែបន្ទាប់*

បានឃើញ និងឯកភាព
ថ្ងៃទី ........ ខែ ............ ឆ្នាំ២០...
**មេឃុំ ចៅសង្កាត់**

*ធ្វើនៅ......................., ថ្ងៃទី ....... ខែ ............ ឆ្នាំ២០ ...*
**ស្មៀន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ក្រុង --------------------

ស្រុក ខណ្ឌ --------------------

ឃុំ សង្កាត់ --------------------

លេខ ---------------

រូបថត ថតថ្មី

៤ x ៦

ថ្ងៃទី......... ខែ.................... ឆ្នាំ.........

# លិខិតបញ្ជាក់

## ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ

យោងពាក្យសុំបញ្ជាក់ភាព............ ចុះថ្ងៃទី......... ខែ............... ឆ្នាំ............ របស់..................................... ។

**យើងមេឃុំ ចៅសង្កាត់**.............................

សូមបញ្ជាក់ថា ឈ្មោះ.................................. ភេទ.......... កើតនៅថ្ងៃ............. ទី.......... ខែ................... ឆ្នាំ.............. នៅភូមិ........................... ឃុំ ឬ សង្កាត់............................ ស្រុក ឬ ខណ្ឌ............................ ខេត្ត ឬ ក្រុង...................................... មុខរបរបច្ចុប្បន្ន................................................ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ.............. ផ្លូវលេខ.............. ក្រុម......... ភូមិ......................... ឃុំ ឬ សង្កាត់.............................. ស្រុក ឬ ខណ្ឌ................................ ខេត្ត ឬ ក្រុង................................... មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន ពិតជា........................ប្រាកដមែន ។

លិខិតបញ្ជាក់នេះ ចេញអោយសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ក្នុងការសុំរៀបអាពាហ៍ពិពាហ៍ ។

( លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល ៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ)

**មេឃុំ ចៅសង្កាត់**

certificate-CR

# ជំពូកទី២

# អត្រានុកូលដ្ឋានកំណើត

# ជំពូកទី២
# អត្រានុកូលដ្ឋានកំណើត

## ២.១. សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត

### ២.១.១. សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត

សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត រួមមាន ៖

- សៀវភៅអត្រានុកូលដ្ឋានកំណើត (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
- សៀវភៅអត្រានុកូលដ្ឋានកំណើតសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត

ចំពោះសៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត មិនចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ។

### ២.១.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត រួមមាន ៖

- សំបុត្រកំណើត
- សំបុត្របញ្ជាក់កំណើត
- សេចក្តីចម្លងសំបុត្រកំណើត (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ)
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ)

## ២.២. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើត

☞ បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស៣០ថ្ងៃ។ ករណីឪពុក ម្តាយមានធុរៈចាំបាច់ពុំអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតបាន អាចពឹងពាក់ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្តាយ ឱ្យទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត។ ការដាក់ឈ្មោះ គឺត្រូវមានការបញ្ជាក់ជាលាយល័ក្ខណ៍អក្សរពីឪពុកម្តាយទារកនោះ និងត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុកម្តាយទារក ឬឯកសារភស្តុតាងផ្សេងៗ ដែលមានបញ្ជាក់ភាពជាប្តីប្រពន្ធទៅជាមួយផង (ប្រសិនបើមាន)។ ទារកដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងរយៈពេលកំណត់ ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋាននឹងផ្តល់នូវសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ដោយឥតគិតថ្លៃ។

☞ ប្រជាពលរដ្ឋខ្មែរដែលបានកើតហើយទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីចំនួន ០២រូប ជានីតិជន

ហើយត្រូវមានទីលំនៅពិតប្រាកដមកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។ ពាក្យប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតរបស់សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ចំនួន០១ច្បាប់ ត្រូវបង់ថ្លៃ ១.០០០ រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅនៅក្នុងខេត្តរតនគីរី ឧត្តរមានជ័យ មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ និងបង់ថ្លៃ ៤.០០០រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ ។

☞ បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើកំណត់ហេតុ និងចុះសៀវភៅអត្រានុកូលដ្ឋានកំណើតដោយរកឈ្មោះដាក់ឱ្យទារកនោះ ។ ក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំកំណើតទារកដែលរើសបាននោះដោយស្មាន និងឈ្មោះឪពុកម្តាយដាក់ថាមិនស្គាល់ ។

☞ រាល់ការសុំកូនយកទៅចិញ្ចឹម ទាំងការសុំកូនធម្មតា និងសុំកូនពេញលេញ ត្រូវមានការសម្រេចពីតុលាការ

☞ បើជនណាសុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ហើយត្រូវយកអ្នកសុំនោះធ្វើជាឪពុកម្តាយ ហើយមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត ។

☞ ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើសបាននោះទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និងធ្វើកំណត់ហេតុស្តីពីការប្រគល់ទារកជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ។

☞ ចំពោះទារក ឬកុមារដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយពុំទាន់មានសំបុត្រកំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះ ត្រូវធ្វើសេចក្តីរាយការណ៍ និងនាំទារក ឬកុមារនោះទៅបង្ហាញផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីផ្តល់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឱ្យ ។ ចំពោះការដាក់ឈ្មោះឱ្យទារក ឬកុមារកំព្រាទាំងនោះ អាស្រ័យទៅលើអ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌល និងមន្ត្រីអត្រានុកូលដ្ឋានឯកភាពដាក់ឱ្យ ។

☞ ការសុំទារក ឬកុមារដែលកំពុងចិញ្ចឹមបីបាច់ថែរក្សាក្នុងមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬកូនដែលកំពុងចិញ្ចឹមដោយឪពុក ម្តាយរបស់ខ្លួនធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុវត្តផ្អែកតាមក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ។

☞ ពេលមានពិរុទ្ធជន ឬទណ្ឌិតណាម្នាក់បានសម្រាលកូនក្នុងមណ្ឌលអប់រំកែប្រែ ពេលនោះអ្នកទទួលខុសត្រូវនៃមណ្ឌលអប់រំកែប្រែត្រូវធ្វើកំណត់ហេតុអំពីទារកកើតឱ្យបានត្រឹមត្រូវ ។ ចំពោះទីកន្លែងកំណើតទារក ត្រូវសរសេរទីកន្លែងនៃលំនៅរបស់ឪពុក ឬរបស់ម្តាយទារកមុនពេលក្លាយជាទណ្ឌិត ។

- បើទារកនោះមានឪពុកត្រឹមត្រូវនៅរស់ អ្នកទទួលខុសត្រូវនៃពន្ធនាគារត្រូវប្រគល់កំណត់ហេតុនោះឱ្យឪពុកទារកយកទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅឃុំ ឬសង្កាត់ ដែលខ្លួនកំពុងរស់នៅជាប់លាប់ឱ្យទាន់ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីទារកនោះកើត ។

- ក្នុងករណីទារកពុំមានឪពុកច្បាស់លាស់ទេ អ្នកទទួលខុសត្រូវនៃពន្ធនាគារ ត្រូវបញ្ជូនកំណត់ហេតុទារកកើតទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅដែលម្ដាយទារកនោះរស់នៅជាប់លាប់ មុនពេលក្លាយជាទណ្ឌិត ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ។

☞ ទារកកើតពីឪពុក ម្ដាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតដែរ ។ នៅពេលធ្វើសំបុត្រកំណើត ប្រសិនបើឪពុក និងម្ដាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបានឆ្លើយទទួលស្គាល់ដោយជាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក និងម្ដាយនោះជាឪពុក ម្ដាយរបស់កូននោះ ។

- ក្នុងករណីមានតែឪពុក ឬមានតែម្ដាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។
- ក្រោយពេលឪពុក ឬម្ដាយបានប្ដឹងចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬម្ដាយណាដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬម្ដាយនោះអាចប្ដឹងសុំទទួលស្គាល់កូនជាក្រោយបាន ។
- កូនឥតខាន់ស្លាដែលឪពុក ម្ដាយបានទទួលស្គាល់ នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុកម្ដាយរបស់កូននោះបានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។
- ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នានឹងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

### ២.២.១. លិខិតស្នាមនានាដែលទាក់ទងនឹងការចុះអត្រានុកូលដ្ឋានកំណើត

#### លិខិតស្នាមនានាដែលទាក់ទងនឹងទារកទើបកើត

☞ អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសុំសំបុត្រកំណើត ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ៖

- លិខិតបញ្ជាក់ទទួលស្គាល់កំណើត ៖
  - លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងទារកកើត បើទារកកើតនៅមន្ទីរពេទ្យ ឬ
  - លិខិតបញ្ជាក់ទទួលស្គាល់កំណើតរបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
  - កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬលិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ
- លិខិតបញ្ជាក់របស់ឪពុកម្ដាយទារកអំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក បើឪពុកម្ដាយទារកពឹងពាក់ញាតិជានីតិជនដែលរស់នៅជាមួយឪពុក ម្ដាយ ឱ្យទៅរាយការណ៍ជំនួស ។
- សៀវភៅគ្រួសារដែលមានឈ្មោះឪពុក ម្ដាយទារក (ប្រសិនបើមាន) ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឪពុក ម្ដាយទារក (ប្រសិនបើមាន) ។
- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតរបស់ឪពុកម្ដាយទារក ។ សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុកម្ដាយទារក (ប្រសិនបើមាន) ។

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកនូវលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតទារក ក្នុងសំណុំឯកសារកំណើត នៅឃុំ ឬសង្កាត់ ៖

- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់របស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬលិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ
- លិខិតរបស់ឪពុក ម្តាយទារកបញ្ជាក់ពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក (ករណីឪពុកម្តាយ ពឹងពាក់ញាតិជានីតិជនដែលរស់នៅជាមួយឪពុក ម្តាយ ឱ្យទៅរាយការណ៍ជំនួស) ។

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់លិខិតស្នាមឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតដែលត្រូវរក្សាទុក ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ៖---------------
ក្រុង ស្រុក ខណ្ឌ ៖---------------
ឃុំ សង្កាត់ ៖----------------
ភូមិ ៖----------------

ថ្ងៃទី------ ខែ---------- ឆ្នាំ-------

## លិខិតបញ្ជាក់ទទួលស្គាល់កំណើត

យើង-------------------- ជាមេភូមិ-------------------- នៃឃុំ សង្កាត់-------------------- ក្រុង ស្រុក ខណ្ឌ--------------- រាជធានី ខេត្ត ------------ សូមបញ្ជាក់ថា (នាមត្រកូល-នាមខ្លួនទារក)---------------------- ភេទ----- កើតនៅថ្ងៃទី----- ខែ--------- ឆ្នាំ------ នៅផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុមទី------- ភូមិ-------- ឃុំ សង្កាត់------------ ក្រុង ស្រុក ខណ្ឌ------------ រាជធានី ខេត្ត ------------- ឪពុកឈ្មោះ--------------------- កើតនៅថ្ងៃទី----- ខែ--------- ឆ្នាំ------ ម្ដាយឈ្មោះ----------------- កើតនៅថ្ងៃទី------ ខែ---------ឆ្នាំ--------- មានទីលំនៅបច្ចុប្បន្ននៅភូមិ---------------- ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ---------------------- រាជធានី ខេត្ត ------------- ពិតជាបានកើតនៅផ្ទះ ប្រាកដមែន ដែលមានឆ្មបបង្កើតឈ្មោះ------------------------ ភេទ------- ឆ្នាំកំណើត--------- មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ---------- ផ្លូវលេខ ---------- ក្រុមទី ---------- ភូមិ------------------ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ---------។

“លិខិតបញ្ជាក់ទទួលស្គាល់កំណើតនេះ ចេញឱ្យប្រើប្រាស់សម្រាប់ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត”

**មេភូមិ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យប្តឹងសុំសំបុត្រអត្រានុកូលដ្ឋានកំណើត

ខ្ញុំបាទ នាងខ្ញុំឈ្មោះ------------------------------------- សញ្ជាតិ---------- ឆ្នាំកំណើត----------- មុខរបរបច្ចុប្បន្ន------------------------------------------------------------------------------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ--------- ក្រុមទី---------- ភូមិ------------ឃុំ សង្កាត់---------------- ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ------------------ ។

**គោរពជូន**
**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់---------------------**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឱ្យឈ្មោះ------------------- ។

**<u>យោង</u>** ៖ លិខិត------------------------------------- លេខ----------- ចុះថ្ងៃទី------ ខែ---------
ឆ្នាំ--------- របស់------------------------------------------------------------------- ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមជម្រាបជូន លោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋាន មេត្តាជ្រាបថា ឈ្មោះ-------------------------- ត្រូវជា------------------------- ពុំទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅឡើយ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋានមេត្តាចុះសៀវភៅអត្រានុកូលដ្ឋានកំណើត តាមសំណើខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី------- ខែ----------- ឆ្នាំ--------

**ស្នាមមេដៃស្តាំអ្នកប្តឹង**

<u>សូមជូនភ្ជាប់មកជាមួយនូវ</u> ៖

- --------------------------
- --------------------------

### ២.២.២. ការសរសេរចុះបញ្ជីកំណើត

#### ក). សម្រាប់ទារកដែលកើតពីឪពុកម្ដាយជាពលរដ្ឋខ្មែរ

☞ នៅពេលមានអ្នកមករាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសុំសំបុត្រកំណើត និងបន្ទាប់ពីបានពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីកំណើតចំនួន០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតភ្លោះ ។

☞ របៀបសរសេរចុះបញ្ជីកំណើត នៃសៀវភៅអត្រានុកូលដ្ឋានកំណើតដែលបានចុះលេខ និងចុះឆ្នាំរួចហើយ មានដូចខាងក្រោម ៖

១). រាជធានី ខេត្ត ៖ ត្រូវសរសេរឈ្មោះរាជធានី ឬឈ្មោះខេត្តសាមី ។ បើខេត្តត្រូវឆូតចោលពាក្យ “ក្រុង” បើរាជធានី ត្រូវឆូត ចោលពាក្យ“ខេត្ត-ក្រុង” និងសរសេរពាក្យ “រាជធានី” បំពេញបន្ថែម ។

២). ក្រុង ស្រុក ខណ្ឌ ៖ ត្រូវសរសេរឈ្មោះក្រុង ឬឈ្មោះស្រុក ឬឈ្មោះខណ្ឌសាមី ។ បើស្រុក ត្រូវឆូតចោលពាក្យ “ខណ្ឌ” បើខណ្ឌ ត្រូវឆូតចោលពាក្យ “ស្រុក” បើក្រុង ត្រូវឆូតចោលពាក្យ “ស្រុក-ខណ្ឌ” និងសរសេរពាក្យ“ក្រុង” បំពេញបន្ថែម ។

៣). ឃុំ សង្កាត់ ៖ ត្រូវសរសេរឈ្មោះឃុំ ឬឈ្មោះសង្កាត់សាមី ។ បើឃុំត្រូវឆូតចោលពាក្យ “សង្កាត់” បើសង្កាត់ត្រូវឆូតចោលពាក្យ “ឃុំ” ។

៤). លេខ ៖ ត្រូវសរសេរលេខរៀងបញ្ជីកំណើត ។ លេខរៀងបញ្ជីកំណើតត្រូវសរសេរពីរខ្ទង់ឡើងទៅ ចាប់ផ្ដើមពីលេខ ០១ដោយសរសេរជាលេខខ្មែរ ។

៥). សៀវភៅកំណើតលេខ ៖ ត្រូវសរសេរលេខសៀវភៅដូចលេខដែលនៅក្របមុខ នៃសៀវភៅកំណើតដែលកំពុងសរសេរ ។ ឧទាហរណ៍ ៖ ០១/២០១២

៦). ឆ្នាំ ៖ ត្រូវសរសេរឆ្នាំដូចឆ្នាំដែលចុះនៅក្របមុខនៃសៀវភៅកំណើតដែលកំពុងសរសេរ ។

៧). នាមត្រកូល ៖ ត្រូវសរសេរនាមត្រកូលរបស់ទារក អាចយកត្រកូលតាមដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬអាចយកឈ្មោះជីតាខាងឪពុក ឬអាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។ ចំពោះកូនដែលមិនស្គាល់ឪពុក ម្ដាយ (ដូចជាកូនដែលគេបោះបង់ចោល និងកូនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា) នៅខ្ទង់ “នាមត្រកូល” ត្រូវទុកចំហចោល (មិនចាំបាច់សរសេរអ្វីទាំងអស់) ។ នេះមានន័យថា កូននេះពុំមាននាមត្រកូលទេ មានតែនាមខ្លួនប៉ុណ្ណោះ ។

៨). នាមខ្លួនទារក៖ ត្រូវសរសេរឈ្មោះទារកដែលទើបកើត ដោយឪពុកម្ដាយទារកជាអ្នកដាក់ឱ្យ ។ ករណីឪពុកម្ដាយមានធុរៈចាំបាច់ ពុំអាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតបាន អាចពឹងពាក់ញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្ដាយ ឱ្យទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ការដាក់ឈ្មោះ គឺត្រូវមានការបញ្ជាក់ជាលាយល័ក្ខណ៍អក្សរពីឪពុកម្ដាយទារកនោះ និងត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុកម្ដាយទារក ឬឯកសារភស្តុតាងផ្សេងៗដែលមានបញ្ជាក់ភាពជាប្ដីប្រពន្ធទៅជាមួយផង (ប្រសិនបើមាន) ។

៩). ភេទ ៖ ត្រូវសរសេរផ្អែកទៅតាមភេទនៃទារក បើប្រុស សរសេរថា “ប្រុស” បើស្រី សរសេរថា “ស្រី” ។ ករណីទារកពុំមានភេទពិតប្រាកដ ត្រូវកំណត់យកភេទណាមួយដែលសមស្របជាង បើលំនាំប្រុសដាក់ភេទ “ប្រុស” បើលំនាំស្រីដាក់ភេទ “ស្រី” ។

១០). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់ទារក ដោយផ្អែកទៅតាមសញ្ជាតិនៃឪពុកម្ដាយ និងផ្អែកតាមច្បាប់ស្ដីពីសញ្ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

- សៀវភៅអត្រានុកូលដ្ឋានកំណើតសម្រាប់ពលរដ្ឋខ្មែរ ឬសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត ត្រង់ខ្ទង់ “សញ្ជាតិ” ត្រូវតែសរសេរថា “ខ្មែរ” ជាដាច់ខាត ។
- ទារកកើតពីឪពុក ឬ ម្ដាយដែលមានសញ្ជាតិខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរដោយស្វ័យប្រវត្តិ ។ (សូមអានចំណុច ១.១.៣-គ ទំព័រទី៣) ។

១១). ជាអក្សរឡាតាំង ៖ ត្រូវឱ្យឪពុក ឬម្ដាយ ឬអ្នកមករាយការណ៍បញ្ជាក់ប្រាប់អំពីអក្សរឡាតាំង ។ ក្នុងករណីឪពុក ឬម្ដាយ ឬអ្នកមករាយការណ៍ មិនចេះអក្សរឡាតាំង ហើយមន្ត្រីអត្រានុកូលដ្ឋានចេះប្រាកដអាចបំពេញជូនបាន ដោយយកតាមសំឡេងខ្មែរ ។ ក្នុងករណីពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកចោលឱ្យនៅទំនេរ ពុំចាំបាច់សរសេរក៏បាន ។

- នាមត្រកូល ៖ ត្រូវសរសេរជាអក្សរឡាតាំងប្រកបឱ្យត្រូវសម្លេងតាមអក្សរខ្មែរ ។
- នាមខ្លួន ៖ ត្រូវសរសេរជាអក្សរឡាតាំងប្រកបឱ្យត្រូវសម្លេងតាមអក្សរខ្មែរ ។

១២). កូនទី ៖ ត្រូវសរសេរជាអក្សរ បើទារកទើបកើតជាកូនដំបូង ត្រូវសរសេរ “មួយ” បើទារកកើតជាកូនទីពីរ ត្រូវសរសេរ “ពីរ” ។

**ឧទាហរណ៍÷** បុរសពោះម៉ាយ ឈ្មោះ **ស** មានកូនមួយនាក់ រៀបការជាមួយនារីមេម៉ាយ ឈ្មោះ **ក** មានកូនមួយនាក់ដែរ ដូច្នេះកូនដំបូង ដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍លើកក្រោយរបស់នារី ឈ្មោះ **ក** និង បុរសឈ្មោះ **ស** នោះ ជាកូនទីមួយ (មិនមែនកូនទីបីទេ) ។

១៣). មាន ឬឥតខាន់ស្លា ៖ នៅពេលមកសុំចុះសំបុត្រកំណើតនេះ បើឪពុក ម្ដាយទារកមានសំបុត្រអាពាហ៍-ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬឯកសារភស្ដុតាងផ្សេងៗដែលមានបញ្ជាក់ភាពជាប្ដីប្រពន្ធ (ដូចជាសៀវភៅគ្រួសារ ប័ណ្ណកម្មសិទ្ធិអចលនវត្ថុជាដើម) ត្រូវដាក់ថា “មានខាន់ស្លា” បើឪពុកម្ដាយទារកពុំមានឯកសារភស្ដុតាងបញ្ជាក់ថា បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ ត្រូវដាក់ថា “ឥតខាន់ស្លា” ។

១៤). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំទារកកើត ដោយសរសេរថ្ងៃជាអក្សរខ្មែរ ទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ និង ឆ្នាំជាលេខខ្មែរតាមគ្រិស្តសករាជ ។

**ឧទាហរណ៍** ÷ ថ្ងៃអង្គារ ទី០១ ខែមករា ឆ្នាំ២០១២ ។

១៥). ទីកន្លែងកំណើត ៖ ត្រូវសរសេរអាសយដ្ឋាននៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលឪពុក ម្ដាយទារកនោះរស់នៅ ដោយសរសេរ ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ឈ្មោះប្រទេស ឬអាចយកទីកន្លែងដែលទារកនោះកើតពិតប្រាកដក៏បាន ។

**ឪពុក ម្តាយទារក ចែកចេញជាពីរផ្នែក ÷ ផ្នែកឪពុក និងផ្នែកម្តាយ**

១៦). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនឪពុកពីក្រោមផ្នែកឪពុក និងសរសេរនាមត្រកូល និងនាមខ្លួនម្តាយពីក្រោមផ្នែកម្តាយ ។

- ចំពោះកូនដែលមិនស្គាល់ឪពុក ម្តាយ (ដូចជាកូនដែលគេបោះបង់ចោល និងកុមារដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា) នៅផ្នែកឪពុក ត្រង់ខ្ទង់ "នាមត្រកូល និងនាមខ្លួន" ត្រូវសរសេរថា "មិនស្គាល់" នៅផ្នែកម្តាយ ត្រង់ខ្ទង់ "នាមត្រកូល និងនាមខ្លួន" ក៏ត្រូវ សរសេរថា "មិនស្គាល់" ដែរ ។
- ចំពោះកូនដែលឪពុកមិនទទួលស្គាល់ នៅផ្នែកឪពុក ត្រូវទុកចំហចោល (មិនចាំបាច់សរសេរអ្វីទាំងអស់)
- ចំពោះកូនដែលម្តាយមិនទទួលស្គាល់ នៅផ្នែកម្តាយ ត្រូវទុកចំហចោល (មិនចាំបាច់សរសេរអ្វីទាំងអស់)

១៧). រស់ ឬស្លាប់៖ បើឪពុក ឬម្តាយនៅរស់ ត្រូវឆូតចោលពាក្យ "ស្លាប់" បើស្លាប់ត្រូវឆូតចោលពាក្យ "រស់" ។

១៨). នាមត្រកូល និងនាមខ្លួនជាអក្សរឡាតាំង ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនឪពុកជាអក្សរឡាតាំង នៅពីក្រោមផ្នែកឪពុក និងសរសេរនាមត្រកូល និងនាមខ្លួនម្តាយ ជាអក្សរឡាតាំងនៅពីក្រោមផ្នែក ម្តាយ ប្រកបឱ្យត្រូវសម្លេងតាមអក្សរខ្មែរ ។ ក្នុងករណីពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកចោលឱ្យនៅទំនេរពុំចាំបាច់សរសេរក៏បាន ។

១៩). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់ឪពុក ចូលពីក្រោមផ្នែកឪពុក និងសរសេរសញ្ជាតិរបស់ម្តាយ ចូលពីក្រោមផ្នែកម្តាយ ។

២០). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកពីក្រោមផ្នែកឪពុក និងសរសេរ ថ្ងៃ ខែ ឆ្នាំកំណើតរបស់ម្តាយពីក្រោមផ្នែកម្តាយ ដោយសរសេរ ថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរ និងឆ្នាំជាលេខខ្មែរ ។ **ឧទាហរណ៍ ÷** ថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៧០ ។ ក្នុងករណីឪពុក ឬម្តាយ ពុំចាំថ្ងៃ ខែ ឆ្នាំកំណើតរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះជាមួយឪពុក ម្តាយ ឬអ្នកមករាយការណ៍នោះ ដើម្បីប៉ាន់ស្មានឆ្នាំកំណើត ឬបើមិនអាចដាក់ឆ្នាំកំណើតបាន អាចដាក់អាយុដោយប៉ាន់ស្មានបាន ។

២១). ទីកន្លែងកំណើត ៖ ត្រូវសរសេរឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និងប្រទេស ដែលជាកន្លែងកំណើតរបស់ឪពុក ចូលពីក្រោមផ្នែកឪពុក និងរបស់ម្តាយចូលពីក្រោមផ្នែកម្តាយ ។

២២). មុខរបរពេលទារកកើត ៖ ត្រូវសរសេរមុខរបររបស់ឪពុក និងមុខរបររបស់ម្តាយនៅពេលទារកកើត ចូលពីក្រោមផ្នែកឪពុក និងចូលពីក្រោមផ្នែកម្តាយ ។

២៣). ទីលំនៅពេលទារកកើត ៖ ត្រូវសរសេរទីលំនៅរបស់ឪពុក និង ទីលំនៅរបស់ម្តាយនៅពេល ទារកកើត មានលេខផ្ទះ លេខផ្លូវ (ប្រសិនបើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស ចូលផ្នែកឪពុក និងចូលផ្នែកម្តាយ ។

២៤). លេខអត្តសញ្ញាណប័ណ្ណ ៖ ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឪពុក ចូលក្រោមផ្នែកឪពុក និងរបស់ម្តាយ ចូលពីក្រោមផ្នែកម្តាយ ។ ករណីគ្មានអត្តសញ្ញាណប័ណ្ណត្រូវទុកខ្ទង់នេះឱ្យនៅទំនេរ ។ ពេលមានអត្តសញ្ញាណប័ណ្ណសាមីខ្លួន អាចមកស្នើសុំចុះជាក្រោយក៏បាន ។

**អ្នករាយការណ៍កំណើតទារក**

២៥). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនអ្នកដែលបានមករាយការណ៍កំណើតទារកចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

២៦). ភេទ ៖ ត្រូវសរសេរអំពីភេទនៃអ្នករាយការណ៍កំណើតទារក បើជាប្រុស សរសេរដាក់ថា "ប្រុស" បើជាស្រី សរសេរដាក់ថា "ស្រី" ។

២៧). ឆ្នាំកំណើត ៖ ត្រូវសរសេរឆ្នាំកំណើតនៃអ្នករាយការណ៍កំណើតទារកជាលេខខ្មែរ។

២៨). សញ្ជាតិ ៖ ត្រូវសរសេរអំពីសញ្ជាតិនៃអ្នករាយការណ៍កំណើតទារក។

២៩). ត្រូវជាអ្វីនឹងទារក ៖ ត្រូវសរសេរអំពីការពាក់ព័ន្ធរវាងទារក និងអ្នកមករាយការណ៍។ អ្នករាយការណ៍អាចជាឪពុក ម្ដាយ ឬជាញាតិជានីតិជនដែលរស់នៅជាមួយឪពុក ម្ដាយទារក។

**ឧទាហរណ៍** ÷ បើឪពុកទារកមករាយការណ៍ ត្រូវសរសេរ "ឪពុក" បើមីងបង្កើតមករាយការណ៍ ត្រូវសរសេរ "មីងបង្កើត" ។

៣០). មុខរបរបច្ចុប្បន្ន ៖ ត្រូវសរសេរអំពីមុខរបររបស់អ្នករាយការណ៍ពេលទារកកើត។

៣១). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរអំពីទីលំនៅរបស់អ្នករាយការណ៍ ពេលទារកកើតដូចជា អំពីលេខផ្ទះ លេខផ្លូវ (បើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស ចូលផ្នែកអ្នករាយការណ៍។

៣២). លេខអត្តសញ្ញាណប័ណ្ណ ៖ ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នករាយការណ៍កំណើតទារក (ប្រសិនបើមាន) បើគ្មានអត្តសញ្ញាណប័ណ្ណខ្ទង់នេះត្រូវទុកឱ្យនៅទំនេរ។ ពេលមានអត្តសញ្ញាណប័ណ្ណ សាមីខ្លួនអាចមកស្នើសុំចុះជាក្រោយក៏បាន។

**បញ្ជាក់** ÷ ពេលសរសេរបំពេញក្នុងខ្ទង់ទាំងអស់ខាងលើនេះចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នកមករាយការណ៍កំណើតទារកពិនិត្យ ។ ក្នុងករណីអ្នកមករាយការណ៍កំណើតទារកមិនចេះអក្សរ មន្ត្រីអត្រានុកូលដ្ឋានត្រូវអានឱ្យអ្នកមករាយការណ៍កំណើតទារកស្ដាប់គ្រប់ចំណុចទាំងអស់ បើឃើញថាត្រឹមត្រូវ និងឯកភាពហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវបន្តដូចខាងក្រោម ៖

៣៣). ស្នាមមេដៃស្ដាំអ្នករាយការណ៍ ៖ ត្រូវផ្ដិតមេដៃស្ដាំដោយទឹកល័ក្ខពណ៌ក្រហមឱ្យឃើញក្រយៅដៃរបស់អ្នករាយការណ៍កំណើត ទារកឱ្យបានច្បាស់លាស់ និងសរសេរឈ្មោះនៅពីក្រោមស្នាមមេដៃដើម្បីទុកជាភស្ដុតាង។ ករណីកូនឥតខាន់ស្លា បើឪពុក និងម្ដាយទទួលស្គាល់ ត្រូវផ្ដិតស្នាមមេដៃទាំងពីរនាក់ បើសិនឪពុក ឬម្ដាយទទួលស្គាល់តែម្ខាង ត្រូវផ្ដិតស្នាមមេដៃតែឪពុក ឬម្ដាយដែលទទួលស្គាល់តែប៉ុណ្ណោះ ។

៣៤). ធ្វើនៅ--- ថ្ងៃទី--- ខែ--- ឆ្នាំ---៖ ត្រូវសរសេរឈ្មោះនៃឃុំ ឬសង្កាត់ទីកន្លែងដែលធ្វើអត្រានុកូលដ្ឋាន និងចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរតាមសុរិយគតិ និងឆ្នាំជាលេខខ្មែរតាមឆ្នាំគ្រិស្តសករាជ។

៣៥). មន្ត្រីអត្រានុកូលដ្ឋាន ៖ ត្រូវសរសេរពីក្រោមថា មេឃុំ ឬចៅសង្កាត់។ បើមេឃុំ ឬចៅសង្កាត់អវត្តមានជំទប់ ចៅសង្កាត់រងនឹងទទួលសិទ្ធិតាមឋានានុក្រម តាមរយៈលិខិតប្រគល់សិទ្ធិជាលាយល័ក្ខណ៍អក្សរពី

មេឃុំ ចៅសង្កាត់។ ក្នុងករណីនេះ ត្រូវសរសេរពីក្រោមពាក្យ “មន្ត្រីអត្រានុកូលដ្ឋាន” ដាក់ថា “មេឃុំស្តីទី” ឬ “ចៅសង្កាត់ស្តីទី”។

៣៦). ហត្ថលេខា និងត្រា ៖ មេឃុំ ឬចៅសង្កាត់ ឬអ្នកជំនួសជាជំទប់ ឬចៅសង្កាត់រង ត្រូវចុះហត្ថលេខាអ្នកនោះ រួចហើយសរសេរឈ្មោះ ឬបោះត្រាឈ្មោះអ្នកចុះហត្ថលេខា និងបោះត្រាសាលាឃុំ ឬសង្កាត់ពីលើផ្នែកខាងឆ្វេងមួយភាគបីនៃហត្ថលេខា និងបោះត្រាឱ្យត្រង់ជួរអក្សរ (ត្រាប្រើទឹកពណ៌ក្រហម)។

**ឧទាហរណ៍ ២.១ ÷** ការសរសេរចុះបញ្ជីកំណើតដែលមានលេខរៀងបញ្ជី២៥ តាមខ្លឹមសារខាងក្រោម ៖

លោក សម សោភ័ណ ជាគ្រូបង្រៀនសាលាបឋមសិក្សាក្នុងឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានមករាយការណ៍នាថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ជូនមន្ត្រីអត្រានុកូលដ្ឋានឃុំគោកត្រប់ សុំចុះសៀវភៅអត្រានុ-កូលដ្ឋានកំណើតឱ្យកូន ពីព្រោះភរិយារបស់គាត់បានសម្រាលកូនប្រុសមួយដំបូង នៅថ្ងៃច័ន្ទ ទី០៥ ខែមករា ឆ្នាំ ២០១២ នៅមន្ទីរពេទ្យស្រុកកណ្តាលស្ទឹង ដោយមានសំបុត្រពេទ្យ និងសំបុត្រអាពាហ៍ពិពាហ៍បង្ហាញផង។

លោក សម សោភ័ណ សញ្ជាតិខ្មែរ កើតថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥ នៅភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល បានរៀបអាពាហ៍ពិពាហ៍ជាមួយនាង គុណ រតនា សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០ នៅភូមិពោធិ៍ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ មានមុខរបរជាជាងកាត់ដេរ។

លោក សម សោភ័ណ បានដាក់ឈ្មោះកូនគាត់ថា សិទ្ធី រីឯត្រកូលរបស់កូនគាត់យកតាមត្រកូលគាត់។ អាសយដ្ឋានរបស់លោក សម សោភ័ណ និងនាង គុណ រតនា នៅភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

**ខេត្ត ក្រុង** (១)........... *កណ្តាល* .............  **លេខ** (៤)............ *២៥* ...............................

**ស្រុក ខណ្ឌ** (២)........ *កណ្តាលស្ទឹង* .........  **សៀវភៅកំណើតលេខ** (៥)....០១/២០១២....

**ឃុំ សង្កាត់** (៣)......... *គោកត្រប់* ............  **ឆ្នាំ** (៦)....... *២០១២*....................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | *សម* | ភេទ (៩) | សញ្ជាតិ (១០) |
| នាមខ្លួនទារក (៨) | | *សិទ្ធី* | *ប្រុស* | *ខ្មែរ* |
| ជាអក្សរឡាតាំង (១១) | នាមត្រកូល | SAM | កូនទី (១២) | មាន ឬឥតខាន់ស្លា (១៣) |
| | នាមខ្លួនទារក | SITHY | *មួយ* | *មានខាន់ស្លា* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៤) | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២* | | |
| ទីកន្លែងកំណើត (១៥) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ........... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* ................. .............................................................................................................. | | |

| **ឪពុក ម្តាយទារក** | **ឪពុក** | | **ម្តាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៦) | *សម សោភ័ណ* (១៧) | រស់ ឬ ស្លាប់ | *គុណ រតនា* | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (១៨) | *SAM SORPHORN* | | *KUN RATANA* | |
| សញ្ជាតិ (១៩) | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* | |
| ទីកន្លែងកំណើត (២១) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | .........*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា* ........................ | | ....... *ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា* ..... | |
| មុខរបរពេលទារកកើត (២២) | *គ្រូបង្រៀន* | | *ជាងកាត់ដេរ* | |
| ទីលំនៅពេលទារកកើត (២៣) | ....... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* ..... | | ....... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* ..... | |
| លេខអត្តសញ្ញាណប័ណ្ណ (២៤) | | | | |

| | | | | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍ កំណើតទារក (២៥) | *សម សោភ័ណ* | ភេទ (២៦) *ប្រុស* | ឆ្នាំកំណើត (២៧) *១៩៧៥* | សញ្ជាតិ (២៨) *ខ្មែរ* |
| ត្រូវជាអ្វីនឹងទារក (២៩) | *ឪពុកបង្កើត* | | | |
| មុខរបរបច្ចុប្បន្ន (៣០) | *គ្រូបង្រៀន* | | | |
| ទីលំនៅបច្ចុប្បន្ន (៣១) | *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៣២) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៣៤) ធ្វើនៅ..... *គោកត្រប់* ..... ថ្ងៃទី *១២* ខែ *មករា* ឆ្នាំ *២០១២*

(៣៣) **ស្នាមមេដៃស្តាំអ្នករាយការណ៍**  (៣៥) **មន្ត្រីអត្រានុកូលដ្ឋាន**

*មេឃុំ*

(៣៦) *ហត្ថលេខា និងត្រា*

*សម សោភ័ណ*  *ទ្រី ហៀង*

**ខ). សម្រាប់ទារកដែលកើតពីឪពុកម្ដាយជាជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា**

☞ ជនបរទេស និងជនអន្តោប្រវេសន្តដែលបានរស់នៅស្របច្បាប់ ហើយបានកើតទារកនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឪពុកម្ដាយទារកនោះ អាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

☞ ចំពោះជនបរទេស ឬជនអន្តោប្រវេសន្តស្របច្បាប់ ការមករាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតត្រូវតែឪពុក និងម្ដាយផ្ទាល់ទើបបាន គឺមិនអនុញ្ញាតឱ្យអ្នកដទៃមករាយការណ៍ជំនួសឡើយ ។

☞ លិខិតស្នាមនានាដែលឪពុកម្ដាយទារក ត្រូវបង្ហាញមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ៖

- លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត
- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- លិខិតឆ្លងដែននៃប្រទេសសាមីរបស់ឪពុក ម្ដាយទារក និងទិដ្ឋាការដែលនៅមានសុពលភាព ឬបង្កាន់ដៃ “ប” (ប១ សំរាប់ជាគ្រួសារ ប៣ សំរាប់បុគ្គលមួយៗ) អនុញ្ញាតឱ្យស្នាក់នៅកម្ពុជាដែលនៅមានសុពលភាព (ចំពោះជនបរទេស ជនអន្តោប្រវេសន្ត)
- សំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ។ ករណីគ្មានសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវដាក់ថា “គ្មានខាន់ស្លា” ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងកំណើតទារក ៖

- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- ច្បាប់ថតចម្លងលិខិតឆ្លងដែន និងច្បាប់ថតចម្លងទិដ្ឋាការ ឬបង្កាន់ដៃ “ប”អនុញ្ញាតឱ្យស្នាក់នៅកម្ពុជា
- លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត
- ច្បាប់ថតចម្លងលិខិតស្នាមផ្លូវការផ្សេងៗ ដែលចេញដោយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា និង/ឬអាជ្ញាធរនៃប្រទេសសាមីរបស់ឪពុកម្ដាយទារក (ប្រសិនបើមាន) ។

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យលិខិតស្នាមអោយបានច្បាស់លាស់ បើឃើញត្រឹមត្រូវតាមការកំណត់ខាងលើហើយ ទើបចាប់ផ្ដើមសរសេរចូលបញ្ជីកំណើត ដោយអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីកំណើត សម្រាប់ទារកដែលកើតពីឪពុកម្ដាយជាពលរដ្ឋខ្មែរដែរ លើកលែងតែចំណុចមួយចំនួនត្រូវអនុវត្តដូចការណែនាំខាងក្រោម ៖

១៣). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិទារកតាមសញ្ជាតិឪពុក ឬម្ដាយទារក តាមការស្នើសុំរបស់ឪពុកម្ដាយទារក ដែលបានឯកភាពយកសញ្ជាតិណាមួយរបស់ខ្លួនដាក់ឱ្យទារកនោះ ។

**ឪពុក ម្ដាយទារក**

២៤). ទីលំនៅឯបរទេស ៖ ត្រូវសរសេរអំពីទីលំនៅរបស់ឪពុក និងម្ដាយទារកនៅប្រទេសដើមរបស់ខ្លួនជាអក្សរខ្មែរ ដោយយកសូរជាភាសាបរទេសឱ្យបានត្រឹមត្រូវ។

២៥). លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ ៖ ត្រូវសរសេរលេខលិខិតឆ្លងដែន និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។

២៦). ទិដ្ឋាការ ឬបង្កាន់ដៃ “ប” អនុញ្ញាតឱ្យស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ ៖ ត្រូវសរសេរលេខទិដ្ឋាការ ឬបង្កាន់ដៃ “ប” អនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំ ដែលអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា។

**បញ្ជាក់ ÷** ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋាន ពិនិត្យឃើញលិខិតឆ្លងដែន ឬទិដ្ឋាការ (ជាសេចក្ដីអនុញ្ញាតឱ្យចេញចូលស្នាក់នៅក្នុងប្រទេសកម្ពុជា ដែលតាមធម្មតាអាជ្ញាធរអន្តោប្រវេសន្ត បានបោះលើលិខិតឆ្លងដែនរបស់សាមីខ្លួន) ឬបង្កាន់ដៃ “ប” អនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសរយៈពេលកំណត់ មិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានកំណើតទេ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច។

| | |
|---|---|
| **ខេត្ត ក្រុង** (១)........................................ | **លេខ** (៤).................................................. |
| **ស្រុក ខណ្ឌ** (២)...................................... | **សៀវភៅកំណើតលេខ** (៥)...................... |
| **ឃុំ សង្កាត់** (៣)...................................... | **ឆ្នាំ** (៦)...................................................... |

## បញ្ជីកំណើតសំរាប់ជនបរទេស និង ជនអន្តោប្រវេសន្តស្របច្បាប់

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | | | ភេទ (៩) |
| នាមខ្លួនទារក (៨) | | | | |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | | កូនទី (១១) | មាន ឬគតខាន់ស្លា (១២) |
| | នាមខ្លួនទារក | | | |
| សញ្ជាតិ (១៣) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៤) | ថ្ងៃ ទី ខែ ឆ្នាំ | | | |
| ទីកន្លែងកំណើត (១៥) | ......................................................................................................<br>...................................................................................................... | | | |

| **ឪពុក ម្តាយទារក** | **ឪពុក** | | **ម្តាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៦) | (១៧) | រស់ ឬស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (១៨) | | | | |
| សញ្ជាតិ (១៩) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | | | |
| ទីកន្លែងកំណើត (២១) | ............................................................<br>............................................................<br>............................................................ | | ............................................................<br>............................................................<br>............................................................ | |
| មុខរបរបច្ចុប្បន្ន (២២) | | | | |
| ទីលំនៅបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា (២៣) | ............................................................<br>............................................................<br>............................................................ | | ............................................................<br>............................................................<br>............................................................ | |
| ទីលំនៅឯបរទេស (២៤) | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹម ថ្ងៃ ខែ ឆ្នាំ (២៥) | | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតអោយស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ (២៦) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(២៨) ធ្វើនៅ...................... ថ្ងៃទី........... ខែ.................... ឆ្នាំ............

(២៧) **ស្នាមមេដៃស្តាំអ្នករាយការណ៍** (២៩) **មន្ត្រីអត្រានុកូលដ្ឋាន**

(៣០) ហត្ថលេខា និងត្រា

### ២.២.៣. ការសរសេរសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានកំណើតទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឱ្យខុសពីខ្លឹមសារនៅក្នុងបញ្ជីកំណើត ដោយដកស្រង់យកតែចំណុចសំខាន់ៗពីបញ្ជីកំណើត ដូចខាងក្រោម ៖

**ក). សម្រាប់ប្រជាពលរដ្ឋខ្មែរ**

១). រាជធានីខេត្ត ៖ ចម្លងយកចំណុចទី១ នៃបញ្ជីកំណើត។

២). ក្រុង ស្រុក ខណ្ឌ ៖ ចម្លងយកចំណុចទី២ នៃបញ្ជីកំណើត។

៣). ឃុំ សង្កាត់ ៖ ចម្លងយកចំណុចទី៣ នៃបញ្ជីកំណើត។

៤). លេខ ៖ ចម្លងយកចំណុចទី៤ នៃបញ្ជីកំណើត។

៥). សៀវភៅកំណើតលេខ ៖ ចម្លងយកចំណុចទី៥ នៃបញ្ជីកំណើត។

៦). ឆ្នាំ ៖ ចម្លងយកចំណុចទី៦ នៃបញ្ជីកំណើត។

៧). នាមត្រកូល ៖ ចម្លងយកចំណុចទី៧ នៃបញ្ជីកំណើត។

៨). នាមខ្លួនទារក ៖ ចម្លងយកចំណុចទី៨ នៃបញ្ជីកំណើត។

៩). ភេទ ៖ ចម្លងយកចំណុចទី៩ នៃបញ្ជីកំណើត។

១០)). នាមត្រកូល និងនាមខ្លួនទារក ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១១ នៃបញ្ជីកំណើត។

១១). សញ្ជាតិ ៖ ចម្លងយកចំណុចទី១០ នៃបញ្ជីកំណើត។

១២). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី១៤ នៃបញ្ជីកំណើត។

១៣). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី១៥ នៃបញ្ជីកំណើត។

**ឪពុក ម្ដាយទារក**

១៤). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកចំណុចទី១៦ នៃបញ្ជីកំណើត។

១៥). ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១៨ នៃបញ្ជីកំណើត។

១៦). សញ្ជាតិ ៖ ចម្លងយកចំណុចទី១៩ នៃបញ្ជីកំណើត។

១៧). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី២០ នៃបញ្ជីកំណើត។

១៨). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី២១ នៃបញ្ជីកំណើត។

១៩). ទីលំនៅពេលទារកកើត ៖ ចម្លងយកចំណុចទី២៣ នៃបញ្ជីកំណើត។

២០). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ មើលចំណុចទី៣៤ នៃបញ្ជីកំណើត។

២១). មន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចទី៣៥ នៃបញ្ជីកំណើត។

២២). ហត្ថលេខា និងត្រា ៖ មើលចំណុចទី៣៦ នៃបញ្ជីកំណើត។

**ខ). សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់**

១). រាជធានី ខេត្ត ៖ ចម្លងយកចំណុចទី១ នៃបញ្ជីកំណើត។

២). ក្រុង ស្រុក ខណ្ឌ ៖ ចម្លងយកចំណុចទី២ នៃបញ្ជីកំណើត។

៣). ឃុំ សង្កាត់ ៖ ចម្លងយកចំណុចទី៣ នៃបញ្ជីកំណើត។

៤). លេខ ៖ ចម្លងយកចំណុចទី៤ នៃបញ្ជីកំណើត។

៥). សៀវភៅកំណើតលេខ ៖ ចម្លងយកចំណុចទី៥ នៃបញ្ជីកំណើត។

៦). ឆ្នាំ ៖ ចម្លងយកចំណុចទី៦ នៃបញ្ជីកំណើត។

៧). នាមត្រកូល ៖ ចម្លងយកចំណុចទី៧ នៃបញ្ជីកំណើត។

៨). នាមខ្លួនទារក ៖ ចម្លងយកចំណុចទី៨ នៃបញ្ជីកំណើត។

៩). ភេទ ៖ ចម្លងយកចំណុចទី៩ នៃបញ្ជីកំណើត។

១០)). នាមត្រកូល និងនាមខ្លួនទារក ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១០ នៃបញ្ជីកំណើត។

១១). សញ្ជាតិ ៖ ចម្លងយកចំណុចទី១៣ នៃបញ្ជីកំណើត។

១២). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី១៤ នៃបញ្ជីកំណើត។

១៣). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី១៥ នៃបញ្ជីកំណើត។

**ឪពុក ម្ដាយទារក**

១៤). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកចំណុចទី១៦ នៃបញ្ជីកំណើត។

១៥). ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១៨ នៃបញ្ជីកំណើត។

១៦). សញ្ជាតិ ៖ ចម្លងយកចំណុចទី១៩ នៃបញ្ជីកំណើត។

១៧). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី២០ នៃបញ្ជីកំណើត។

១៨). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី២១ នៃបញ្ជីកំណើត។

១៩). ទីលំនៅពេលទារកកើត ៖ ចម្លងយកចំណុចទី២៣ នៃបញ្ជីកំណើត។

២០). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ មើលចំណុចទី២៨ នៃបញ្ជីកំណើត។

២១). មន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចទី២៩ នៃបញ្ជីកំណើត។

២២). ហត្ថលេខា និងត្រា ៖ មើលចំណុចទី៣០ នៃបញ្ជីកំណើត។

**បញ្ជាក់ ÷**

☞ ការប្រគល់សំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ក្រោយពីសរសេរ ចុះហត្ថលេខា និងបោះត្រាលើបញ្ជីទាំងពីរ និងសំបុត្រកំណើតច្បាប់ដើមមួយសន្លឹករួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រកំណើតច្បាប់ដើមនេះ ទៅឱ្យអ្នកមករាយការណ៍កំណើតទារកដែលសុំ ចុះសៀវភៅអត្រានុកូលដ្ឋានកំណើតដោយមិនបង់ថ្លៃអ្វីឡើយ និងណែនាំឱ្យរក្សាទុកដាក់ឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រកំណើតច្បាប់ដើមជូនជាលើកទីពីរបានទេ ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រកំណើតច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួនមានតែមួយច្បាប់ប៉ុណ្ណោះ ។ សំបុត្រកំណើតច្បាប់ដើមមិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ជៀសវាងការបាត់បង់ ដូច្នេះត្រូវធ្វើសេចក្ដីចម្លងសំបុត្រកំណើតឱ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| | |
|---|---|
| **ខេត្ត** ~~**ក្រុង**~~ (១) ---- *កណ្តាល* ------ | **លេខ** (៤)------ *២៥* ------------------ |
| **ស្រុក** ~~**ខណ្ឌ**~~ (២) ---- *កណ្តាលស្ទឹង* --- | **សៀវភៅកំណើតលេខ** (៥)--០១/២០១២-- |
| **ឃុំ** ~~**សង្កាត់**~~ (៣) ---- *គោកត្រប់* ----- | **ឆ្នាំ** (៦)-------- *២០១២*---------------- |

## សំបុត្រកំណើត

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | *សម* | ភេទ (៩) |
| នាមខ្លួនទារក (៨) | | *សិទ្ធី* | *ប្រុស* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | SAM | |
| | នាមខ្លួនទារក | SITHY | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២* | |
| ទីកន្លែងកំណើត (១៣) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | .... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* ...................................................................... | |

| **ឪពុក ម្តាយទារក** | **ឪពុក** | **ម្តាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៤) | *សម សោភ័ណ* | *គុណ រតនា* |
| ជាអក្សរឡាតាំង (១៥) | SAM SORPHORN | KUN RATANA |
| សញ្ជាតិ (១៦) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៧) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* |
| ទីកន្លែងកំណើត (១៨) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ...*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា*... | ...*ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា*... |
| ទីលំនៅពេលទារកកើត (១៩) | .......*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាល ស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* | |

(២០) ធ្វើនៅ.... *គោកត្រប់* ..... ថ្ងៃទី *១២* ខែ *មករា* ឆ្នាំ *២០១២*

(២១) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២២) *ហត្ថលេខា និងត្រា*

*ទ្រី ហៀង*

## ២.៣. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសំបុត្របញ្ជាក់កំណើត

☞ ប្រជាពលរដ្ឋខ្មែរដែលបានកើតហើយទុកឱ្យហួសរយៈពេល៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នៅសាលាឃុំ សង្កាត់សាមី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីចំនួន ០២រូប ជានីតិជន ហើយត្រូវមានទីលំនៅពិតប្រាកដ មកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។ ពាក្យប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតរបស់សាមីខ្លួន ឬឪពុក ឬម្តាយ ឬអាណាព្យាបាល ចំនួន០១ច្បាប់ ត្រូវបង់ថ្លៃ ១.០០០ រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅក្នុងខេត្តរតនគីរី ឧត្តរមានជ័យ មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ និងបង់ថ្លៃ ៤.០០០រៀល សម្រាប់ប្រជាពលរដ្ឋដែលមាន ទីលំនៅក្រៅពីខេត្តខាងលើ។

☞ ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ។

### ២.៣.១. លិខិតស្នាមនានាដែលពាក់ពន្ធ័នឹងការបញ្ជាក់កំណើត

☞ សាមីខ្លួន និងសាក្សី ត្រូវយកជាប់ជាមួយនូវលិខិតស្នាមចាំបាច់មួយចំនួន ដូចខាងក្រោម ៖

- សៀវភៅគ្រួសាររបស់សាមីខ្លួន និង របស់សាក្សី ឬ
- អត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន និង របស់សាក្សី (ប្រសិនបើមាន) ឬ
- ឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី បើជាមន្ត្រីរាជការ

☞ បើអាចធ្វើបាន មន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងបញ្ជាក់កំណើត ៖

- ច្បាប់ថតចម្លងសៀវភៅគ្រួសាររបស់សាមីខ្លួន និង របស់សាក្សី ឬ
- ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន និង របស់សាក្សី ឬ
- ច្បាប់ថតចម្លងឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី បើជាមន្ត្រីរាជការ ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមទៅឱ្យសាមីខ្លួន និងសាក្សីវិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

### ២.៣.២. ការសរសេរចុះបញ្ជីបញ្ជាក់កំណើត

☞ នៅពេលមានអ្នកមករាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសុំសំបុត្របញ្ជាក់កំណើត និងបន្ទាប់ពីបានពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីបញ្ជាក់កំណើតចំនួន០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតភ្លោះ។

☞ របៀបសរសេរចុះបញ្ជីបញ្ជាក់កំណើត នៃសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត ត្រូវអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីកំណើតដែរ លើកលែងតែចំណុចមួយចំនួនខាងក្រោមនេះ ៖

១៤). ទីកន្លែងកំណើត (របស់សាមីខ្លួន) ៖ ត្រូវសរសេរអាសយដ្ឋាននៃលំនៅដ្ឋានដែលសាមីខ្លួនបានកើតនៅសម័យកាលនោះ ដោយសរសេរឈ្មោះភូមិ ឃុំ ឬសង្កាត់ ស្រុក ឬខណ្ឌ ខេត្ត ឬក្រុង ឈ្មោះប្រទេស។

**ឧទាហរណ៍** ÷ សាមីខ្លួនបានកើតនៅភូមិបាក់ខែង ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល។ បច្ចុប្បន្នភូមិបាក់ខែង ត្រូវបានកាត់ឱ្យនៅចំណុះសង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ដូចនេះ ទីកន្លែងកំណើតរបស់សាមីខ្លួន ៖ ភូមិបាក់ខែង ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា។

**សាក្សី**

២៣). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួននៃសាក្សីទាំង២រូប ដែលមានវត្តមានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

២៤). ភេទ ៖ ត្រូវសរសេរភេទរបស់សាក្សីទាំង២រូប។

២៥). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់សាក្សីទាំង២រូប។

២៦). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់សាក្សីទាំង០២រូប។

២៧). ទីកន្លែងកំណើត ៖ ត្រូវសរសេរទីកន្លែងកំណើតរបស់សាក្សីទាំង០២រូប អំពីលេខផ្ទះ លេខផ្លូវ (ប្រសិនបើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស។

២៨). មុខរបរបច្ចុប្បន្ន ៖ ត្រូវសរសេរអំពីមុខរបរបច្ចុប្បន្នរបស់សាក្សីទាំង០២រូប។

២៩). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរទីលំនៅបច្ចុប្បន្នរបស់សាក្សីទាំង០២រូប អំពីលេខផ្ទះ លេខផ្លូវ (ប្រសិនបើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស។

៣០). លេខអត្តសញ្ញាណប័ណ្ណ ៖ ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណរបស់សាក្សីទាំង២រូប (បើមាន)

៣១). ស្នាមមេដៃស្ដាំរបស់អ្នកសុំបញ្ជាក់ និងសាក្សីទាំង២រូប ៖ ត្រូវផ្ដិតមេដៃស្ដាំរបស់អ្នកសុំបញ្ជាក់ និងសាក្សីទាំង២រូប ទុកជាភស្តុតាង ក្រោយពេលឯកភាពថាត្រឹមត្រូវ។ បន្ទាប់មក សរសេរឈ្មោះរបស់អ្នកសុំបញ្ជាក់ និងសាក្សីទាំង២រូប ពីក្រោមស្នាមមេដៃរបស់ខ្លួន។

**បញ្ជាក់** ÷

**ក). សាមីខ្លួនជាអនីតិជនដែលមិនមានសំបុត្រកំណើតច្បាប់ដើម**

មន្ត្រីអត្រានុកូលដ្ឋានមិនត្រូវអនុញ្ញាតឱ្យអនីតិជន (អ្នកមានអាយុក្រោម១៨ឆ្នាំ) ផ្ដិតមេដៃស្ដាំនៅលើបញ្ជីបញ្ជាក់កំណើតនោះទេ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវស្នើឱ្យឪពុក ឬម្ដាយ ឬញាតិជានីតិជនដែលរស់នៅជាមួយឪពុកម្ដាយ ដែលមកសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត ផ្ដិតមេដៃស្ដាំជំនួសសាមីខ្លួន។

ត្រង់ចំណុច "ស្នាមមេដៃស្ដាំ" មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរបន្ថែមពាក្យអនីតិជន បន្ទាប់ពីពាក្យសាមីខ្លួន ហើយនៅពីក្រោមពាក្យសាមីខ្លួនអនីតិជន ត្រូវសរសេរពាក្យ ឪពុក ឬម្ដាយ ឬញាតិជានីតិជនដែល រស់នៅជាមួយឪពុក ម្ដាយ។ ករណីឪពុក ម្ដាយពុំមានសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្ដាយត្រូវផ្ដិតមេដៃនៅពីក្រោមពាក្យសាមីខ្លួនអនីតិជន លើកលែងតែសហព័ទ្ធណាមួយស្លាប់អាចផ្ដិតស្នាមមេដៃអ្នកដែលនៅរស់ ។

ឧទាហរណ៍ ៖

| | |
|---|---|
| **ស្នាមមេដៃស្តាំ**<br>សាមីខ្លួន សាក្សី សាក្សី | **ស្នាមមេដៃស្តាំ**<br>សាមីខ្លួនអនីតិជន សាក្សី សាក្សី<br>ឪពុក ឬម្តាយ ឬញាតិជានីតិជនដែលរស់នៅជាមួយឪពុក ម្តាយ<br>(ឈ្មោះម្ចាស់ស្នាមមេដៃស្តាំ) |

### ខ). សាមីខ្លួនជានីតិជនដែលគ្មានម្រាមដៃ

បើនីតិជន (អ្នកមានអាយុចាប់ពី១៨ឆ្នាំឡើង) ដែលគ្មានម្រាមដៃ មកសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នៅត្រង់ចំណុច "ស្នាមមេដៃស្តាំ" មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុវត្តដូចខាងក្រោម ៖

| ករណី | ការសរសេរបន្ថែមពីក្រោមពាក្យ "សាមីខ្លួន" | ម្រាមដៃដែលត្រូវផ្តិត |
|---|---|---|
| គ្មានមេដៃស្តាំ | មេដៃឆ្វេង | មេដៃឆ្វេង |
| គ្មានមេដៃទាំងពីរ | ចង្អុលដៃស្តាំ | ចង្អុលដៃស្តាំ |
| គ្មានមេដៃទាំងពីរ និងចង្អុលដៃស្តាំ | ចង្អុលដៃឆ្វេង | ចង្អុលដៃឆ្វេង |
| គ្មានមេដៃទាំងពីរ និងចង្អុលដៃទាំងពីរ | ម្រាមដៃកណ្តាលស្តាំ | ម្រាមដៃកណ្តាលស្តាំ |
| គ្មានមេដៃទាំង២ ចង្អុលដៃទាំង២ និងម្រាមដៃកណ្តាលស្តាំ | ម្រាមដៃកណ្តាលឆ្វេង | ម្រាមដៃកណ្តាលឆ្វេង |
| គ្មានមេដៃទាំង២ ចង្អុលដៃទាំង២ និងម្រាមដៃកណ្តាលទាំង២ | ម្រាមនាងដៃស្តាំ | ម្រាមនាងដៃស្តាំ |
| គ្មានមេដៃទាំង២ ចង្អុលដៃទាំង២ ម្រាមដៃកណ្តាលទាំង២ និងម្រាមនាងដៃស្តាំ | ម្រាមនាងដៃឆ្វេង | ម្រាមនាងដៃឆ្វេង |
| គ្មានមេដៃទាំង២ ចង្អុលដៃទាំង២ ម្រាមដៃកណ្តាលទាំង២ និងម្រាមនាងដៃទាំង២ | ម្រាមកូនដៃស្តាំ | ម្រាមកូនដៃស្តាំ |
| គ្មានមេដៃទាំង២ ចង្អុលដៃទាំង២ ម្រាមដៃកណ្តាលទាំង២ ម្រាមនាងដៃទាំង២ និងម្រាមកូនដៃស្តាំ | ម្រាមកូនដៃឆ្វេង | ម្រាមកូនដៃឆ្វេង |
| គ្មានម្រាមដៃទាំងអស់ | គ្មានម្រាមដៃទាំងអស់ | មិនចាំបាច់ផ្តិតអ្វីទេ |

### គ). សាមីខ្លួនជានីតិជន អះអាងថាខ្លួនមិនស្គាល់ឪពុក ម្តាយ

បើសាមីខ្លួនអះអាងថាខ្លួនមិនស្គាល់ឪពុក ម្តាយ ហើយសាក្សីទាំង០២រូប ក៏បានបញ្ជាក់ថា សាមីខ្លួនពិតជាមិនស្គាល់ឪពុក ម្តាយរបស់ខ្លួន ហើយពួកគេ (សាក្សីទាំង០២រូប) ពិតជាមិនស្គាល់ឪពុក ម្តាយរបស់សាមីខ្លួនមែន មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរនៅផ្នែកឪពុក ត្រង់ខ្ទង់ "នាមត្រកូល និងនាមខ្លួន" ដាក់ថា "មិនស្គាល់" នៅផ្នែកម្តាយត្រង់ខ្ទង់ "នាមត្រកូល និងនាមខ្លួន" ក៏ត្រូវសរសេរថា "មិនស្គាល់" ដែរ ហើយសាមីខ្លួនមានតែឈ្មោះពុំមានត្រកូលទេ។

**ឧទាហរណ៍ ២.២** ÷ ការសរសេរចុះបញ្ជីបញ្ជាក់កំណើតលេខ១០ តាមខ្លឹមសារអត្ថបទខាងក្រោម ៖

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១២ លោក យឹម សុផល បានទៅសាលាសង្កាត់ព្រែកព្នៅ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតរបស់គាត់។

លោក យឹម សុផល ភេទប្រុស សញ្ជាតិខ្មែរ កើតថ្ងៃសុក្រ ទី២៥ ខែសីហា ឆ្នាំ១៩៦៩ នៅភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល គាត់ជាកូនទី៣។

ឪពុកយឹម សុផល ឈ្មោះ យឹម ដួង មានសញ្ជាតិខ្មែរ កើតថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៣៩ នៅភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ គាត់ស្លាប់ក្នុងឆ្នាំ១៩៧៨។

ម្តាយលោកយឹម សុផល ឈ្មោះ នូ ផល្លា មានសញ្ជាតិខ្មែរ កើតថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៤៣ នៅភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល គាត់ស្លាប់ក្នុងឆ្នាំ១៩៧៨។

លោក គឹម សុខ សញ្ជាតិខ្មែរ កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៦១ នៅភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល មុខរបរជាកសិករ ត្រូវជាមិត្តភ័ក្ររបស់លោកយឹម សុផល ។

អ្នកស្រី ឆោម វ៉ាឱ្យ មានសញ្ជាតិខ្មែរ កើតថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៦៩ នៅភូមិខ្ពប ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានមុខរបរជាកសិករ ត្រូវជាប្រពន្ធលោក គឹម សុខ។

លោកគឹម សុខ និងនាង ឆោម វ៉ាឱ្យ បានទៅធ្វើជាសាក្សីក្នុងការបញ្ជាក់កំណើតលោក យឹម សុផល ពីព្រោះអ្នកទាំងបីនាក់មានទីលំនៅបច្ចុប្បន្ននៅជាមួយគ្នាក្នុងភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ហើយអ្នកទាំងបីនាក់នេះគ្មានអត្តសញ្ញាណប័ណ្ណទេ។

| | | | |
|---|---|---|---|
| ~~**ខេត្ត**~~ ~~**ក្រុង**~~ (១)....... *រាជធានីភ្នំពេញ*............ | | **លេខ** (៤)............. *១០*............................... | |
| ~~**ស្រុក**~~ **ខណ្ឌ** (២)...... *សែនសុខ*.................. | | **សៀវភៅកំណើតលេខ** (៥)... *០១/២០១២* .... | |
| ~~**ឃុំ**~~ **សង្កាត់** (៣)....... *ព្រែកព្នៅ* ............... | | **ឆ្នាំ** (៦)........... *២០១២*................................ | |

# បញ្ជីបញ្ជាក់កំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | *យឹម* | ភេទ (៩) | សញ្ជាតិ (១០) | កូនទី (១១) |
| នាមខ្លួនអ្នកកើត (៨) | *សុផល* | *ប្រុស* | *ខ្មែរ* | *បី* |
| ជាអក្សរឡាតាំង (១២) នាមត្រកូល | YIM | | | |
| ជាអក្សរឡាតាំង (១២) នាមខ្លួនអ្នកកើត | SOPHAL | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៣) | *ថ្ងៃ សុក្រ ទី ២៥ ខែ សីហា ឆ្នាំ១៩៦៩* | | | |
| ទីកន្លែងកំណើត (១៤)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ..... *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..........................<br>................................................................................ | | | |

| **ឪពុក ម្ដាយ** | **ឪពុក** | | **ម្ដាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៥) | *យឹម ដួង* (១៦) | រស់ ឬស្លាប់ | *នូ ផល្លា* | រស់ ឬស្លាប់ |
| ជាអក្សរឡាតាំង (១៧) | YIM DUONG | | NOU PHALLA | |
| សញ្ជាតិ (១៨) | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | *ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ១៩៣៩* | | *ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ១៩៤៣* | |
| ទីកន្លែងកំណើត (២០)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ......*ភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រទេសកម្ពុជា* ...................... | | ........ *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| មុខរបរបច្ចុប្បន្ន (២១) | | | | |
| ទីលំនៅបច្ចុប្បន្ន (២២) | | | | |

| **អំពីសាក្សី** | **សាក្សី** | | **សាក្សី** | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួន (២៣) | *គីម សុខ* (២៤) | ភេទ *ប្រុស* | *ឆោម រ៉ាឌី* | ភេទ *ស្រី* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៥) | *ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៦១* (២៦) | សញ្ជាតិ *ខ្មែរ* | *ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៦៩* | សញ្ជាតិ *ខ្មែរ* |
| ទីកន្លែងកំណើត (២៧)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ........ *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | | .....*ភូមិខ្ពប ឃុំកោះឧញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| មុខរបរបច្ចុប្បន្ន (២៨) | *កសិករ* | | *កសិករ* | |
| ទីលំនៅបច្ចុប្បន្ន (២៩) | ........ *ភូមិដួង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | | ........ *ភូមិដួង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| លេខអត្តសញ្ញាណប័ណ្ណ (៣០) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៣២) ធ្វើនៅ..... *ព្រែកព្នៅ* ....... ថ្ងៃទី *១១* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(៣១) **ស្នាមមេដៃស្ដាំ**

សាមីខ្លួន សាក្សី សាក្សី

*យឹម សុផល* *គីម សុខ* *ឆោម រ៉ាឌី*

(៣៣) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(៣៤) *ហត្ថលេខា និងត្រា*

*ពេជ ណុំ*

### ២.៣.៣. ការសរសេរសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក

☞ ក្រោយពេលសរសេរបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឱ្យខុសពីខ្លឹមសារក្នុងបញ្ជីបញ្ជាក់កំណើត ដោយដកស្រង់យកចំណុចសំខាន់ៗពីបញ្ជីបញ្ជាក់កំណើត ។

☞ ការសរសេរសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក មានលក្ខណៈប្រហាក់ប្រហែលនឹងការសរសេរសំបុត្រកំណើតច្បាប់ដើមមួយសន្លឹកដែរ ៖

១). រាជធានី ខេត្ត ៖ ចម្លងយកចំណុចទី១ នៃបញ្ជីបញ្ជាក់កំណើត ។

២). ក្រុង ស្រុក ខណ្ឌ ៖ ចម្លងយកចំណុចទី២ នៃបញ្ជីបញ្ជាក់កំណើត ។

៣). ឃុំ សង្កាត់ ៖ ចម្លងយកចំណុចទី៣ នៃបញ្ជីបញ្ជាក់កំណើត ។

៤). លេខ ៖ ចម្លងយកចំណុចទី៤ នៃបញ្ជីបញ្ជាក់កំណើត ។

៥). សៀវភៅកំណើតលេខ ៖ ចម្លងយកចំណុចទី៥ នៃបញ្ជីបញ្ជាក់កំណើត ។

៦). ឆ្នាំ ៖ ចម្លងយកចំណុចទី៦ នៃបញ្ជីបញ្ជាក់កំណើត ។

៧). នាមត្រកូល ៖ ចម្លងយកចំណុចទី៧ នៃបញ្ជីបញ្ជាក់កំណើត ។

៨). នាមខ្លួនអ្នកកើត ៖ ចម្លងយកចំណុចទី៨ នៃបញ្ជីបញ្ជាក់កំណើត ។

៩). ភេទ ៖ ចម្លងយកចំណុចទី៩ នៃបញ្ជីបញ្ជាក់កំណើត ។

១០)). នាមត្រកូល និងនាមខ្លួនអ្នកកើត ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១២នៃបញ្ជីបញ្ជាក់ កំណើត ។

១១). សញ្ជាតិ ៖ ចម្លងយកចំណុចទី១០ នៃបញ្ជីបញ្ជាក់កំណើត ។

១២). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី១៣ នៃបញ្ជីបញ្ជាក់កំណើត ។

១៣). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី១៤ នៃបញ្ជីកំណើត ។

**ឪពុក ម្តាយ**

១៤). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកចំណុចទី១៥ នៃបញ្ជីបញ្ជាក់កំណើត ។

១៥). ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១៧ នៃបញ្ជីបញ្ជាក់កំណើត ។

១៦). សញ្ជាតិ ៖ ចម្លងយកចំណុចទី១៨ នៃបញ្ជីបញ្ជាក់កំណើត ។

១៧). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី១៩ នៃបញ្ជីបញ្ជាក់កំណើត ។

១៨). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី២០ នៃបញ្ជីបញ្ជាក់កំណើត ។

១៩). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ មើលចំណុចទី៣២ នៃបញ្ជីបញ្ជាក់កំណើត ។

២០). មន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចទី៣៣ នៃបញ្ជីបញ្ជាក់កំណើត ។

២១). ហត្ថលេខា និងត្រា ៖ មើលចំណុចទី៣៤ នៃបញ្ជីបញ្ជាក់កំណើត ។

**បញ្ជាក់ ៖**

☞ ការប្រគល់សំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក ក្រោយពីសរសេរ ចុះហត្ថលេខា និងបោះត្រាលើសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក រួចហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ទៅឱ្យសាមីខ្លួន ដែលមកសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងណែនាំឱ្យអ្នកនោះថែរក្សាទុកដាក់ឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្របញ្ជាក់កំណើតច្បាប់ដើម ជូនជាលើកទីពីរបានទេ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្របញ្ជាក់កំណើតច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួនមានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ដូច្នេះ គួរធ្វើសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតឱ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** (១) ---- *រាជធានីភ្នំពេញ* ---- **លេខ** (៤)------ *១០* ------------------
**ស្រុក ខណ្ឌ** (២) ---- *សែនសុខ* ------- **សៀវភៅកំណើតលេខ** (៥)--០១/២០១២--
**ឃុំ សង្កាត់** (៣) ---- *ព្រែកព្នៅ* ----- **ឆ្នាំ** (៦)-------- *២០១២*------------------

## សំបុត្របញ្ជាក់កំណើត

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | *យឹម* | ភេទ (៩) |
| នាមខ្លួនអ្នកកើត (៨) | | *សុផល* | *ប្រុស* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | YIM | |
| | នាមខ្លួនអ្នកកើត | SOPHAL | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ សុក្រ ទី ២៥ ខែ សីហា ឆ្នាំ១៩៦៩* | |
| ទីកន្លែងកំណើត (១៣) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | ... *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* .... ....................................................................................... | |

| **ឪពុក ម្ដាយ** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៤) | *យឹម ដួង* | *នូ ផល្លា* |
| ជាអក្សរឡាតាំង (១៥) | YIM DUONG | NOU PHALLA |
| សញ្ជាតិ (១៦) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៧) | *ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៣៩* | *ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៤៣* |
| ទីកន្លែងកំណើត (១៨) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | *ភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រទេសកម្ពុជា* | *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* |

(១៩) ធ្វើនៅ..... *ព្រែកព្នៅ* ....... ថ្ងៃទី *១១* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(២០) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២១) *ហត្ថលេខា និងត្រា*

*ពេជ ណុំ*

## ២.៤. សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត

☞ ការសុំចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ហើយត្រូវបោះត្រាផង ។

☞ ការសុំចម្លង ឬសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតនៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌ។

- បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាល ឬអភិបាលរងក្រុង ស្រុក ខណ្ឌ ដែលអភិបាល ក្រុង ស្រុក ខណ្ឌប្រតិភូកម្ម និងបោះត្រាផង។

☞ ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើត នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ៖

- ការសុំចម្លង ឬសម្រង់សំបុត្រកំណើត នៅក្នុងឆ្នាំមិនទាន់ដាច់ អ្នកសុំត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ
- ការសុំចម្លង ឬសម្រង់សំបុត្រកំណើត នៅក្នុងឆ្នាំដែលកន្លងផុតទៅ អ្នកសុំត្រូវដាក់ពាក្យសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ហើយស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ត្រូវផ្ញើពាក្យសុំចម្លង ឬសុំស្រង់មកក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុកនៅទីនោះ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្រកំណើត ត្រូវយកសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើត មកជាមួយ ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់កំណើត ត្រូវយកសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតមកជាមួយ។

**បញ្ជាក់** ៖ ករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចមកសុំចម្លងបាន ត្រូវមានល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

- រាយការណ៍ជាលាយល័ក្ខណ៍អក្សរឱ្យបានច្បាស់សាល់ អំពីមូលហេតុនៃការបាត់បង់

- បញ្ជាក់ពីឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និងឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន ដើម្បីមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅងាយស្រួលក្នុងការស្វែងរក ។

### ២.៤.១. ការសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត

☞ មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ដែលសាមីខ្លួនយកមក ដោយធ្វើការ ៖

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតនោះ ពិតជាត្រឹមត្រូវដែលចេញដោយក្រសួងមហាផ្ទៃ មែនដែរឬទេ?

- ផ្ទៀងផ្ទាត់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតនោះ ជាមួយបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើត ឬក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នូវចំណុចមួយចំនួនដូចខាងក្រោម ៖
  – ឆ្នាំដែលអនុវត្តនៃសៀវភៅអត្រានុកូលដ្ឋាន
  – លេខសៀវភៅអត្រានុកូលដ្ឋាន
  – លេខបញ្ជីអត្រានុកូលដ្ឋាន

☞ នៅពេលពិនិត្យសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឃើញថាជាសំបុត្រច្បាប់ដើមពិតប្រាកដហើយ ទើបមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្តើមសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត។

☞ ការសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត ដោយចម្លងចេញពី ៖

- សៀវភៅអត្រានុកូលដ្ឋានកំណើត បើសុំចម្លងសំបុត្រកំណើត។
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត បើសុំចម្លងសំបុត្របញ្ជាក់កំណើត។

☞ របៀបសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត ដូចខាងក្រោម ៖

១). លេខរៀង ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពីលេខ ០១។

២). ថ្ងៃខែឆ្នាំចេញសេចក្តីចម្លង ៖ ត្រូវចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខ ខ្មែរតាមគ្រិស្តសករាជ គឺជាថ្ងៃខែឆ្នាំដែលមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ចុះហត្ថលេខាលើសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។

៣). ចម្លងសំបុត្រកំណើត ឬចម្លងសំបុត្របញ្ជាក់កំណើត ៖

- បើចម្លងសំបុត្រកំណើត ត្រូវសរសេរក្នុងខ្ទង់នេះថា “ចម្លងសំបុត្រកំណើត” ។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវសរសេរក្នុងខ្ទង់នេះថា “ចម្លងសំបុត្របញ្ជាក់កំណើត” ។

**សៀវភៅ**

៤). លេខ ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី៥ នៃបញ្ជីកំណើត។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី៥ នៃបញ្ជីបញ្ជាក់កំណើត។

៥). ឃុំ សង្កាត់ ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី៣ នៃបញ្ជីកំណើត។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី៣ នៃបញ្ជីបញ្ជាក់កំណើត។

**សំបុត្រ**

៦). លេខ ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី៤ នៃបញ្ជីកំណើត។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី៤ នៃបញ្ជីបញ្ជាក់កំណើត។

៧). ចុះថ្ងៃ ខែ ឆ្នាំ ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី៣៤ នៃបញ្ជីកំណើត ។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី៣២ នៃបញ្ជីបញ្ជាក់កំណើត ។

**អ្នកកើត**

៨). នាមត្រកូល និងនាមខ្លួន ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី៧ និងទី៨ នៃបញ្ជីកំណើត ។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី ៧ និងទី៨ នៃបញ្ជីបញ្ជាក់កំណើត ។

៩). ភេទ ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី៩ នៃបញ្ជីកំណើត ។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី ៩ នៃបញ្ជីបញ្ជាក់កំណើត ។

១០). សញ្ជាតិ ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី១០ នៃបញ្ជីកំណើត ។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី១០ នៃបញ្ជីបញ្ជាក់កំណើត ។

១១). ថ្ងៃ ខែ ឆ្នាំកំណើត ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី១៤ នៃបញ្ជីកំណើត ។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី១៣ នៃបញ្ជីបញ្ជាក់កំណើត ។

១២). នាមត្រកូល និងនាមខ្លួនឪពុក ម្តាយអ្នកកើត ៖

- បើចម្លងសំបុត្រកំណើត ត្រូវចម្លងយកពីចំណុចទី១៦ នៃបញ្ជីកំណើត ។
- បើចម្លងសំបុត្របញ្ជាក់កំណើត ត្រូវចម្លងយកពីចំណុចទី១៥ នៃបញ្ជីបញ្ជាក់កំណើត ។

**អ្នកសុំចម្លងសំបុត្រកំណើត និងបញ្ជាក់កំណើត**

១៣). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួន របស់អ្នកមកសុំចម្លងសំបុត្រ កំណើត ឬអ្នកមកសុំចម្លងសំបុត្របញ្ជាក់កំណើត ។

១៤). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរទីលំនៅបច្ចុប្បន្ន របស់អ្នកមកសុំចម្លងសំបុត្រកំណើត ឬ អ្នកមកសុំចម្លងសំបុត្របញ្ជាក់កំណើត ដោយសរសេរលេខផ្ទះ លេខផ្លូវ (បើសិនជាមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ស្រុក ឬខណ្ឌខេត្ត ឬក្រុង និង ប្រទេស ។

១៥). ត្រូវជាអ្វីនឹងអ្នកកើត ៖ ត្រូវសរសេរពីការពាក់ព័ន្ធរវាងអ្នកកើត និងអ្នកសុំចម្លង ។ អ្នកមកសុំចម្លងជាឪពុក ម្តាយ សាច់ញាតិសន្តាន ឬអ្នកជិតខាងនៃអ្នកកើត ។ **ឧទាហរណ៍** ÷ បើជាឪពុកបង្កើត ត្រូវសរសេរ “ឪពុកបង្កើត” បើជាមីងបង្កើត ត្រូវសរសេរ “មីងបង្កើត” ។

១៦). ស្នាមមេដៃស្តាំ ៖ ក្រោយពីសរសេរបំពេញគ្រប់ខ្ទង់រួចហើយ ត្រូវឱ្យអ្នកមកសុំចម្លង ផ្តិតមេដៃស្តាំ ។

**មន្ត្រីចម្លងសំបុត្រកំណើត និងបញ្ជាក់កំណើត**

១៧). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនអ្នកដែលចុះហត្ថលេខាលើសេចក្តី

ចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត។

១៨). មុខងារ ៖ ត្រូវសរសេរមុខងាររបស់មន្ត្រីដែលមានឈ្មោះនៅចំណុច១៧ ៖

- អាចសរសេរ"មេឃុំ" ឬ"ចៅសង្កាត់" បើគាត់ជាមេឃុំ ឬចៅសង្កាត់។ អាចសរសេរ"ជំទប់ទី១" ឬ "ចៅសង្កាត់រងទី១" បើគាត់បានទទួលការផ្ទេរសិទ្ធិ។
- អាចសរសេរ "ប្រធានការិយាល័យរដ្ឋបាលទូទៅ" បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន នៅសាលាស្រុក ខណ្ឌ។
- អាចសរសេរ "ក្រឡាបញ្ជី" បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន នៅតុលាការខេត្ត ក្រុង។

១៩). ចំនួនសន្លឹកចម្លង ៖ ត្រូវសរសេរចំនួនសន្លឹកនៃសេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតដែលបានចម្លង ដោយសរសេរជាលេខខ្មែរ។

២០). សេចក្ដីផ្សេងៗ ៖ បើមានករណីពិសេសដែលគ្មានរៀបរាប់ក្នុងចំណុចទាំង១៩ នោះទេ ត្រូវសរសេរក្នុងសេចក្ដីផ្សេងៗនេះ។ បើគ្មានករណីពិសេសទេ មិនត្រូវសរសេរអ្វីឡើយ ដោយទុកឱ្យនៅទំនេរ។
**ឧទាហរណ៍** ÷ ការចម្លងលើកទី២ ស្នាមមេដៃឆ្វេង (បើអ្នកមកសុំចម្លងពុំមានមេដៃស្ដាំ)... ។ល។

**ឧទាហរណ៍ ២.៣** ÷ ការសរសេរសៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើតនៅសាលាឃុំ ឬសង្កាត់ តាមខ្លឹមសារអត្ថបទខាងក្រោម ៖

ថ្ងៃច័ន្ទ ទី០១ ខែមីនា ឆ្នាំ២០១២ លោក សម សោភ័ណ បានទៅសុំចម្លងសំបុត្រកំណើតឱ្យកូនប្រុសរបស់គាត់ឈ្មោះ សម សិទ្ធី ចំនួន១០សន្លឹក ដោយកាន់យកទៅជាមួយនូវសំបុត្រកំណើតច្បាប់ដើមរបស់កូនគាត់ លេខ២៥ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ ក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតលេខ ០១/២០១២ ដើម្បីបង្ហាញមន្ត្រីអត្រានុកូលដ្ឋាន ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

មន្ត្រីអត្រានុកូលដ្ឋានឃុំគោកត្រប់ឈ្មោះ មោក ស៊ីម។

**ឧទាហរណ៍ ២.៤** ÷ ការសរសេរចូលក្នុងសៀវភៅចម្លង និងចម្លងសំបុត្របញ្ជាក់កំណើត នៅសាលាស្រុក ខណ្ឌ តាមខ្លឹមសារអត្ថបទខាងក្រោម ៖

ថ្ងៃពុធ ទី១៤ ខែមករា ឆ្នាំ២០១២ លោក យឹម សុផល បានទៅសុំចម្លងសំបុត្របញ្ជាក់កំណើតរបស់គាត់ចំនួន១៥សន្លឹក នៅសាលាស្រុកពញាឮ ខេត្តកណ្ដាល ដោយបានកាន់យកទៅជាមួយនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើមរបស់គាត់លេខ១០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតលេខ ០១/២០១១ ដើម្បីបង្ហាញមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅស្រុកពញាឮ។

គ្រួសាររបស់លោក យឹម សុផល បច្ចុប្បន្នរស់នៅភូមិដូង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល។

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុកពញាឮឈ្មោះ នៅ ណាត អភិបាលស្រុកពញាឮឈ្មោះ ទេព សុធីរ។

លេខថ្ងៃខែឆ្នាំបញ្ជាក់លើសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតនេះ របស់ស្រុកពញាឮ ៖ ០៣ ព.ញ.ប.ក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។

## សៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត (នៅសាលាឃុំ សង្កាត់)

| លេខរៀង | ថ្ងៃ ខែ ឆ្នាំ ចេញសេចក្តីចម្លង | ចម្លងសំបុត្រ កំណើត ឬសំបុត្រ បញ្ជាក់កំណើត | សៀវភៅ | | សំបុត្រ | | អ្នកកើត | | | | នាមត្រកូល និង នាមខ្លួនឪពុក ម្តាយអ្នកកើត | អ្នកសុំចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | | | | មន្ត្រីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃ ខែ ឆ្នាំ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំកំណើត | | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹង អ្នកកើត | ស្នាមមេដៃ ស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួន សន្លឹកចម្លង | សេចក្តី ផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២* | *ចម្លងសំបុត្រ កំណើត* | *០១/ ២០១២* | *គោក ត្រប់* | *២៥* | *ថ្ងៃទី១២ ខែមករា ឆ្នាំ២០១២* | *សម សិទ្ធី* | *ប្រុស* | *ខ្មែរ* | *ថ្ងៃច័ន្ទ ទី០៥ ខែមករា ឆ្នាំ២០១២* | *សម សោភ័ណ<br>គុណ រតនា* | *សម សោភ័ណ* | *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ឪពុក បង្កើត* | | *មោក ស៊ីម* | *មេឃុំ* | *១០ សន្លឹក* | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

## សៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត (នៅសាលាឃុំក្រុង ស្រុក ខណ្ឌ)

| លេខរៀង | ថ្ងៃ ខែ ឆ្នាំ ចេញសេចក្តីចម្លង | ចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | សៀវភៅ | | សំបុត្រ | | អ្នកកើត | | | | នាមត្រកូល និង នាមខ្លួនឪពុកម្តាយអ្នកកើត | អ្នកសុំចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | | | | មន្ត្រីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃ ខែ ឆ្នាំ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំកំណើត | | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកកើត | ស្នាមមេដៃស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២* | *ចម្លងសំបុត្របញ្ជាក់កំណើត* | *០១/ ២០១១* | *ព្រែកព្នៅ* | *១០* | *ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១* | *យឹម សុផល* | *ប្រុស* | *ខ្មែរ* | *ថ្ងៃសុក្រ ទី២៥ ខែសីហា ឆ្នាំ១៩៦៩* | *យឹម ដួង* <br> *នូ ផល្លា* | *យឹម សុផល* | *ភូមិដូង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *សាមីខ្លួន* | | *នៅ ណាត* | *ប្រធានការិយាល័យរដ្ឋបាលទូទៅ* | *១៥ សន្លឹក* | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

## ២.៤.២. របៀបសរសេរសេចក្តីចម្លងសំបុត្រកំណើត និងសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត

☞ នៅពេលការសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និង សៀវភៅចម្លងសំបុត្របញ្ជាក់កំណើតចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវសរសេរសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។

☞ របៀបសរសេរសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត អនុវត្តដូចគ្នានឹងការសរសេរសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើមដែរ។

☞ ចំពោះការសុំចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវមានការបញ្ជាក់មួយចំនួន ដូចខាងក្រោម ៖

| |
|---|
| លេខ (ក)...................... |
| យើង(ខ)............................................................ |
| បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា |
| របស់លោក (គ)............................. ជាមន្ត្រីរក្សាសៀវភៅ |
| អត្រានុកូលដ្ឋាន(ឃ)..............................ពិតប្រាកដមែន។ |
| (ង) ធ្វើនៅ.................. ថ្ងៃទី........ ខែ............ ឆ្នាំ....... |
| (ច) ហត្ថលេខា និងត្រា |

ក). លេខ ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពី០១ រហូតដល់ដំណាច់ឆ្នាំ។ នៅឆ្នាំថ្មីត្រូវអនុវត្តចុះលេខថ្មី ចាប់ពីលេខ០១ ដដែល។ នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានសៀវភៅចុះលេខចេញដោយឡែក សម្រាប់សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន។

ខ). ត្រូវសរសេរ “អភិបាលក្រុង ស្រុក ខណ្ឌ.......(ឈ្មោះក្រុង ស្រុក ខណ្ឌ).......”។

គ). ឈ្មោះមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន។

ឃ). ត្រូវសរសេរ “ក្រុង ស្រុក ខណ្ឌ...........(ឈ្មោះក្រុង ស្រុក ខណ្ឌ)..........”។

ង). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ ត្រូវសរសេរឈ្មោះក្រុង ស្រុក ខណ្ឌ និងចុះថ្ងៃទី ជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរតាម គ្រិស្តសករាជ។

ច). ហត្ថលេខា និងត្រា ៖ ហត្ថលេខារបស់អភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** (១) ---- *កណ្ដាល* ------
**ស្រុក ខណ្ឌ** (២) ---- *កណ្ដាលស្ទឹង* ---
**ឃុំ សង្កាត់** (៣) ---- *គោកត្រប់* -----

## សេចក្ដីចម្លងសំបុត្រកំណើត

| ចម្លងសំបុត្រកំណើតចេញពី | | (៤) សៀវភៅកំណើត លេខ ៖ *០១/២០១២* | (៥) សំបុត្រកំណើត លេខ *២៥* ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ | |
|---|---|---|---|---|
| នាមត្រកូល (៦) | | *សម* | | ភេទ (៨) |
| នាមខ្លួនទារក (៧) | | *សិទ្ធី* | | *ប្រុស* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAM | | |
| | នាមខ្លួនទារក | SITHY | | |
| សញ្ជាតិ (១០) | | *ខ្មែរ* | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២* | | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | .... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ...................................................................... | | |

| **ឪពុក ម្ដាយទារក** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៣) | *សម សោភ័ណ* | *គុណ រតនា* |
| ជាអក្សរឡាតាំង (១៤) | SAM SORPHORN | KUN RATANA |
| សញ្ជាតិ (១៥) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៦) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* |
| ទីកន្លែងកំណើត (១៧) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | .....*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា*....... | ......*ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា*...... |
| ទីលំនៅពេលទារកកើត (១៨) | *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* |

(១៩) ធ្វើនៅ.... *គោកត្រប់* ..... ថ្ងៃទី *០១* ខែ *មីនា* ឆ្នាំ *២០១២*

(២០) **មន្ត្រីអត្រានុកូលដ្ឋាន**-----

**មេឃុំ**

(២១) *ហត្ថលេខា និងត្រា*

*ទ្រី ហៀង*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** (១) ---- *កណ្តាល* ------
**ស្រុក ខណ្ឌ** (២) ---- *ពញាឮ* -------
**ឃុំ សង្កាត់** (៣) --------------------

# សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត

| ចម្លងសំបុត្របញ្ជាក់កំណើតចេញពី | | (៤) សៀវភៅបញ្ជាក់កំណើត<br>លេខ ៖ *០១/២០១១* | (៥) សំបុត្របញ្ជាក់កំណើត<br>លេខ *១០* ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ |
|---|---|---|---|
| នាមត្រកូល (៦) | | *យឹម* | ភេទ (៨) |
| នាមខ្លួនអ្នកកើត (៧) | | *សុផល* | *ប្រុស* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | *YIM* | |
| | នាមខ្លួនអ្នកកើត | *SOPHAL* | |
| សញ្ជាតិ (១០) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃ សុក្រ ទី ២៥ ខែ សីហា ឆ្នាំ១៩៦៩* | |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | ...... *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល ប្រទេសកម្ពុជា* ..........<br>...................................................................................................... | |

| **ឪពុក ម្តាយ** | **ឪពុក** | **ម្តាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៣) | *យឹម ដួង* | *នូ ផល្លា* |
| ជាអក្សរឡាតាំង (១៤) | *YIM DUONG* | *NOU PHALLA* |
| សញ្ជាតិ (១៥) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៦) | *ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៣៩* | *ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៤៣* |
| ទីកន្លែងកំណើត (១៧)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | *ភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រទេសកម្ពុជា* | *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល ប្រទេសកម្ពុជា* |

លេខ (ក)..... *០៣ ព.ញ.ប.ក* ............
យើង (ខ).... *អភិបាលស្រុកពញាឮ* ................................
បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្តាំនេះ ជាហត្ថលេខា
របស់លោក (គ)... *នៅ ណាត*............ ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន (ឃ).......ស្រុកពញាឮ.......ពិតប្រាកដមែន ។
(ង) ធ្វើនៅ...ពញាឮ ..... ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២
(ច) *ហត្ថលេខា និងត្រា*
*ទេព សុធីរ*

(២៤) ធ្វើនៅ...ពញាឮ.... ថ្ងៃទី១៤ ខែ *មករា* ឆ្នាំ២០១២
(២៥) **មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**--
*ហត្ថលេខា*
*នៅ ណាត*

### ២.៤.៣. សេចក្តីសម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត

☞ សម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានកំណើត និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារតាមសំណើរបស់អ្នកមកសុំស្រង់ប៉ុណ្ណោះ ។

# ជំពូកទី៣

# អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

# ជំពូកទី៣
# អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

## ៣.១. សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

### ៣.១.១. និយមន័យ

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកដែលធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។

អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ត្រូវធ្វើដោយផ្អែកតាមនីតិវិធី ដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិស្ដីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

**បញ្ជាក់ ÷** ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី មិនមែនជាការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ទេ។ នៅក្នុងឯកសារនេះ ការប្រើពាក្យថា “អាពាហ៍ពិពាហ៍” មានន័យថា “អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ឬការចុះបញ្ជីអាពាហ៍ពិពាហ៍” នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

### ៣.១.២. ប្រភេទនៃការរៀបអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍មាន ៤ប្រភេទ ដូចខាងក្រោម ៖

- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនបរទេសដែលរស់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជា
- ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលកំពុងរស់នៅស្របច្បាប់ឯបរទេស។

### ៣.១.៣. លក្ខខណ្ឌដែលអាចរៀបអាពាហ៍ពិពាហ៍បាន

- បុរស នារីត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើង
- បុរស និងនារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ ។
- ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ៥(ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មត់ថាជាសន្តតិជនអច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណា-

ព្យាបាល ឪពុក ម្តាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

- បញ្ញត្តិនៃចំណុចខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះបានកន្លងផុតទៅ ។
- ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះបានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេង ហើយអាពាហ៍ពិពាហ៍មុនត្រូវរលាយដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ ។

### ៣.១.៤. លំនាំខណ្ឌដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន

- បុគ្គលមានភេទដូចគ្នា
- ជនវិកលចរិក មិនដឹងខុសត្រូវ
- បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ
- បុគ្គលដែលជាប់ចំណងសាច់ញាតិលោហិត (ញាតិដែលមានឈាមជាមួយគ្នា) ឬញាតិពន្ធ (សាច់ថ្លៃ) ក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះជាចំណងនោះមានខាន់ស្លា ឬគតខាន់ស្លា ឬសាច់ញាតិចិញ្ចឹម ។

ឧទាហរណ៍ ៖

- ឪពុក ម្តាយ និងកូន (ថ្នាក់ទី១) បងប្អូនបង្កើត (ថ្នាក់ទី២) មា មីង និងក្មួយ (ថ្នាក់ទី៣) មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ។
- ឪពុក ម្តាយ និងកូនប្រសារ (សាខាញាតិពន្ធថ្នាក់ទី១) បងប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី២) មា មីង និងក្មួយប្រសារ (សាខាញាតិពន្ធថ្នាក់ទី៣) អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានតាមផ្លូវច្បាប់ ប្រសិនបើសហព័ទ្ធណាមួយស្លាប់ ។

## ៣.២. សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍

### ៣.២.១. សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍

សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍ រួមមាន ៖

- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២-២០០៧)

### ៣.២.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍ រួមមាន ៖

- សំបុត្រអាពាហ៍ពិពាហ៍

- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២-២០០៧)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (សំរាប់ចម្លងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ)

## ៣.៣. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍

☞ បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅឋានសាមីខ្លួនខាងនារី ។

☞ បុរស នារីដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ ឬបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី រួចហើយ ប៉ុន្តែពុំទាន់បានសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យការរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ មានលក្ខណៈជាប្តីប្រពន្ធពេញច្បាប់ ឬការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈពេញច្បាប់ សាមីខ្លួនទាំងពីររូប ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់សាមី នៃលំនៅឋានដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ។

☞ បុរស នារី ដែលមកសុំច្បាប់រៀបអាពាហ៍ពិពាហ៍ ត្រូវភ្ជាប់មកជាមួយនូវ ៖

- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ។
- លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ របស់សាមីខ្លួនទាំង២នាក់ ។ លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយទាំងពីរនាក់ ត្រូវចេញដោយមេឃុំ ចៅសង្កាត់សាមី ។
  - បើក្នុងករណីមេម៉ាយ ឬពោះម៉ាយ ដោយប្តី ឬប្រពន្ធស្លាប់ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព ។
  - បើក្នុងករណីមេម៉ាយ ឬពោះម៉ាយដោយលែងលះ ត្រូវភ្ជាប់មកជាមួយនូវសាលក្រមតុលាការ ។
- សៀវភៅគ្រួសារ ដែលមានទិន្នន័យរបស់សាមីខ្លួនទាំងពីរនាក់ច្បាស់លាស់ និងត្រឹមត្រូវ ។

☞ នៅពេលទទួលបានពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យឱ្យបានហ្មត់ចត់ ចំពោះបុរស នារីដែលបានដាក់ពាក្យសុំនោះ ៖

- បើពិនិត្យទៅឃើញថា មិនមានលក្ខណៈត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានទេ មន្ត្រីអត្រានុកូលដ្ឋានមិនអាចអនុញ្ញាតឱ្យបុរសនារីនោះរៀបអាពាហ៍ពិពាហ៍បានឡើយ ។
- បើពិនិត្យទៅឃើញថា មានលក្ខណៈត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រា-នុកូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណ ប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈចំនួន ០៥ច្បាប់ ដូចខាងក្រោម ៖
  - ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅលំនៅឋានសាមីខ្លួននារី
  - ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
  - ០១ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី

– ០២ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយជាសាធារណៈ នៅលំនៅឋានសាមីខ្លួនបុរស០១ច្បាប់ និងនៅសាលាឃុំ ឬសង្កាត់សាមីខ្លួនបុរស ០១ច្បាប់ ។

☞ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ។ ផុតរយៈពេល១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់ ។ បើមានបណ្តឹងទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បានលុះត្រាតែបណ្តឹងទាស់ត្រូវបានដោះស្រាយរួចរាល់តាមគោលការណ៍ដែលបានចែងក្នុងក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- នាមត្រកូល និងនាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្ន នៃអនាគតប្តី ឬប្រពន្ធ ។
- នាមត្រកូល និងនាមខ្លួន ថ្ងៃខែឆ្នាំកំណើត មុខរបរ និងទីលំនៅបច្ចុប្បន្នរបស់ឪពុក ម្តាយ នៃអនាគតប្តីប្រពន្ធ (បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ផង) ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ---------------------- ភេទ---------- សញ្ជាតិ---------- ឆ្នាំកំណើត------------ មុខរបរបច្ចុប្បន្ន-------------------------------------------------------- ស្ថានភាពផ្ទាល់ខ្លួន--------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ--------- ផ្លូវលេខ---------- ក្រុម---------- ភូមិ------------ ឃុំ សង្កាត់ ---------------- ក្រុង ស្រុក ខណ្ឌ----------------- រាជធានី ខេត្ត ------------------ ។ ឪពុកឈ្មោះ------------------ អាយុ------- ឆ្នាំ (រស់ ស្លាប់) ម្តាយឈ្មោះ----------------------អាយុ-------ឆ្នាំ (រស់ ស្លាប់) ។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់.......................................**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំរៀបអាពាហ៍ពិពាហ៍ ។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ---------------------ភេទ------ សញ្ជាតិ-----------ឆ្នាំកំណើត------------មុខរបរ-------------------------------------------------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុម--------- ភូមិ--------------ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------- រាជធានី ខេត្ត ------------------ ។

ខ្ញុំសូមអះអាងថា ខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់------------------------------ មេត្តាអនុញ្ញាត ឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី------- ខែ----------- ឆ្នាំ--------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃស្តាំសាមីខ្លួន**

– ------------------------------
– ------------------------------
– ------------------------------

ឈ្មោះ-----------

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំបញ្ជាក់

**ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ**

ខ្ញុំបាទ នាងខ្ញុំឈ្មោះ-------------------- ភេទ------- សញ្ជាតិ------- កើតនៅថ្ងៃ-------- ទី------ ខែ----------- ឆ្នាំ-------- នៅភូមិ------------------- ឃុំ សង្កាត់--------------------- ក្រុង ស្រុក ខណ្ឌ---------------- រាជធានី ខេត្ត ---------------- មុខរបរបច្ចុប្បន្ន--------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------- ផ្លូវលេខ-------- ក្រុម------ ភូមិ----------- ឃុំ សង្កាត់----------- ក្រុង ស្រុក ខណ្ឌ--------------- រាជធានី ខេត្ត --------------- ។

**គោរពជូន**

**មេឃុំ ចៅសង្កាត់-------------------------**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំលិខិតបញ្ជាក់ភាព----------------------------- ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមជម្រាបលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាជ្រាបថា បច្ចុប្បន្ន ខ្ញុំបាទ នាងខ្ញុំ មានស្ថានភាពផ្ទាល់ខ្លួន----------------------- ហើយមានបំណងរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ--------------- ភេទ---------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ------ ផ្លូវលេខ---------ក្រុម---------- ភូមិ------------------------ ឃុំ សង្កាត់---------------------- ក្រុង ស្រុក ខណ្ឌ------------------------- រាជធានី ខេត្ត ---------------------- ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់ មេត្តាចេញលិខិតបញ្ជាក់ឱ្យខ្ញុំបាទ នាងខ្ញុំ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន ដោយអនុគ្រោះ។

ដើម្បីជាសក្ខីភាពនៃការអះអាងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមផ្ដិតស្នាមមេដៃស្ដាំ ទុកជា ភស្តុតាង។

ធ្វើនៅថ្ងៃទី------ ខែ----------- ឆ្នាំ--------

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖

**ស្នាមមេដៃសាមីខ្លួន**

– -----------------------------

– --------------------------

ឈ្មោះ ------------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

4x6

រាជធានី ខេត្ត ៖----------------
ក្រុង ស្រុក ខណ្ឌ ៖----------------
ឃុំ សង្កាត់ ៖----------------
លេខ ៖----------------

ថ្ងៃទី------ ខែ---------- ឆ្នាំ-------

**លិខិតបញ្ជាក់**
**ភាពនៅលីវ ភាពពោះម៉ាយ ភាពមេម៉ាយ**

យោងពាក្យសុំបញ្ជាក់ភាព------ ចុះថ្ងៃទី------ ខែ---------- ឆ្នាំ-------- របស់------------------------។

**យើងមេឃុំ ចៅសង្កាត់**------------------------

សូមបញ្ជាក់ថា ឈ្មោះ------------------------ ភេទ------- កើតនៅថ្ងៃ------- ទី------- ខែ----------ឆ្នាំ--------- នៅភូមិ------------ ឃុំ សង្កាត់--------------- ក្រុង ស្រុក ខណ្ឌ-----------------រាជធានី ខេត្ត------------------- មុខរបរបច្ចុប្បន្ន----------------------------------ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ-------- ផ្លូវលេខ-------- ក្រុម------- ភូមិ--------------ឃុំ សង្កាត់-----------------ក្រុង ស្រុក ខណ្ឌ---------------------រាជធានី ខេត្ត----------------- មានស្ថានភាពផ្ទាល់ខ្លួនបច្ចុប្បន្ន ពិតជា-------------------ប្រាកដមែន។

លិខិតបញ្ជាក់នេះ ចេញឱ្យសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ក្នុងការសុំរៀបអាពាហ៍ពិពាហ៍។

(លិខិតបញ្ជាក់នេះ មានសុពលភាពរយៈពេល៣ខែ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ)

**មេឃុំ ចៅសង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** --------------------
**ស្រុក ខណ្ឌ** --------------------
**ឃុំ សង្កាត់** --------------------
**លេខ** --------------------

# ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | | |
| ជាអក្សរឡាតាំង | | |
| សញ្ជាតិ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| ទីកន្លែងកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| រយៈពេលប្តឹងជំទាស់ | | |
| នាមត្រកូល និងនាមខ្លួនឪពុក | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |
| នាមត្រកូល និងនាមខ្លួនម្តាយ | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | |
| មុខរបរបច្ចុប្បន្ន | | |
| ទីលំនៅបច្ចុប្បន្ន | | |

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី............. ខែ....................... ឆ្នាំ................ ។

ធ្វើនៅ....................... ថ្ងៃទី.......... ខែ................ ឆ្នាំ...........

**មន្ត្រីអត្រានុកូលដ្ឋាន**

## ៣.៤. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍

☞ ក្រោយរយៈពេល១០ថ្ងៃ នៃការបិទផ្សាយជាសាធារណៈ នូវប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និងប្រសិនបើគ្មានការប្ដឹងជំទាស់អំពីអាពាហ៍ពិពាហ៍នេះទេ សាមីខ្លួនទាំង២នាក់អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសុំសំបុត្រអាពាហ៍ពិពាហ៍ ដែលចាត់ទុកជាការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដោយនាំទៅជាមួយនូវសាក្សី ០២រូប ជានីតិជន។

☞ សាក្សីទាំង២រូប ត្រូវយកមកជាមួយនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន។

### ៣.៤.១. ការសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍

#### ក). ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ នៅក្នុងប្រទេស

☞ ប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ ត្រូវតែអនុវត្តទៅតាមក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន។

☞ មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ នៃលំនៅឋាននារី ជាអធិបតីនៃពិធីរៀបអាពាហ៍ពិពាហ៍នេះ។

☞ នៅពេលមានសាមីខ្លួនប្ដី ប្រពន្ធមកសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសុំសំបុត្រអាពាហ៍ពិពាហ៍ និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថា ត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន ០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុងនៅក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ភ្លោះ។

☞ របៀបសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ នៃសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ដែលបានចុះលេខ និងចុះឆ្នាំរួចហើយ មានដូចខាងក្រោម ៖

១). ខេត្ត ក្រុង ៖ ត្រូវសរសេរឈ្មោះរាជធានី ឬខេត្តសាមី។ បើខេត្តត្រូវឆូតចោល ពាក្យ “ក្រុង” បើរាជធានីត្រូវឆូតចោលពាក្យ “ខេត្ត ក្រុង” និងសរសេរបំពេញបន្ថែម ពាក្យ “រាជធានី”។

២). ស្រុក ខណ្ឌ ៖ ត្រូវសរសេរឈ្មោះក្រុង ឬស្រុក ឬខណ្ឌសាមី។ បើស្រុកត្រូវឆូតចោលពាក្យ “ខណ្ឌ” បើខណ្ឌត្រូវឆូតចោលពាក្យ “ស្រុក” បើក្រុងត្រូវឆូតចោលពាក្យ “ស្រុក ខណ្ឌ” និង សរសេរ បំពេញបន្ថែមពាក្យ “ក្រុង”។

៣). ឃុំ សង្កាត់ ៖ ត្រូវសរសេរឈ្មោះឃុំ ឬសង្កាត់របស់ខ្លួន។ បើឃុំត្រូវឆូតចោលពាក្យ “សង្កាត់” បើសង្កាត់ត្រូវឆូតចោលពាក្យ “ឃុំ”។

៤). លេខ ៖ ត្រូវសរសេរលេខបញ្ជីអាពាហ៍ពិពាហ៍។ លេខរៀងបញ្ជីអាពាហ៍ពិពាហ៍ ដែលត្រូវសរសេរចុះ គឺសរសេរ ២ខ្ទង់ ចាប់ផ្ដើមពីលេខ ០១ ដោយសរសេរជាលេខខ្មែរ។

៥). សៀវភៅអាពាហ៍ពិពាហ៍លេខ៖ ត្រូវសរសេរលេខសៀវភៅដូចលេខដែលចុះនៅក្របមុខ នៃសៀវភៅអាពាហ៍ពិពាហ៍ដែលកំពុងសរសេរ។

៦). ឆ្នាំ ៖ ត្រូវសរសេរដូចឆ្នាំដែលចុះនៅក្របមុខនៃសៀវភៅអាពាហ៍ពិពាហ៍ដែលកំពុងសរសេរ។

៧). នាមត្រកូល ៖ ត្រូវសរសេរនាមត្រកូលរបស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធសរសេរនៅក្រោម

ផ្នែកប្រពន្ធ។

បញ្ជាក់ ៖ បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន នៅត្រង់ខ្ទង់ "នាមត្រកូល" ទុកចំហចោល ដូច្នេះនៅត្រង់ខ្ទង់ "នាមត្រកូល" នៃបញ្ជីអាពិហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ ក៏ត្រូវទុកចំហចោលដែរ។

៨). នាមខ្លួន ៖ ត្រូវសរសេរនាមខ្លួនរបស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។

៩). នាមត្រកូល និងនាមខ្លួន ជាអក្សរឡាតាំង ៖ ត្រូវសរសេរជាអក្សរឡាតាំងប្រកបឱ្យត្រូវសម្លេងតាមអក្សរខ្មែរ នៃនាមត្រកូល និងនាមខ្លួនរបស់ប្ដី ចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធ ចូលក្រោមផ្នែកប្រពន្ធ។ ក្នុងករណីមិនចេះសរសេរជាអក្សរឡាតាំង អាចទុកចោលទំនេរបាន។

១០). **សញ្ជាតិ** ៖ ត្រូវសរសេរសញ្ជាតិរបស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ

១១). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ ក្នុងការសរសេរថ្ងៃ ខែ ឆ្នាំកំណើត ត្រូវសរសេរឈ្មោះថ្ងៃជាអក្សរខ្មែរ ទីជាលេខខ្មែរ ខែជាអក្សរខ្មែរ តាមសុរិយគតិ និងឆ្នាំជាលេខខ្មែរ តាមគ្រិស្តសករាជ។

**ឧទាហរណ៍** ÷ ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣។

១២). ទីកន្លែងកំណើត ៖ ត្រូវសរសេរឈ្មោះភូមិ ឃុំ ឬ សង្កាត់ ក្រុង ឬ ស្រុក ឬ ខណ្ឌ រាជធានី ឬ ខេត្ត ប្រទេស របស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។

១៣). មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ៖ ត្រូវសរសេរមុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍របស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។

១៤). ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ៖ ត្រូវសរសេរទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ របស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។ទីលំនៅត្រូវចុះលេខផ្ទះលេខផ្លូវ(បើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និងប្រទេស។

១៥). លេខអត្តសញ្ញាណប័ណ្ណ ៖ ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណរបស់ប្ដីចូលក្រោមផ្នែកប្ដី និងរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។ ក្នុងករណីមិនទាន់មានអត្តសញ្ញាណប័ណ្ណ ត្រូវទុកខ្ទង់នេះឱ្យនៅទំនេរ ពេលមានអត្តសញ្ញាណប័ណ្ណ សាមីខ្លួនអាចមកស្នើសុំចុះជាក្រោយបាន។

១៦). ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី ៖ ត្រូវសរសេរចូលចំនួនលើកទីប៉ុន្មានជាអក្សរ ដែលប្ដី ឬប្រពន្ធបានចុះសៀវភៅអាពាហ៍ពិពាហ៍។

ឧទាហរណ៍ ៖ បើប្ដីរៀបអាពាហ៍ពិពាហ៍លើកទីពីរ (ប្រពន្ធមុនស្លាប់ ឬលែងលះគ្នា) ត្រូវសរសេរ "ពីរ" ក្រោមផ្នែកប្ដី បើប្រពន្ធទើបរៀបអាពាហ៍ពិពាហ៍លើកទីមួយ ត្រូវសរសេរ "មួយ" នៅក្រោមផ្នែកប្រពន្ធ។

១៧). ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ៖ ត្រូវសរសេរថ្ងៃជាអក្សរ ទីជាលេខខ្មែរ ខែជាអក្សរតាមសុរិយគតិ ឆ្នាំជាលេខតាមគ្រិស្តសករាជ ។ **ឧទាហរណ៍:** ថ្ងៃច័ន្ទ ទី១៩ ខែកុម្ភៈ ឆ្នាំ២០១២។

១៨). ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ៖ ត្រូវសរសេរឈ្មោះសាលាឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ

រាជធានី ឬខេត្ត ដែលសាមីខ្លួនប្តី ប្រពន្ធទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍។

**ឧទាហរណ៍** ÷ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

១៩). លេខ និង ថ្ងៃ ខែ ឆ្នាំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍៖ ត្រូវសរសេរលេខប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និង ថ្ងៃទី ជាលេខ ខែជាអក្សរ និង ឆ្នាំជាលេខ។

**ឧទាហរណ៍** ÷ លេខ ០៩ ប.ខ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០១២។

**អំពីឪពុក** (ចែកជាពីរផ្នែក ៖ ផ្នែកខាងប្តី និងផ្នែកខាងប្រពន្ធ)។

**បញ្ជាក់** ៖

- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពុំមានសរសេរអ្វីនៅផ្នែកឪពុក ដូច្នេះ នៅផ្នែកឪពុកនៃបញ្ជីអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ ក៏ត្រូវទុកឱ្យនៅទំនេរដែរ (មិនសរសេរអ្វីទាំងអស់)។
- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនសរសេរ “មិនស្គាល់” នៅផ្នែកឪពុក ដូច្នេះនៅផ្នែកឪពុកនៃបញ្ជីអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ក៏ត្រូវសរសេរ “មិនស្គាល់” ដែរ។

២០). នាមត្រកូល និងនាមខ្លួនឪពុក ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនឪពុករបស់ប្តីចូលក្រោមផ្នែកប្តី និងឪពុករបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។

២១). សញ្ជាតិ៖ ត្រូវសរសេរសញ្ជាតិឪពុករបស់ប្តីចូលក្រោមផ្នែកប្តី និងឪពុករបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។

២២). នាមត្រកូល និងនាមខ្លួនឪពុកជាអក្សរឡាតាំង ៖ ត្រូវសរសេរជាអក្សរឡាតាំងនូវនាមត្រកូល និងនាមខ្លួនឪពុករបស់ប្តីចូលក្រោមផ្នែកប្តី និងឪពុករបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ។ ក្នុងករណីពុំអាច សរសេរជាអក្សរឡាតាំងបាន អាចទុកចោលឱ្យនៅទំនេរដោយពុំចាំបាច់សរសេរក៏បាន។

២៣). រស់ ឬស្លាប់ ៖ បើនៅរស់ ត្រូវឆូតចោលពាក្យ “ស្លាប់” បើស្លាប់ត្រូវឆូតចោលពាក្យ “រស់”។

២៤). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតឪពុករបស់ប្តីចូលក្រោមផ្នែកប្តី និងឪពុករបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ ។ **ឧទាហរណ៍** ÷ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៤៨។

**បញ្ជាក់** ÷ ក្នុងករណីឪពុក ឬម្តាយមិនចាំថ្ងៃខែកំណើត ហើយចាំតែឆ្នាំកំណើត មន្ត្រីអត្រានុកូលដ្ឋានអាចចុះតែឆ្នាំកំណើតក៏បាន។ ក្នុងករណីដែលមិនចាំឆ្នាំកំណើតមន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះជាមួយនឹងឪពុក ម្តាយ ឬកូនរបស់ឪពុក ម្តាយនោះដើម្បីប៉ាន់ស្មានអាយុ ករណីនេះអាចចុះអាយុ ឬចុះតែឆ្នាំកំណើតក៏បាន។

២៥). មុខរបរបច្ចុប្បន្ន ៖ ត្រូវសរសេរមុខរបរបច្ចុប្បន្ន នៃឪពុករបស់ប្តីចូលក្រោមផ្នែកប្តី និងឪពុករបស់ប្រពន្ធ ចូលក្រោមផ្នែកប្រពន្ធ។

២៦). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរលេខផ្ទះ លេខផ្លូវ(បើមាន) ឈ្មោះភូមិ ឃុំឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត នៃឪពុករបស់ប្តីចូលក្រោមផ្នែកប្តី និងឪពុករបស់ប្រពន្ធ ចូលក្រោមផ្នែកប្រពន្ធ។

**អំពីម្តាយ** (ចែកជាពីរផ្នែក ៖ ផ្នែកខាងប្តី និងផ្នែកខាងប្រពន្ធ) ។

- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ពុំមានសរសេរអ្វី នៅផ្នែកម្តាយ ដូច្នេះ នៅផ្នែកម្តាយនៃបញ្ជីអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ ក៏ត្រូវទុកឱ្យនៅទំនេរដែរ (មិនសរសេរអ្វីទាំងអស់) ។
- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនសរសេរ "មិនស្គាល់" នៅផ្នែកម្តាយ ដូច្នេះ នៅផ្នែកម្តាយនៃបញ្ជីអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ ក៏ត្រូវសរសេរ "មិនស្គាល់" ដែរ ។

២៧). នាមត្រកូល និងនាមខ្លួនម្តាយ ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនម្តាយរបស់ប្តីចូលក្រោមផ្នែកប្តី និងម្តាយរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ ។

២៨). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិម្តាយរបស់ប្តីចូលក្រោមផ្នែកប្តី និងម្តាយរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ ។

២៩). នាមត្រកូល និងនាមខ្លួនម្តាយជាអក្សរឡាតាំង ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនម្តាយរបស់ប្តីជាអក្សរឡាតាំងចូលក្រោមផ្នែកប្តី និងម្តាយរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ ។ ក្នុងករណីពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកចោលឱ្យនៅទំនេរ ដោយពុំចាំបាច់សរសេរក៏បាន ។

៣០). រស់ ឬស្លាប់ ៖ បើនៅរស់ ត្រូវឆូតចោលពាក្យ "ស្លាប់" បើស្លាប់ត្រូវឆូតចោលពាក្យ "រស់" ។

៣១). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតម្តាយរបស់ប្តីចូលក្រោមផ្នែកប្តី និងម្តាយរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ ។ (មើលការណែនាំចំណុច២៤ ថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុក) ។

៣២). មុខរបរបច្ចុប្បន្ន ៖ ត្រូវសរសេរមុខរបរបច្ចុប្បន្ននៃម្តាយរបស់ប្តីចូលក្រោមផ្នែកប្តី និងម្តាយរបស់ប្រពន្ធចូលក្រោមផ្នែកប្រពន្ធ ។

៣៣). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរលេខផ្ទះ លេខផ្លូវ(បើមាន) ឈ្មោះភូមិ ឃុំឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត នៃម្តាយរបស់ប្តីចូលក្រោមផ្នែកប្តី និងម្តាយរបស់ប្រពន្ធចូល ក្រោមផ្នែកប្រពន្ធ ។

**អំពីសាក្សី** (ចែកជាពីរផ្នែក ៖ ផ្នែកទី១ សម្រាប់សាក្សីម្នាក់ និងផ្នែកទី២ សម្រាប់សាក្សីម្នាក់ទៀត)

៣៤). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនរបស់សាក្សី១នាក់ ចូលក្រោមផ្នែកមួយ និងសាក្សី១នាក់ទៀតចូលក្រោមផ្នែកមួយទៀត ។

៣៥). ភេទ ៖ ត្រូវសរសេរភេទរបស់សាក្សី១នាក់ ចូលក្រោមផ្នែកមួយ និងសាក្សី១នាក់ទៀតចូលក្រោមផ្នែកមួយទៀត ។

៣៦). សញ្ជាតិៈ ត្រូវសរសេរសញ្ជាតិរបស់សាក្សី១នាក់ ចូលក្រោមផ្នែកមួយ និងរបស់សាក្សី១នាក់ទៀតចូលក្រោមផ្នែកមួយទៀត ។

៣៧). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់សាក្សី១នាក់ ចូលក្រោមផ្នែកមួយ និងរបស់សាក្សី ១នាក់ទៀតចូលក្រោមផ្នែកមួយទៀត ។

៣៨). មុខរបរបច្ចុប្បន្ន ៖ ត្រូវសរសេរមុខរបរបច្ចុប្បន្នរបស់សាក្សី១នាក់ ចូលក្រោមផ្នែកមួយ និងរបស់សាក្សី១នាក់ទៀត ចូលក្រោមផ្នែកមួយទៀត ។

៣៩). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរទីលំនៅបច្ចុប្បន្ន មានលេខផ្ទះ លេខផ្លូវ (បើមាន) ឈ្មោះ ភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្តរបស់សាក្សី១នាក់ ចូលក្រោមផ្នែកមួយ និងរបស់សាក្សី ១នាក់ទៀត ចូលក្រោមផ្នែកមួយទៀត ។

៤០). លេខអត្តសញ្ញាណប័ណ្ណ ៖ ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណរបស់សាក្សី១នាក់ ចូលក្រោមផ្នែកមួយ និងរបស់សាក្សី១នាក់ទៀតចូលក្រោមផ្នែកមួយទៀត (ការណែនាំដូចចំណុច ១៥) ។

**បញ្ជាក់** ÷ ពេលសរសេរបំពេញក្នុងខ្ទង់ខាងលើនេះចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យសាមីខ្លួនពិនិត្យមើល បើសិនជាសាមីខ្លួនចេះអក្សរ ប៉ុន្តែបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីអត្រានុកូលដ្ឋានត្រូវអានឱ្យសាមីខ្លួនជាប្តី ប្រពន្ធ និងសាក្សីទាំងពីរនាក់ស្តាប់គ្រប់ចំណុចទាំងអស់ បើឃើញថាត្រឹមត្រូវ និងឯកភាពហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុវត្តបន្តដូចខាងក្រោម ៖

៤១). ស្នាមមេដៃស្តាំរបស់ប្តី ប្រពន្ធ សាក្សី សាក្សី ៖ ត្រូវផ្តិតមេដៃស្តាំរបស់ប្តី របស់ប្រពន្ធ របស់សាក្សីម្នាក់ៗនៅពីក្រោម និងសរសេរនាមត្រកូល និងនាមខ្លួនពីក្រោមស្នាមមេដៃរបស់ខ្លួន ។

៤២). ធ្វើនៅ------ ថ្ងៃទី--- ខែ----- ឆ្នាំ---- ៖ ត្រូវសរសេរឈ្មោះនៃឃុំ ឬសង្កាត់ទីកន្លែងដែលធ្វើអត្រានុកូលដ្ឋាន និងចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ និងឆ្នាំជាលេខខ្មែរ តាមគ្រិស្តសករាជ ។ **ឧទាហរណ៍** ÷ ធ្វើនៅបាក់ខែង ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ ។

៤៣). មន្ត្រីអត្រានុកូលដ្ឋាន ៖ ត្រូវសរសេរពីក្រោមពាក្យមន្ត្រីអត្រានុកូលដ្ឋានថា “មេឃុំ” ឬ“ចៅ សង្កាត់” ។ បើមេឃុំ ឬចៅសង្កាត់អវត្តមានជំទប់ ចៅសង្កាត់រង នឹងទទួលសិទ្ធិតាមឋានានុក្រម តាមរយៈលិខិតប្រគល់សិទ្ធិជាលាយល័ក្ខណ៍អក្សរពីមេឃុំ ចៅសង្កាត់ ។ ក្នុងករណីនេះ ត្រូវសរសេរ ពីក្រោមពាក្យ “មន្ត្រីអត្រានុកូលដ្ឋាន” ដាក់ថា “មេឃុំស្តីទី” ឬ “ចៅសង្កាត់ស្តីទី” ។

៤៤). ហត្ថលេខា និងត្រា ៖ ត្រូវចុះហត្ថលេខាមន្ត្រីអត្រានុកូលដ្ឋានក្រោមឋានៈនាទី សរសេរនាមត្រកូល និងនាមខ្លួន ឬបោះត្រាឈ្មោះអ្នកចុះហត្ថលេខា ពីក្រោមហត្ថលេខា រួចបោះត្រាឃុំ ឬ សង្កាត់ ពីលើផ្នែកខាងឆ្វេងមួយភាគបីនៃហត្ថលេខា និងបោះត្រាឱ្យត្រង់តួអក្សរ (ត្រាប្រើទឹក ពណ៌ក្រហម) ។

### ខ). ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅក្នុងប្រទេសកម្ពុជា

ត្រូវចាត់ទុកជាជនបរទេស គឺជនណាដែលគ្មានសញ្ជាតិជាខ្មែរ ទោះបីជនទោះស្ថិតនៅក្រៅប្រទេសកម្ពុជាក្តី ឬកំពុងស្ថិតនៅ ឬ ស្នាក់នៅក្នុងប្រទេសកម្ពុជាក្តី ។

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ។ ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេស ហើយក្រសួងការបរទេស និងសហប្រតិ

បត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យចុះបញ្ជីរួចជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

**+ សំណុំឯកសារជនបរទេសមាន ៖**

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារីទំហំ ៤x៦ ថតចំពីមុខក្នុងរយៈពេល ០៣ខែ ចុងក្រោយ
- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេស និងមានទិដ្ឋាការចូលប្រទេសកម្ពុជាដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- សៀវភៅការងារចំពោះសាមីខ្លួនជនបរទេស ដែលប្រកបមុខរបរធ្វើអាជីវកម្ម ឬ ពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងឯកសារបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់នីត្យានុកូលភាព ពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**+ សំណុំឯកសារពលរដ្ឋខ្មែរមាន ៖**

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារីទំហំ ៤x៦ ថតចំពីមុខក្នុងរយៈពេល ០៣ខែចុងក្រោយ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ដែលមានចុះបញ្ជីច្បាស់លាស់ និងត្រឹមត្រូវ
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ចៅសង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដែលនៅមានសុពលភាព (ករណី ពោះម៉ាយ ឬ មេម៉ាយ ដោយប្រពន្ធ ឬប្តីស្លាប់ ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយ ឬ មេម៉ាយ ដោយលែងលះ ត្រូវមានសាលក្រមស្ថាពរពីតុលាការ) ។
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- សៀវភៅគ្រួសារដែលមានទិន្នន័យច្បាស់លាស់ និងត្រឹមត្រូវ ។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងការអនុវត្តបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដូចខាងក្រោម ៖

**១-អំពីភារកិច្ច ៖**

**ក-ថ្នាក់ក្រសួង ៖**

នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួងលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន និងមានភារកិច្ច ៖

- ចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសដែលផ្ញើមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ថតចម្លងឯកសារសាមីខ្លួនជនបរទេសបញ្ជូនទៅអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ដើម្បីសហការផ្តល់ព័ត៌មានពីអត្តសញ្ញាណជនបរទេសនោះ
- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ទៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាមី និងមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ និងជូនដំណឹងព្រមទាំងប្រគល់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅសាមីខ្លួនពលរដ្ឋខ្មែរ និងជនបរទេស ក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ ដើម្បីសាមីខ្លួនដាក់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។
- ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់ពលរដ្ឋខ្មែរ ។

**ខ-ថ្នាក់រាជធានី ខេត្ត ៖**

អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅរាជធានី ខេត្តរបស់ខ្លួនដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃសាលារាជធានី ខេត្ត ជាសេនាធិការ និងមានភារកិច្ចដូចខាងក្រោម ៖

- គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាន នៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ផ្សព្វផ្សាយ និងចលនាឱ្យមន្ទីរពាក់ព័ន្ធនានាជុំវិញរាជធានី ខេត្ត សហការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផ្ញើមកក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) នៅរៀងរាល់ថ្ងៃទី១៥ នៃខែបន្ទាប់ ។

**គ-ថ្នាក់ក្រុង ស្រុក ខណ្ឌ ៖**

អភិបាលក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម ៖

- គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាន នៅឃុំ សង្កាត់
- ផ្សព្វផ្សាយ និងចលនាឱ្យការិយាល័យពាក់ព័ន្ធនានាជុំវិញ ក្រុង ស្រុក ខណ្ឌ សហការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់
- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ផ្ញើមករាជធានី ខេត្តនៅរៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ ។

**ឃ-ថ្នាក់ឃុំ សង្កាត់ ៖**

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋាននៅក្នុងដែនដីឃុំ សង្កាត់ដែលខ្លួនគ្រប់គ្រង។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីទទួលបាននូវសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃ ស្តីពីការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស ជាមួយពលរដ្ឋខ្មែរ និងបន្ទាប់ពីបានទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ ពីសា-មីខ្លួនជនបរទេស និងពីសាមីខ្លួនពលរដ្ឋខ្មែររួចហើយ មានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យ និងសម្រេចលើសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស និងរបស់ពលរដ្ឋខ្មែរ យ៉ាងយូរក្នុងរយៈពេល ០៣ថ្ងៃ ការងារ។ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាជនបរទេស និងរបស់ពលរដ្ឋខ្មែរ ត្រូវដាក់ស្របពេលជាមួយគ្នាទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានអចិ-ន្ត្រៃយ៍របស់ពលរដ្ឋខ្មែរ។
- បើពិនិត្យឃើញឯកសារខាងលើមានលក្ខណៈត្រឹមត្រូវស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីអត្រានុ-កូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋានដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី ត្រូវចេញប័ណ្ណប្រកាសចំនួន ០៩ច្បាប់ ដោយមានបិទរូបថតសាមីខ្លួនបុរស និងនារីទំហំ ៤ x ៦ ថត ចំពីមុខក្នុងរយៈពេល ០៣ខែចុងក្រោយ នៅខាងលើផ្នែកខាងស្តាំសម្រាប់ប្រើប្រាស់ដូចខាងក្រោម ៖
- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់ នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅរបស់សាមីខ្លួនជនបរទេស (ករណីជនបរទេសនោះមានលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា) ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយរយៈពេល១០ថ្ងៃ នៅទីកន្លែងដូចបានកំណត់ខាងលើ ។ ផុតរយៈពេល១០ថ្ងៃ ប្រសិនបើគ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន។ អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែ សាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន

នៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

- មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីចុះបញ្ជីអាពាហ៍ពិពាហ៍តាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋានហើយ ត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ០១សន្លឹក និងចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍តាមការស្នើសុំរបស់សាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ ។
- ផ្ញើរបាយការណ៍ជាបន្ទាន់ ផ្ញើមកក្រសួងមហាផ្ទៃ តាមរយៈក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត បន្ទាប់ពីបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនីមួយៗរួចហើយ ដោយបញ្ជាក់អំពីលេខបញ្ជីលេខសៀវភៅ ថ្ងៃ ខែ ឆ្នាំចុះបញ្ជីឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងសញ្ជាតិ របស់សាមីខ្លួនបុរស និងសាមីខ្លួននារី ។
- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ផ្ញើមកសាលាក្រុង ស្រុក ខណ្ឌ នៅរៀងរាល់ថ្ងៃទី ០៥ នៃខែបន្ទាប់ ។

**២-បំរាម និងការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីអត្រានុកូលដ្ឋាន ៖**

☞ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ មិនត្រូវអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយជនបរទេស ក្នុងករណីដូចខាងក្រោម ៖

ក-សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសពុំបានចុះបញ្ជី និងពុំបានជូនដំណឹងពីការសុំរៀបអាពាហ៍ពិពាហ៍ពីក្រសួងមហាផ្ទៃ

ខ-សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ឬ របស់សាមីខ្លួនពលរដ្ឋខ្មែរ ពុំបានបំពេញត្រឹមត្រូវតាមបែបបទ និងនីតិវិធីដែលបានកំណត់

គ-សាមីខ្លួនពលរដ្ឋខ្មែរពុំមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងឃុំ សង្កាត់ក្នុងដែនដីដែលខ្លួនគ្រប់គ្រង

ឃ-សាមីខ្លួនពលរដ្ឋខ្មែរ និងជនបរទេសពុំទាន់គ្រប់អាយុដែលច្បាប់អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍

ង-មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ហើយមិនបានដោះស្រាយឱ្យបានចប់សព្វគ្រប់។

☞ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវដូចខាងក្រោម ៖

-ត្រូវប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានដែលបោះពុម្ពតាមគំរូឯកភាពចេញដោយក្រសួងមហាផ្ទៃ និងអនុវត្តឱ្យបានត្រឹមត្រូវតាមបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន អំពីការចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ការចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ការចេញសំបុត្រអាពាហ៍ពិពាហ៍ និងការចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ។

-រាល់សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្រៅពីខ្ទង់សរសេរឈ្មោះជាអក្សរឡាតាំង គឺមិនអនុញ្ញាតឱ្យសរសេរភាសាបរទេសបញ្ចូលឡើយ ។

-រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទមិនអនុញ្ញាតឱ្យ កោស ឆូត លុប ឬសរសេរជ្រៀតឡើយ ។

**៣-អំពីការបង់ថ្លៃក្រដាស និងថ្លៃតែមប្រើលើសំបុត្រអត្រានុកូលដ្ឋាន ៖**

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងតែមប្រើត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ ។

☞ យោងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

☞ យោងអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

☞ យោងសេចក្តីណែនាំលេខ ០០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការអនុវត្តអនុក្រឹត្យ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

☞ ការសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តដូចគ្នានឹងការចុះបញ្ជីអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរដែរ លើកលែងតែចំណុចមួយចំនួននៃភាគីបរទេស ដែលត្រូវបំពេញដូចខាងក្រោម ៖

១០). **សញ្ជាតិ** ៖ ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន្តដែលបានរៀបអាពាហ៍ពិពាហ៍។

១៤). **ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍** ៖ ត្រូវសរសេរទីលំនៅរបស់សាមីខ្លួនប្តី ឬប្រពន្ធនៅប្រទេសដើមរបស់ខ្លួនជាអក្សរខ្មែរ ដោយបញ្ជាក់ពីទីលំនៅឯបរទេសឱ្យបានពិតប្រាកដ។

១៥). **លេខអត្តសញ្ញាណប័ណ្ណ** ៖ ត្រូវសរសេរលេខលិខិតឆ្លងដែន និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព ឬលេខទិដ្ឋាការ ឬលេខលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំដែលមានសុពលភាព។

**បញ្ជាក់ ÷** បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ទេ ហើយទន្ទឹមនេះមន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ត្រីមានសមត្ថកិច្ចភ្លាម។

**ឧទាហរណ៍ ៣.១÷** ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការសរសេរប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និងការសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ (បញ្ជីលេខ ០៩) តាមឧទាហរណ៍ខាងក្រោម ៖

នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ លោកសាស្ត្រាចារ្យ សាយ សំអាន និងអ្នកគ្រូពេទ្យ អ៊ូ នួនស្រី បានទៅសាលាសង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីសុំរៀបអាពាហ៍ពិពាហ៍ដំបូងនៃជីវិតរបស់គាត់ដោយដាក់ជូនលោកមន្ត្រីអត្រានុកូលដ្ឋាននូវ ៖

១). ពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់លោក សាយ សំអាន ០១ច្បាប់

២). ពាក្យសុំរៀបអាពាហ៍របស់នាង អ៊ូ នួនស្រី ០១ច្បាប់

៣). លិខិតបញ្ជាក់ភាពនៅលីវរបស់លោក សាយ សំអាន ០១ច្បាប់

៤). លិខិតបញ្ជាក់ភាពនៅលីវរបស់នាង អ៊ូ នួនស្រី ០១ច្បាប់

៥). សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់លោក សាយ សំអាន ០១ច្បាប់

៦). សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់នាង អ៊ូ នួនស្រី ០១ច្បាប់

នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ ដដែលនោះ ក្រោយពីមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បាក់ខែង បានពិនិត្យសំណុំ

លិខិត ទាំងអស់ឃើញថា មានលក្ខណៈត្រឹមត្រូវហើយ មន្ត្រីអត្រានុកូលដ្ឋានបានចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ លេខ ០៩ ប.ខ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១២ មានចំនួន ០៥ច្បាប់។

- ០១ច្បាប់ យកទៅបិទផ្សាយនៅសាលាសង្កាត់នៃលំនៅដ្ឋានរបស់លោក សាយ សំអាន
- ០១ច្បាប់ យកទៅបិទផ្សាយនៅផ្ទះលោក សាយ សំអាន
- ០១ច្បាប់ យកទៅបិទផ្សាយនៅផ្ទះនាង អ៊ូ នួនស្រី
- ០១ច្បាប់ យកទៅបិទផ្សាយនៅសាលាសង្កាត់បាក់ខែង ជាសង្កាត់នៃលំនៅដ្ឋានរបស់នាងអ៊ូ នួនស្រី
- ០១ច្បាប់ ទៀតតម្កល់ទុកជាឯកសារ នៅសាលាសង្កាត់បាក់ខែង។

ក្រោយពីបិទផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ផុតរយៈពេល១០ថ្ងៃហើយ លោក សាយ សំអាន និងនាង អ៊ូ នួនស្រី ពុំមានជនណាប្តឹងជំទាស់ឡើយ សាមីខ្លួនទាំងពីរ រួមនិងសាក្សីគ្រប់អាយុការពីររូប បានទៅចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បាក់ខែង នៅសាលាសង្កាត់បាក់ខែង (រៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់) នាថ្ងៃសុក្រ ទី២០ ខែកុម្ភៈ ឆ្នាំ២០១២។

ប្រវត្តិតួអង្គទាក់ទងនឹងអាពាហ៍ពិពាហ៍ខាងលើ ៖

ផ្នែកខាងប្រុស ៖

**១). លោក សាយ សំអាន**

- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣។
- ទីកន្លែងកំណើត ៖ ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា
- សញ្ជាតិ ៖ ខ្មែរ
- មុខរបរបច្ចុប្បន្ន ៖ សាស្ត្រាចារ្យ
- ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ៖ ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
- អត្តសញ្ញាណប័ណ្ណ ៖ គ្មាន

**២). លោក សាយ សំអឿន ជាឪពុកលោក សាយ សំអាន**

- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦
- រស់ ឬស្លាប់ ៖ រស់
- សញ្ជាតិ ៖ ខ្មែរ
- មុខរបរបច្ចុប្បន្ន ៖ កសិករ
- ទីលំនៅបច្ចុប្បន្ន ៖ ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**៣). អ្នកស្រី សែម បុប្ផា ជាម្តាយលោក សាយ សំអាន**

- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី៩ ខែមករា ឆ្នាំ១៩៤៨
- រស់ ឬស្លាប់ ៖ រស់
- សញ្ជាតិ ៖ ខ្មែរ

- មុខរបរបច្ចុប្បន្ន ៖ ជាងកាត់ដេរ
- ទីលំនៅបច្ចុប្បន្ន ៖ ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ផ្នែកខាងស្រី ៖

**១).នាង អ៊ូ នួនស្រី**

- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩
- ទីកន្លែងកំណើត ៖ ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- សញ្ជាតិ ៖ ខ្មែរ
- មុខរបរបច្ចុប្បន្ន ៖ គ្រូពេទ្យ
- ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ៖ ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
- អត្តសញ្ញាណប័ណ្ណ ៖ គ្មាន

**២). លោក អ៊ូ សែម ជាឪពុកនាង អ៊ូ នួនស្រី**

- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥
- រស់ ឬស្លាប់ ៖ រស់
- សញ្ជាតិ ៖ ខ្មែរ
- មុខរបរបច្ចុប្បន្ន ៖ ជាងសំណង់
- ទីលំនៅបច្ចុប្បន្ន ៖ ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**៣). អ្នកស្រី នួន ផល្លា ជាម្តាយនាង អ៊ូ នួនស្រី**

- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០
- រស់ ឬស្លាប់ ៖ រស់
- សញ្ជាតិ ៖ ខ្មែរ
- មុខរបរបច្ចុប្បន្ន ៖ លក់ដូរ
- ទីលំនៅបច្ចុប្បន្ន ៖ ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ផ្នែកសាក្សី ៖

**១). សាក្សីមួយនាក់ឈ្មោះ សោម ទុយ**

- ភេទ ៖ ប្រុស
- សញ្ជាតិ ៖ ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧២
- មុខរបរបច្ចុប្បន្ន ៖ កសិករ
- ទីលំនៅបច្ចុប្បន្ន ៖ ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- អត្តសញ្ញាណប័ណ្ណ ៖ គ្មាន

**២). សាក្សីមួយនាក់ទៀតឈ្មោះ សេង ភក្តី**

- ភេទ ៖ ស្រី
- សញ្ជាតិ ៖ ខ្មែរ
- ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧០
- មុខរបរបច្ចុប្បន្ន ៖ គ្រូបង្រៀន
- ទីលំនៅបច្ចុប្បន្ន ៖ ភូមិក្តិចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំព្រះ នាងខ្ញុំឈ្មោះ----អ៊ូ *នួនស្រី----* ភេទ--ស្រី-- សញ្ជាតិ--ខ្មែរ-- ឆ្នាំកំណើត--១៩៧៥-- មុខរបរបច្ចុប្បន្ន------------------គ្រូពេទ្យ------------------------ ស្ថានភាពផ្ទាល់ខ្លួន------នៅលីវ------ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ----------- ក្រុម--------- ភូមិ----------ក្តីចាស់---------- ឃុំ សង្កាត់-------បាក់ខែង------- ស្រុក ខណ្ឌ-------ឫស្សីកែវ------- ខេត្ត រាជធានី-------ភ្នំពេញ------- ។ ឪពុកឈ្មោះ------អ៊ូ *សែម------* អាយុ---៤៧---ឆ្នាំ (ស្លាប់ រស់) ម្តាយឈ្មោះ------នួន *ផល្លា------* អាយុ---៤២---ឆ្នាំ (ស្លាប់ រស់) ។

**គោរពជូន**
**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់------បាក់ខែង------**

**<u>កម្មវត្ថុ</u>** ÷ សំណើសុំរៀបអាពាហ៍ពិពាហ៍ ។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ-----សាយ *សំអាន-----* ភេទ---ប្រុស--- សញ្ជាតិ---ខ្មែរ--- ឆ្នាំកំណើត---១៩៧៣--- មុខរបរ------------សាស្ត្រាចារ្យ------------ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ--------- ផ្លូវលេខ--------- ក្រុម---------- ភូមិ----------បាក់ខែង--------ឃុំ សង្កាត់------ព្រែកលៀប------- ស្រុក ខណ្ឌ------ឫស្សីកែវ------- ខេត្ត រាជធានី-------ភ្នំពេញ------ ។

ខ្ញុំសូមអះអាងថា ខ្ញុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់---បាក់ខែង----- មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី *០២* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖ **ស្នាមមេដៃសាមីខ្លួន**

- ----លិខិតបញ្ជាក់ភាពនៅលីវ *០១ច្បាប់----*
- ----សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត *០១ច្បាប់----*

*អ៊ូ នួនស្រី*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ---*សាយ សំអាន*--- ភេទ--ប្រុស-- សញ្ជាតិ--ខ្មែរ-- ឆ្នាំកំណើត--១៩៧៣-- មុខរបរបច្ចុប្បន្ន--------------សាស្ត្រាចារ្យ------------------------- ស្ថានភាពផ្ទាល់ខ្លួន----នៅលីវ---- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ----------- ក្រុម--------- ភូមិ---------បាក់ខែង---------- ឃុំ សង្កាត់-------ព្រែកលៀប------- ស្រុក ខណ្ឌ-------ឫស្សីកែវ------- ខេត្ត រាជធានី------ភ្នំពេញ------- ។ ឪពុកឈ្មោះ------*សាយ សំអឿន*----- អាយុ---៥៦---ឆ្នាំ (ស្លាប់ រស់) ម្តាយឈ្មោះ------*សែម បុប្ផា*----- អាយុ---៤២---ឆ្នាំ (ស្លាប់ រស់) ។

## គោរពជូន
### មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់...... *បាក់ខែង* .......

**<u>កម្មវត្ថុ</u>** ÷ សំណើសុំរៀបអាពាហ៍ពិពាហ៍។

ដោយខ្ញុំបាទ នាងខ្ញុំ បានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ------*អ៊ូ នួនស្រី*------- ភេទ---*ស្រី*--- សញ្ជាតិ---ខ្មែរ--- ឆ្នាំកំណើត---១៩៧៥--- មុខរបរ--------គ្រូពេទ្យ-------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ---------- ក្រុម---------- ភូមិ---------ក្តីចាស់----------- ឃុំ សង្កាត់-------បាក់ខែង------- ស្រុក ខណ្ឌ-------ឫស្សីកែវ------- ខេត្ត រាជធានី-------ភ្នំពេញ------- ។

ខ្ញុំសូមអះអាងថា ខ្ញុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់---បាក់ខែង----- មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានរៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ។

ធ្វើនៅថ្ងៃទី *០២* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

<u>សូមជូនភ្ជាប់ជាមួយនូវ</u> ៖ **ស្នាមមេដៃសាមីខ្លួន**

– ---លិខិតបញ្ជាក់ភាពនៅលីវ *០១ច្បាប់---*

– ---សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត *០១ច្បាប់---* *សាយ សំអាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**~~ខេត្ត~~ ~~ក្រុង~~ រាជធានី** ---- *ភ្នំពេញ* -------
**~~ស្រុក~~ ខណ្ឌ** ---- *ឫស្សីកែវ* ------
**~~ឃុំ~~ សង្កាត់** ---- *បាក់ខែង* ------
**លេខ** ---- *០៩ ប.ខ* -----

# បណ្ណប្រកាសអាពាហ៍ពិពាហ៍

| អំពីសាមីខ្លួន | ខាងប្រុស | ខាងស្រី |
|---|---|---|
| នាមត្រកូល និង នាមខ្លួន | *សាយ សំអាន* | *អ៊ូ នួនស្រី* |
| ជាអក្សរឡាតាំង | SAY SAM ANN | OU NUON SREY |
| សញ្ជាតិ | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរបច្ចុប្បន្ន | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| រយៈពេលប្ដឹងជំទាស់ | *១០ថ្ងៃ គិតពីថ្ងៃបិទផ្សាយ* | |
| នាមត្រកូល និងនាមខ្លួនឪពុក | *សាយ សំអឿន* | *អ៊ូ សែម* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| មុខរបរបច្ចុប្បន្ន | *កសិករ* | *ជាងសំណង់* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| នាមត្រកូល និងនាមខ្លួនម្ដាយ | *សែម បុផ្ផា* | *នួន ផល្លា* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |
| មុខរបរបច្ចុប្បន្ន | *ជាងកាត់ដេរ* | *លក់ដូរ* |
| ទីលំនៅបច្ចុប្បន្ន | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |

បណ្ណប្រកាសអាពាហ៍ពិពាហ៍នេះ ត្រូវបិទផ្សាយជាសាធារណៈ នៅថ្ងៃទី *០៣* ខែ *កុម្ភៈ* ឆ្នាំ *២០១២* ។

ធ្វើនៅ.... *បាក់ខែង* ....ថ្ងៃទី *០២* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

**មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

*ផែ សូនី*

~~ខេត្ត~~ **រាជធានី** (១)..... *ភ្នំពេញ* ..........
~~ស្រុក~~ **ខណ្ឌ** (២).... *ឫស្សីកែវ* ........
~~ឃុំ~~ **សង្កាត់** (៣)...... *បាក់ខែង* ........

**លេខ** (៤)................ *០៩* ............................
**សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)...០១/២០១២...
**ឆ្នាំ** (៦)......... *២០១២* ..................................

## បញ្ជីអាពាហ៍ពិពាហ៍

| **អំពីប្តី ប្រពន្ធ** | **ប្តី** | | **ប្រពន្ធ** | |
|---|---|---|---|---|
| នាមត្រកូល (៧) | *សាយ* | | *អ៊ូ* | |
| នាមខ្លួន (៨) | *សំអាន* | | *នួនស្រី* | |
| ជាអក្សរឡាតាំង (៩) នាមត្រកូល | SAY | | OU | |
| ជាអក្សរឡាតាំង (៩) នាមខ្លួន | SAM ANN | | NUON SREY | |
| សញ្ជាតិ (១០) | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | *ភូមិពញ្ញាឮ ឃុំពញ្ញាឮ ស្រុកពញ្ញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា* | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | *សាស្ត្រចារ្យ* | | *គ្រូពេទ្យ* | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | *ភូមិបាក់ខែង សង្កាត់ព្រែកល្បៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (១៥) | | | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៦) | *មួយ* | | *មួយ* | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៧) | *ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២* | | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៨) | *សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ* | | | |
| លេខ និងថ្ងៃ ខែឆ្នាំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (១៩) | *០៩ ប.ខ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២* | | | |
| **អំពីឪពុក ម្តាយ** | **ខាងប្តី** | | **ខាងប្រពន្ធ** | |
| នាមត្រកូល និង នាមខ្លួនឪពុក (២០) | *សាយ សំអឿន* (២១) | សញ្ជាតិ *ខ្មែរ* | *អ៊ូ សែម* | សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២២) | SAY SAM OEUN (២៣) | រស់ ឬ ស្លាប់ | OU SEM | រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* | |
| មុខរបរបច្ចុប្បន្ន (២៥) | *កសិករ* | | *ជាងសំណង់* | |
| ទីលំនៅបច្ចុប្បន្ន (២៦) | *ភូមិបាក់ខែង សង្កាត់ព្រែកល្បៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| នាមត្រកូល និង នាមខ្លួនម្តាយ (២៧) | *សែម បុប្ផា* (២៨) | សញ្ជាតិ *ខ្មែរ* | *នួន ផល្លា* | សញ្ជាតិ *ខ្មែរ* |
| ជាអក្សរឡាតាំង (២៩) | SEM BOPHA (៣០) | រស់ ឬ ស្លាប់ | NUON PHALLA | រស់ ឬ ស្លាប់ |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣១) | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* | |
| មុខរបរបច្ចុប្បន្ន (៣២) | *ជាងកាត់ដេរ* | | *លក់ដូរ* | |
| ទីលំនៅបច្ចុប្បន្ន (៣៣) | *ភូមិបាក់ខែង សង្កាត់ព្រែកល្បៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| **អំពីសាក្សី** | **សាក្សី** | | **សាក្សី** | |
| នាមត្រកូល និង នាមខ្លួន (៣៤) | *សោម ទុយ* (៣៥) | ភេទ *ប្រុស* | *សេង ភក្តី* | ភេទ *ស្រី* |
| សញ្ជាតិ (៣៦) | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | *ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧២* | | *ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧០* | |
| មុខរបរបច្ចុប្បន្ន (៣៨) | *កសិករ* | | *គ្រូបង្រៀន* | |
| ទីលំនៅបច្ចុប្បន្ន (៣៩) | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | |
| លេខអត្តសញ្ញាណប័ណ្ណ (៤០) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤២) ធ្វើនៅ.....បាក់ខែង ........... ថ្ងៃទី *២០* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(៤១) **ស្នាមមេដៃស្តាំ**

ប្តី ប្រពន្ធ សាក្សី សាក្សី

*សាយ សំអាន* *អ៊ូ នួន ស្រី* *សោម ទុយ* *សេង ភក្តី*

(៤៣) **មន្ត្រីអត្រានុកូលដ្ឋាន**
***មេឃុំ***
(៤៤) *ហត្ថលេខា និងត្រា*
*ផៃ សូនី*

**គ).ការរៀបអាពាហ៍ពិពាហ៍រវាងជនបរទេស និងជនអន្តោប្រវេសន្ត ជាមួយជនបរទេស និងជនអន្តោប្រវេសន្ត ដែលរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា**

☞ ជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន្តបានដោយអនុវត្តតាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋាន នៅទីកន្លែងដែលខ្លួនស្នាក់នៅជាប់លាប់ ដោយប្រាប់ពីទីកន្លែង និងពេលវេលារៀបអាពាហ៍ពិពាហ៍នោះឱ្យបានច្បាស់លាស់។

☞ ការសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អាចទៅសុំចុះនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា (ប្រសិនបើមាន) ឬអាចទៅសុំចុះនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ដោយអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

☞ មន្ត្រីអត្រានុកូលដ្ឋាននៅឃុំ ឬសង្កាត់ អាចចុះសៀវភៅអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តនោះបាន ដោយអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

☞ ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍នៅឃុំ ឬសង្កាត់ សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តដូចគ្នានឹងការណែនាំចុះសៀវភៅអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរដែរ លើកលែងចំណុចមួយចំនួន ដូចខាងក្រោម ៖

១០). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិជនបរទេស ឬជនអន្តោប្រវេសន្តដែលបានរៀបអាពាហ៍ពិពាហ៍។

១៥). ទីលំនៅឯបរទេស៖ ត្រូវសរសេរទីលំនៅរបស់សាមីខ្លួនប្ដី ប្រពន្ធ នៅប្រទេសដើមរបស់ខ្លួន ជាអក្សរខ្មែរ ដោយបញ្ជាក់ពីទីលំនៅឯបរទេសអោយបានត្រឹមត្រូវ។

១៦). លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ៖ ត្រូវសរសេរលេខលិខិតឆ្លងដែន និងថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។

១៧). ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ៖ ត្រូវសរសេរលេខទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។

**បញ្ជាក់៖** បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ទេ ហើយទន្ទឹមនេះមន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ត្រីមានសមត្ថកិច្ចភ្លាម។

**ខេត្ត ក្រុង** (១)........................................ **លេខ** (៤)..................................................

**ស្រុក ខណ្ឌ** (២)..................................... **សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)............

**ឃុំ សង្កាត់** (៣)....................................... **ឆ្នាំ** (៦).........................................................

## បញ្ជីអាពាហ៍ពិពាហ៍សំរាប់ជនបរទេស និង ជនអន្តោប្រវេសន្តស្របច្បាប់

| **អំពីប្តី ប្រពន្ធ** | **ប្តី** | **ប្រពន្ធ** |
|---|---|---|
| នាមត្រកូល (៧) | | |
| នាមខ្លួន (៨) | | |
| ជាអក្សរឡាតាំង (៩) នាមត្រកូល | | |
| ជាអក្សរឡាតាំង (៩) នាមខ្លួន | | |
| សញ្ជាតិ (១០) | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | |
| ទីកន្លែងកំណើត (១២) | | |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | |
| ទីលំនៅឯបរទេស (១៥) | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៦) | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតអោយស្នាក់នៅកម្ពុជាលេខ ថ្ងៃ ខែឆ្នាំ (១៧) | | |
| ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី (១៨) | | |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៩) | | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (២០) | | |
| លេខ និង ថ្ងៃ ខែ ឆ្នាំ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ (២១) | | |
| **អំពីឪពុក ម្តាយ** | **ខាងប្តី** | **ខាងប្រពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក (២២) | (២៣) \| រស់ ឬ ស្លាប់ | \| រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (២៤) | | |
| សញ្ជាតិ (២៥) | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៦) | | |
| មុខរបរបច្ចុប្បន្ន (២៧) | | |
| ទីលំនៅបច្ចុប្បន្ន (២៨) | | |
| នាមត្រកូល និង នាមខ្លួនម្តាយ (២៩) | (៣០) \| រស់ ឬ ស្លាប់ | \| រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (៣១) | | |
| សញ្ជាតិ (៣២) | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៣) | | |
| មុខរបរបច្ចុប្បន្ន (៣៤) | | |
| ទីលំនៅបច្ចុប្បន្ន (៣៥) | | |
| **អំពីសាក្សី** | **សាក្សី** | **សាក្សី** |
| នាមត្រកូល និង នាមខ្លួន (៣៦) | (៣៧) \| ភេទ | \| ភេទ |
| ជាអក្សរឡាតាំង (៣៨) | | |
| សញ្ជាតិ (៣៩) | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៤០) | | |
| មុខរបរបច្ចុប្បន្ន (៤១) | | |
| ទីលំនៅបច្ចុប្បន្នុន (៤២) | | |
| លេខអត្តសញ្ញាណប័ណ្ណ (៤៣) | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យអ្នកដែលមកសុំ ជននោះ និង មន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៥) ធ្វើនៅ.................... ថ្ងៃទី........... ខែ................ ឆ្នាំ...............

(៤៤) **ស្នាមមេដៃស្តាំ**

ប្តី ប្រពន្ធ សាក្សី សាក្សី

(៤៦) **មន្ត្រីអត្រានុកូលដ្ឋាន**

(៤៧) ហត្ថលេខា និងត្រា

**ឃ).** **ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេសដែលកំពុងរស់នៅស្របច្បាប់ឯបរទេស** នីតិវិធី នៃការចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ចំពោះពលរដ្ឋខ្មែររៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ឬពលរដ្ឋខ្មែររៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសដែលកំពុងរស់នៅស្របច្បាប់ឯបរទេស នឹងមានការណែនាំជាក្រោយ។

### ៣.៤.២. ការសរសេរសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ទាំងពីររួចហើយ មន្ត្រីអត្រា-នុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឱ្យខុសពីខ្លឹមសារក្នុងបញ្ជីអាពាហ៍ពិពាហ៍ ដោយដកស្រង់យកតែចំណុចសំខាន់ៗពីបញ្ជីអាពាហ៍ពិពាហ៍ ដូចខាងក្រោម ៖

**ក).** **សម្រាប់ពលរដ្ឋខ្មែរ រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ឬជាមួយជនបរទេសដែលរស់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជា**

១). រាជធានី ខេត្ត ៖ ចម្លងយកចំណុចទី១ នៃបញ្ជីអាពាហ៍ពិពាហ៍។

២). ក្រុង ស្រុក ខណ្ឌ ៖ ចម្លងយកចំណុចទី២ នៃបញ្ជីអាពាហ៍ពិពាហ៍។

៣). ឃុំ សង្កាត់ ៖ ចម្លងយកចំណុចទី៣ នៃបញ្ជីអាពាហ៍ពិពាហ៍។

៤). លេខ ៖ ចម្លងយកចំណុចទី៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

៥). សៀវភៅអាពាហ៍ពិពាហ៍លេខ ៖ ចម្លងយកចំណុចទី៥ នៃបញ្ជីអាពាហ៍ពិពាហ៍។

៦). ឆ្នាំ ៖ ចម្លងយកចំណុចទី៦ នៃបញ្ជីអាពាហ៍ពិពាហ៍។

៧). នាមត្រកូលប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី៧ នៃបញ្ជីអាពាហ៍ពិពាហ៍។

៨). នាមខ្លួនប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី៨ នៃបញ្ជីអាពាហ៍ពិពាហ៍។

៩). នាមត្រកូល និងនាមខ្លួនប្តីប្រពន្ធជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី៩ នៃបញ្ជីអាពាហ៍ពិពាហ៍។

១០)). សញ្ជាតិ ៖ ចម្លងយកចំណុចទី១០ នៃបញ្ជីអាពាហ៍ពិពាហ៍។

១១). ថ្ងៃ ខែ ឆ្នាំ កំណើតប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី១១ នៃបញ្ជីអាពាហ៍ពិពាហ៍។

១២). ទីកន្លែងកំណើតប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី១២ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៣). មុខរបរប្តី ប្រពន្ធពេលចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី១៣ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៤). ទីលំនៅប្តី ប្រពន្ធពេលចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី១៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៥). ថ្ងៃ ខែ ឆ្នាំចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី១៧ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៦). ទីកន្លែងចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី១៨ នៃបញ្ជីអាពាហ៍ពិពាហ៍។

**ឪពុក**

១៧). នាមត្រកូល និងនាមខ្លួនឪពុក ៖ ចម្លងយកចំណុចទី២០ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៨). នាមត្រកូល និងនាមខ្លួនឪពុកជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី២២ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៩). សញ្ជាតិ ៖ ចម្លងយកចំណុចទី២១ នៃបញ្ជីអាពាហ៍ពិពាហ៍។

២០). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី២៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

**ម្តាយ**

២១). នាមត្រកូល និងនាមខ្លួនម្តាយ ៖ ចម្លងយកចំណុចទី២៧ នៃបញ្ជីអាពាហ៍ពិពាហ៍។

២២). នាមត្រកូល និងនាមខ្លួនម្តាយជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី២៩ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៣). សញ្ជាតិ ៖ ចម្លងយកចំណុចទី២៨ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៤). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី៣១ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៥). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ មើលចំណុចទី៤២ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៦). មន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចទី៤៣ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៧). ហត្ថលេខា និងត្រា ៖ មើលចំណុចទី៤៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

ខ). **សម្រាប់ជនបរទេស ឬ ជនអន្តោប្រវេសន្ត រៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន្ត ដែលរស់នៅស្របច្បាប់ ក្នុងប្រទេសកម្ពុជា**

១). រាជធានី ខេត្ត ៖ ចម្លងយកចំណុចទី១ នៃបញ្ជីអាពាហ៍ពិពាហ៍។

២). ក្រុង ស្រុក ខណ្ឌ ៖ ចម្លងយកចំណុចទី២ នៃបញ្ជីអាពាហ៍ពិពាហ៍។

៣). ឃុំ សង្កាត់ ៖ ចម្លងយកចំណុចទី៣ នៃបញ្ជីអាពាហ៍ពិពាហ៍។

៤). លេខ ៖ ចម្លងយកចំណុចទី៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

៥). សៀវភៅអាពាហ៍ពិពាហ៍លេខ ៖ ចម្លងយកចំណុចទី៥ នៃបញ្ជីអាពាហ៍ពិពាហ៍។

៦). ឆ្នាំ ៖ ចម្លងយកចំណុចទី៦ នៃបញ្ជីអាពាហ៍ពិពាហ៍។

៧). នាមត្រកូលប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី៧ នៃបញ្ជីអាពាហ៍ពិពាហ៍។

៨). នាមខ្លួនប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី៨ នៃបញ្ជីអាពាហ៍ពិពាហ៍។

៩). នាមត្រកូល និងនាមខ្លួនប្តីប្រពន្ធជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី៩ នៃបញ្ជីអាពាហ៍ពិពាហ៍។

១០)). សញ្ជាតិ ៖ ចម្លងយកចំណុចទី១០ នៃបញ្ជីអាពាហ៍ពិពាហ៍។

១១). ថ្ងៃ ខែ ឆ្នាំ កំណើតប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី១១ នៃបញ្ជីអាពាហ៍ពិពាហ៍។

១២). ទីកន្លែងកំណើតប្តី ប្រពន្ធ ៖ ចម្លងយកចំណុចទី១២ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៣). មុខរបរប្តី ប្រពន្ធពេលចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី១៣ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៤). ទីលំនៅប្តី ប្រពន្ធពេលចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី១៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៥). ថ្ងៃ ខែ ឆ្នាំចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី១៩ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៦). ទីកន្លែងចុះអាពាហ៍ពិពាហ៍ ៖ ចម្លងយកចំណុចទី២០ នៃបញ្ជីអាពាហ៍ពិពាហ៍។

**ឳពុក**

១៧). នាមត្រកូល និងនាមខ្លួនឪពុក ៖ ចម្លងយកចំណុចទី២២ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៨). នាមត្រកូល និងនាមខ្លួនឪពុកជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី២៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

១៩). សញ្ជាតិ ៖ ចម្លងយកចំណុចទី២៥ នៃបញ្ជីអាពាហ៍ពិពាហ៍។

២០). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី២៦ នៃបញ្ជីអាពាហ៍ពិពាហ៍។

**ម្ដាយ**

២១). នាមត្រកូល និងនាមខ្លួនម្ដាយ ៖ ចម្លងយកចំណុចទី២៩ នៃបញ្ជីអាពាហ៍ពិពាហ៍។

២២). នាមត្រកូល និងនាមខ្លួនម្ដាយជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី៣១ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៣). សញ្ជាតិ ៖ ចម្លងយកចំណុចទី៣២ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៤). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី៣៣ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៥). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ មើលចំណុចទី៤៥ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៦). មន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចទី៤៦ នៃបញ្ជីអាពាហ៍ពិពាហ៍។

២៧). ហត្ថលេខា និងត្រា ៖ មើលចំណុចទី៤៧ នៃបញ្ជីអាពាហ៍ពិពាហ៍។

**បញ្ជាក់ ÷**

☞ ការប្រគល់សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក៖ ក្រោយពីសរសេរ ចុះហត្ថលេខា និងបោះត្រាលើបញ្ជីទាំងពីរ និងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹករួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមនេះ ទៅឱ្យសាមីខ្លួនប្ដី ប្រពន្ធ និងណែនាំឱ្យរក្សាទុកដាក់ឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមជូនជាលើកទីពីរបានទេ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបសាមីខ្លួនថា សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួនមានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ដូច្នេះគួរធ្វើសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ឱ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។

☞ នៅពេលចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងធ្វើសំបុត្រអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរដោយផ្អែកតាមខ្លឹមសារនៃសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត។

ឧទាហរណ៍ ៖ នៅផ្នែកឪពុក ត្រង់ខ្ទង់ "នាមត្រកូល និងនាមខ្លួន" នៃសំបុត្រកំណើត បានសរសេរថា "មិនស្គាល់" ត្រូវសរសេរថា "មិនស្គាល់" ដូចគ្នានេះដែរ នៅផ្នែកឪពុករបស់សាមីខ្លួន ត្រង់ខ្ទង់ "នាមត្រកូល និងនាមខ្លួន" នៃបញ្ជីអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

~~ខេត្ត~~ ~~ក្រុង~~ **រាជធានី**(១) ----- *ភ្នំពេញ* -----
~~ស្រុក~~ **ខណ្ឌ** (២) ----- *ឫស្សីកែវ* -----
~~ឃុំ~~ **សង្កាត់** (៣) ----- *បាក់ខែង* ------

**លេខ** (៤)-------០៩---------------------------
**សៀវភៅអាពាហ៍ពិពាហ៍លេខ** (៥)-០១/២០១២
**ឆ្នាំ** (៦)-------- *២០១២* -----------------------

# សំបុត្រអាពាហ៍ពិពាហ៍

| **អំពីប្ដី ប្រពន្ធ** | | **ប្ដី** | **ប្រពន្ធ** |
|---|---|---|---|
| នាមត្រកូល (៧) | | *សាយ* | *អ៊ូ* |
| នាមខ្លួន (៨) | | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | SAY | OU |
| | នាមខ្លួន | SAM ANN | NUON SREY |
| សញ្ជាតិ (១០) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្ត ក្រុង ប្រទេស | | *ភូមិពញ្ញាពុ ឃុំពញ្ញាពុ ស្រុកពញ្ញាពុ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្ដីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | *ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៦) | | *សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ* | |
| **អំពីឪពុក ម្ដាយ** | | **ខាងប្ដី** | **ខាងប្រពន្ធ** |
| នាមត្រកូល និង នាមខ្លួនឪពុក (១៧) | | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៨) | | SAY SAM OEUN | OU SEM |
| សញ្ជាតិ (១៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២១) | | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២២) | | SEM BOPHA | NUON PHALLA |
| សញ្ជាតិ (២៣) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៤) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៥) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *២០* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(២៦) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២៧) *ហត្ថលេខា និងត្រា*

*ផៃ សុទី*

## ៣.៥. សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

☞ ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ សង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ហើយត្រូវបោះត្រាផង ។

☞ ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌ សាមី ។

- បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រាផង ។

☞ ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ៖

- ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង ។
- ការសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់ទុកនៅទីនោះ ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមកជាមួយ ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវយកសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមមក ជាមួយ ។

### ៣.៥.១. ការសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និង សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍-ពិពាហ៍

☞ មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ដែលសាមីខ្លួនយកមកដោយធ្វើការ ៖

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍នោះ ពិតជាត្រឹមត្រូវ ដែលចេញដោយក្រសួងមហាផ្ទៃ មែនដែរឬទេ ?
- ផ្ទៀងផ្ទាត់សំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍នោះ ជាមួយបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ឬក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ នូវចំណុចមួយចំនួន ដូចខាងក្រោម ៖
  - ឆ្នាំដែលអនុវត្តនៃសៀវភៅអត្រានុកូលដ្ឋាន
  - លេខសៀវភៅអត្រានុកូលដ្ឋាន
  - លេខបញ្ជីអត្រានុកូលដ្ឋាន

☞ នៅពេលពិនិត្យសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឃើញថាជាសំបុត្រច្បាប់ដើមពិតប្រាកដ ហើយ ទើបមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្ដើមសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

☞ ការសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ដោយចម្លងចេញពី ៖

- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ បើសុំសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍។
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ បើសុំសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

☞ របៀបសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ដូចខាងក្រោម ៖

១). លេខរៀង ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពីលេខ០១។

២). ថ្ងៃខែឆ្នាំចេញសេចក្ដីចម្លង៖ ត្រូវចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរតាមគ្រិស្តសករាជ គឺជាថ្ងៃខែឆ្នាំដែលមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានចុះហត្ថលេខាលើសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

៣). សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវសរសេរក្នុងខ្ទង់នេះថា “ចម្លងសំបុត្រអាពាហ៍ពិពាហ៍”។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវសរសេរក្នុងខ្ទង់នេះថា “ចម្លងសំបុត្របញ្ជាក់អាពាហ៍-ពិពាហ៍”។

**សៀវភៅ**

៤). លេខ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៥ នៃបញ្ជីអាពាហ៍ពិពាហ៍។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៥ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

៥). ឃុំ សង្កាត់ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៣ នៃបញ្ជីអាពាហ៍ពិពាហ៍។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៣ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

**សំបុត្រ**

៦). លេខ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៤ នៃបញ្ជីអាពាហ៍ពិពាហ៍។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៤ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

៧). ចុះថ្ងៃ ខែ ឆ្នាំ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៣៤ នៃបញ្ជីអាពាហ៍ពិពាហ៍។

- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៣២ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

**ប្ដី ប្រពន្ធ**

៨). នាមត្រកូល និងនាមខ្លួន ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៧ និងទី៨ នៃបញ្ជីអាពាហ៍ពិពាហ៍។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី៧-៨ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

៩). សញ្ជាតិ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១០ នៃបញ្ជីអាពាហ៍ពិពាហ៍។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១០ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

១០). ថ្ងៃ ខែ ឆ្នាំកំណើត ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១១ នៃបញ្ជីអាពាហ៍ពិពាហ៍ ។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១១ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

១១). ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១៨ នៃបញ្ជីអាពាហ៍ពិពាហ៍។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១៨ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

១២). ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ ៖

- បើចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១៧ នៃបញ្ជីអាពាហ៍ពិពាហ៍ ។
- បើចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវចម្លងយកពីចំណុចទី១៧ នៃបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។

**អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍**

១៣). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនរបស់អ្នកមកសុំចម្លងសំបុត្រអាពាហ៍-ពិពាហ៍ ឬអ្នកមកសុំចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

១៤). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរទីលំនៅបច្ចុប្បន្នរបស់អ្នកមកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ អ្នកមកសុំចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ដោយសរសេរលេខផ្ទះ លេខផ្លូវ (បើសិនជាមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និង ប្រទេស។

១៥). ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ ៖ ត្រូវសរសេរពីការពាក់ព័ន្ធរវាងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ និងអ្នកសុំចម្លង។ អ្នកមក សុំចម្លងអាចជាសាមីខ្លួន ឬឪពុកម្ដាយ ឬសាច់ញាតិសន្ដាននៃអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍។ **ឧទាហរណ៍** ÷ បើជាសាមីខ្លួន ត្រូវសរសេរ “សាមីខ្លួន” បើជាឪពុកបង្កើត ត្រូវសរសេរ “ឪពុកបង្កើត” បើជាមាបង្កើតត្រូវសរសេរ “មាបង្កើត” ។

១៦). ស្នាមមេដៃស្ដាំ ៖ ក្រោយពីសរសេរបំពេញគ្រប់ខ្ទង់រួចហើយ ត្រូវឱ្យអ្នកមកសុំចម្លងផ្ដិតមេដៃស្ដាំ។

**មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍**

១៧). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនអ្នកដែលចុះហត្ថលេខាលើសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

១៨). មុខងារ ៖ ត្រូវសរសេរមុខងាររបស់មន្ត្រីដែលមានឈ្មោះនៅចំណុច១៧ ៖
- អាចសរសេរ“មេឃុំ” ឬ“ចៅសង្កាត់” បើគាត់ជាមេឃុំ ឬចៅសង្កាត់។ អាចសរសេរ “ជំទប់ទី១” ឬ“ចៅសង្កាត់រងទី១” បើគាត់បានទទួលការផ្ទេរសិទ្ធិ។
- អាចសរសេរ “ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ” បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន នៅសាលាក្រុង ស្រុក ខណ្ឌ ។
- អាចសរសេរ “នាយកទីចាត់ការរដ្ឋបាល” បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅ សាលារាជធានី ខេត្ត ។

១៩). ចំនួនសន្លឹកចម្លង ៖ ត្រូវសរសេរចំនួនសន្លឹកនៃសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ដែលបានចម្លង ដោយសរសេរជាលេខខ្មែរ។

២០). សេចក្តីផ្សេងៗ ៖ បើមានករណីពិសេសដែលគ្មានរៀបរាប់ក្នុងចំណុចទាំង១៩នោះទេ ត្រូវសរសេរក្នុងសេចក្តីផ្សេងៗនេះ។ បើគ្មានករណីពិសេសទេ មិនត្រូវសរសេរអ្វីឡើយ ដោយទុកឱ្យនៅទំនេរ។

**ឧទាហរណ៍ ៣.៣** ÷ ការសរសេរចូលក្នុងសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ នៅសាលាឃុំ សង្កាត់ តាមឧទាហរណ៍ដូចខាងក្រោម ៖

ថ្ងៃច័ន្ទ ទី១៦ ខែសីហា ឆ្នាំ២០១២ លោក សាយ សំអាន បានទៅសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់គាត់ចំនួន០៥សន្លឹក នៅសង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយកាន់យកទៅជាមួយនូវសំបុត្រអាពាហ៍-ពិពាហ៍ច្បាប់ដើមរបស់គាត់លេខ ០៩ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍លេខ ០១/២០១២ ដើម្បីបង្ហាញមន្ត្រីអត្រានុកូលដ្ឋាន។

ពេលបច្ចុប្បន្ននេះ លោក សាយ សំអាន និងភរិយារបស់គាត់ បានរស់នៅជាមួយឪពុកម្តាយបង្កើតរបស់គាត់វិញ គឺភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

មន្ត្រីអត្រានុកូលដ្ឋានសង្កាត់បាក់ខែងឈ្មោះ ឆៃ សូនី។

**ឧទាហរណ៍ ៣.៤** ÷ ការសរសេរចូលក្នុងសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍-ពិពាហ៍នៅសាលាក្រុង ស្រុក ខណ្ឌ តាមឧទាហរណ៍ដូចខាងក្រោម ៖

ថ្ងៃសុក្រ ទី២៣ ខែមករា ឆ្នាំ២០១២ លោក ទេព សឿង បានទៅសុំចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់គាត់ចំនួន១២សន្លឹកនៅសាលាស្រុកស្អាង ខេត្តកណ្តាល ដោយកាន់យកទៅជាមួយនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមរបស់គាត់លេខ១២ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ ក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍លេខ ០១/២០០៥ ដើម្បីបង្ហាញមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុកស្អាង។

- មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុកស្អាងឈ្មោះ គុង្គ គឹមយ៉ន។
- លេខ ថ្ងៃ ខែ ឆ្នាំបញ្ជាក់លើសេចក្តីចម្លងសំបុត្រងបញ្ជាក់អាពាហ៍ពិពាហ៍នេះរបស់ស្រុកស្អាង ០៥ ស.ប.អ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២។
- អភិបាលស្រុកស្អាងឈ្មោះ ខឹម ច័ន្ទគិរី។

## សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាឃុំ សង្កាត់)

| លេខរៀង | ថ្ងៃខែឆ្នាំចេញសេចក្តីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្តី ប្រពន្ធ | | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២* | *ចម្លងសំបុត្រអាពាហ៍ពិពាហ៍* | *០១/ ២០១២* | *បាក់ខែង* | *០៩* | *ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២* | *សាយ សំអាន*<br>*អ៊ូ នួនស្រី* | *ខ្មែរ*<br>*ខ្មែរ* | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣*<br>*ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* | *សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ* | *ថ្ងៃសុក្រ ទី២០ ខែកុម្ភៈ ឆ្នាំ២០១២* | *សាយ សំអាន* | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *សាមីខ្លួន* | | *ឆែ សូនី* | *មេឃុំ* | *០៥ សន្លឹក* | |
| | | | | | | | ប្តី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្តី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

## សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ (នៅសាលាស្រុក ខណ្ឌ)

| លេខរៀង | ថ្ងៃខែឆ្នាំចេញសេចក្ដីចម្លង | ចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | សៀវភៅ | | សំបុត្រ | | ប្ដី ប្រពន្ធ | | | | | អ្នកសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | | មន្ត្រីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃខែឆ្នាំ | នាមត្រកូល និងនាមខ្លួន | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំ កំណើត | ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងអ្នកចុះបញ្ជីអាពាហ៍ពិពាហ៍ ឬបញ្ជាក់អាពាហ៍ពិពាហ៍ | ស្នាមមេដៃស្ដាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្ដីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| ០១ | ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ | ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | ០១/២០០៥ | ព្រែក អំបិល | ១ ២ | ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥ | ទេព សឿង<br>ភួង វណ្ណា | ខ្មែរ<br>ខ្មែរ | ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨<br>ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣ | ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល | ថ្ងៃសុក្រ ទី១៥ ខែសីហា ឆ្នាំ២០០៥ | ទេព សឿង | ភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា | សាមីខ្លួន | | គុង្គ គឹមយ៉ន | ប្រធានការិយាល័យរដ្ឋបាលទូទៅ | ១២ សន្លឹក | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្ដី........ | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | ប្រពន្ធ... | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

### ៣.៥.២. របៀបសរសេរសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

☞ នៅពេលការសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានត្រូវសរសេរចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

☞ របៀបសរសេរសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ អនុវត្តដូចគ្នានឹងការសរសេរសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមដែរ។

☞ ចំពោះការសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវមានការបញ្ជាក់មួយចំនួន ដូចខាងក្រោម ៖

| |
|---|
| លេខ (ក)...................... |
| យើង |
| (ខ)............................................................. |
| បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្ដាំនេះ ជាហត្ថលេខា |
| របស់លោក (គ)................................ |
| ជាមន្ត្រីរក្សាសៀវភៅ អត្រានុកូលដ្ឋាន |
| (ឃ)...............................ពិតប្រាកដមែន។ |
| (ង) ធ្វើនៅ.................. ថ្ងៃទី........ ខែ.............. |
| ឆ្នាំ........ |
| (ច) ហត្ថលេខា និងត្រា |

ក). លេខ ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពី០១ រហូតដល់ដំណាច់ឆ្នាំ។ នៅឆ្នាំថ្មី ត្រូវអនុវត្តចុះលេខថ្មី ចាប់ពីលេខ០១ដដែល។ នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានសៀវភៅចុះលេខចេញដោយឡែក សម្រាប់សេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋាន។

ខ). ត្រូវសរសេរ “អភិបាលក្រុង ស្រុក ខណ្ឌ......(ឈ្មោះក្រុង ស្រុក ខណ្ឌ)......។

គ). ឈ្មោះមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន។

ឃ). ត្រូវសរសេរ “ក្រុង ស្រុក ខណ្ឌ...........(ឈ្មោះក្រុង ស្រុក ខណ្ឌ)...........” ។

ង). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ ត្រូវសរសេរឈ្មោះក្រុង ស្រុក ខណ្ឌ និងចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរតាម គ្រិស្តសករាជ។

ច). ហត្ថលេខា និងត្រា ៖ ហត្ថលេខារបស់អភិបាលក្រុង ស្រុក ខណ្ឌ និង បោះត្រា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**~~ខេត្ត~~ ~~ក្រុង~~ រាជធានី(១)** ----- *ភ្នំពេញ*-----
**~~ស្រុក~~ ខណ្ឌ (២)** ----- *ឫស្សីកែវ* ---
**~~ឃុំ~~ សង្កាត់ (៣)** ----- *បាក់ខែង* ----

# សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍

| ចម្លងសំបុត្រអាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅអាពាហ៍ពិពាហ៍<br>លេខ ៖--- *០១/២០១២*------ | (៥) សំបុត្រអាពាហ៍ពិពាហ៍<br>លេខ *០៩* ចុះថ្ងៃទី *២០* ខែ *កុម្ភៈ* ឆ្នាំ *២០១២* |
|---|---|---|---|
| អំពីប្តី ប្រពន្ធ | | ប្តី | ប្រពន្ធ |
| នាមត្រកូល (៦) | | *សាយ* | *អ៊ូ* |
| នាមខ្លួន (៧) | | *សំអាន* | *នួនស្រី* |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | *SAY* | *OU* |
| | នាមខ្លួន | *SAM ANN* | *NUON SREY* |
| សញ្ជាតិ (៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១០) | | *ថ្ងៃពុធ ទី២៥ ខែសីហា ឆ្នាំ១៩៧៣* | *ថ្ងៃច័ន្ទ ទី១៧ ខែមករា ឆ្នាំ១៩៧៩* |
| ទីកន្លែងកំណើត (១១)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តដ ក្រុង ប្រទេស | | *ភូមិពញាឮ ឃុំពញាឮ ស្រុកពញាឮ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១២) | | *សាស្ត្រាចារ្យ* | *គ្រូពេទ្យ* |
| ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ (១៣) | | *ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* | *ភូមិក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍ (១៤) | | *ថ្ងៃ សុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២* | |
| ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍ (១៥) | | *សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ* | |
| អំពីឪពុក ម្តាយ | | ខាងប្តី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | | *សាយ សំអឿន* | *អ៊ូ សែម* |
| ជាអក្សរឡាតាំង (១៧) | | *SAY SAM OEUN* | *OU SEM* |
| សញ្ជាតិ (១៨) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៤៦* | *ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៥* |
| នាមត្រកូល និង នាមខ្លួនម្តាយ (២០) | | *សែម បុប្ផា* | *នួន ផល្លា* |
| ជាអក្សរឡាតាំង (២១) | | *SEM BOPHA* | *NUON PHALLA* |
| សញ្ជាតិ (២២) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៤៨* | *ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៦០* |

(២៤) ធ្វើនៅ.... *បាក់ខែង* .... ថ្ងៃទី *១៦* ខែ *សីហា* ឆ្នាំ *២០១២*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**-----

***មេឃុំ***

(២៦) *ហត្ថលេខា និងត្រា*

*ផៃ សូនី*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ~~ក្រុង~~ (១) ----- *កណ្ដាល* -----
ស្រុក ~~ខណ្ឌ~~ (២) ----- *ស្អាង* --------
ឃុំ សង្កាត់ (៣) ---------------------

## សេចក្ដីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

| ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចេញពី | | (៤) សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ លេខ ៖ *០១/២០០៥* | (៥) សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ លេខ០១២ ចុះថ្ងៃទី *១៥* ខែ *សីហា* ឆ្នាំ *២០០៥* |
|---|---|---|---|
| អំពីប្ដី ប្រពន្ធ | | ប្ដី | ប្រពន្ធ |
| នាមត្រកូល (៦) | | *ទេព* | *ភួង* |
| នាមខ្លួន (៧) | | *សឿង* | *វណ្ណា* |
| ជាអក្សរឡាតាំង (៨) | នាមត្រកូល | TEP | PHUONG |
| | នាមខ្លួន | SOEUNG | VANNA |
| សញ្ជាតិ (៩) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ១៩៤៨* | *ថ្ងៃពុធ ទី១៨ ខែកក្កដា ឆ្នាំ១៩៥៣* |
| ទីកន្លែងកំណើត (១១) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្ត ក្រុង ប្រទេស | | *ភូមិកណ្ដាល ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| មុខរបរពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១២) | | *គ្រូបង្រៀន* | *ជាងកាត់ដេរ* |
| ទីលំនៅពេលចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៣) | | *ភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | *ភូមិសំប៉ានលើ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា* |
| ថ្ងៃ ខែ ឆ្នាំចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៤) | | *ថ្ងៃ សុក្រ ទី ១៥ ខែ សីហា ឆ្នាំ ២០០៥* | |
| ទីកន្លែងចុះបញ្ជីបញ្ជាក់អាពាហ៍ពិពាហ៍ (១៥) | | *ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល* | |
| អំពីឪពុក ម្ដាយ | | ខាងប្ដី | ខាងប្រពន្ធ |
| នាមត្រកូល និង នាមខ្លួនឪពុក (១៦) | | *ទេព សួង* | *កៅ សៀម* |
| ជាអក្សរឡាតាំង (១៧) | | TEP SUONG | KAO SEAM |
| សញ្ជាតិ (១៨) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩២៣* | *ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩២២* |
| នាមត្រកូល និង នាមខ្លួនម្ដាយ (២០) | | *ប្រាក់ សម្បត្តិ* | *សុខ សន* |
| ជាអក្សរឡាតាំង (២១) | | PRAK SAMBATH | SOK SAN |
| សញ្ជាតិ (២២) | | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩២៥* | *ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩២៦* |

លេខ (ក)..... *០៥ ស.ប.អ* ............
យើង (ខ).... *អភិបាលស្រុកស្អាង* .........................
បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្ដាំនេះ ជាហត្ថលេខា
របស់លោក (គ)......គុង្គ *គឹមយ៉ន.......* ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន (ឃ)......ស្រុកស្អាង..........ពិតប្រាកដមែន។
(ង) ធ្វើនៅ...ស្អាង.... ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២
(ច) *ហត្ថលេខា និងត្រា*
*ខឹម ច័ន្ទគិរី*

(២៤) ធ្វើនៅ....ស្អាង ..... ថ្ងៃទី *២៣* ខែ *មករា* ឆ្នាំ *២០១២*

**(២៥) មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**----
*ហត្ថលេខា*
*គុង្គ គឹមយ៉ន*

**បញ្ជាក់ ÷**

☞ **ការសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្ត**

ការសុំចម្លងសំបុត្រអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចម្លងចូលក្នុងសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍សម្រាប់ប្រជាពលរដ្ឋខ្មែរដែរ រីឯសន្លឹកនៃសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ក៏ត្រូវប្រើប្រាស់សន្លឹកនៃសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ សម្រាប់ប្រជាពលរដ្ឋខ្មែរដែរ ។

### ៣.៥.៣. សម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

☞ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូល-ដ្ឋានអាពាហ៍ពិពាហ៍ និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារ តាមសំណើរបស់អ្នកមកសុំស្រង់ប៉ុណ្ណោះ ។

# ជំពូកទី៤

# អត្រានុកូលដ្ឋានមរណភាព

# ជំពូកទី៤

# អត្រានុកូលដ្ឋានមរណភាព

## ៤.១. សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

### ៤.១.១. សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

សៀវភៅអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព រួមមាន ៖

- សៀវភៅអត្រានុកូលដ្ឋានមរណភាព (សម្រាប់ប្រជាពលរដ្ឋខ្មែរ)
- សៀវភៅអត្រានុកូលដ្ឋានមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ២០០២-២០០៧)

ចំពោះសៀវភៅចម្លងសំបុត្រមរណភាព និងសៀវភៅចម្លងសំបុត្របញ្ជាក់មរណភាព មិនចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ។

### ៤.១.២. ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព រួមមាន ៖

- សំបុត្រមរណភាព
- សំបុត្របញ្ជាក់មរណភាព (បានអនុវត្តនៅក្នុងអំឡុងឆ្នាំ ២០០២-២០០៧)
- សេចក្តីចម្លងសំបុត្រមរណភាព (ក្នុងឆ្នាំសម្រាប់ចម្លងនៅឃុំ សង្កាត់ និងដាច់ឆ្នាំសម្រាប់ចម្លងនៅ ក្រុង ស្រុក ខណ្ឌ)
- សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព (សម្រាប់ចម្លងនៅក្រុង ស្រុក ខណ្ឌ)

## ៤.២. ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព

☞ ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្នុងក្រសួងស្ថាប័នអង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់**ឱ្យទាន់ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព**។

☞ ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ចាប់ពីថ្ងៃទទួលមរណភាព។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្តល់សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ ជូនចំពោះក្រុមគ្រួសារ ឬសាច់ញាតិសន្តានដែលមករាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពឱ្យអ្នកស្លាប់ ក្នុងរយៈពេលកំណត់ ១៥ថ្ងៃ។

☞ ករណីមានអ្នកស្លាប់ទុកឱ្យហួសរយៈពេលដែលកំណត់ដោយច្បាប់ ត្រូវអនុវត្តដូចខាងក្រោម៖

- បើមានអ្នកស្លាប់ទុកឱ្យហួសរយៈពេល១៥ថ្ងៃ នៅក្នុងឆ្នាំពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ចៅសង្កាត់សាមីនៃលំនៅឋានពិត

ប្រាកដរបស់អ្នកស្លាប់។ ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនេះត្រូវបង់ថ្លៃ ១.០០០រៀល (មួយពាន់រៀលគត់) សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅនៅក្នុងខេត្តឧត្តរមានជ័យ រតនគិរី ព្រះវិហារ មណ្ឌលគិរី ស្ទឹងត្រែង និង ៤.០០០រៀល (បួនពាន់រៀលគត់) សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅក្រៅពីខេត្តខាងលើ។

- បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសាលក្រមពីសាលាដំបូងរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន។

☞ បើមានសាលក្រមបញ្ជាក់ពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីអត្រានុកូលដ្ឋានមរណភាព ។

**បញ្ជាក់ ÷**

☞ ចំពោះអ្នកស្លាប់នៅចុងខែធ្នូ នៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល១៥ថ្ងៃអាចឆ្លងចូលឆ្នាំបន្ទាប់ ក្រុមគ្រួសារនៃអ្នកស្លាប់អាចប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅក្នុងឆ្នាំកំពុងអនុវត្ត ឬនៅឆ្នាំបន្ទាប់បាន

☞ ចំពោះអ្នកស្លាប់នៅចុងខែធ្នូ នៃឆ្នាំកំពុងអនុវត្ត ហើយរយៈពេល១៥ថ្ងៃឆ្លងចូលឆ្នាំបន្ទាប់ តែទុកឱ្យហួសរយៈពេលកំណត់១៥ថ្ងៃ ក្រុមគ្រួសារនៃអ្នកស្លាប់អាចប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឆ្នាំ បន្ទាប់បាន ដោយត្រូវអនុវត្តទៅតាមបែបបទនៃករណីអ្នកទទួលមរណភាពទុកឱ្យហួសរយៈពេល ១៥ថ្ងៃ។

### ៤.២.១. លិខិតស្នាមនានាដែលពាក់ព័ន្ធនឹងសព

**ក). ករណីការចុះអត្រានុកូលដ្ឋានមរណភាព ក្នុងរយៈពេលកំណត់១៥ថ្ងៃ**

☞ អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម ៖

- លិខិតជូនដំណឹងមរណភាព ៖
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
  - <u>លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់បានស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ</u>
  - លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬ

  - លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព បើស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព។
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)។
- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់

សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្ត ត្រូវមានឯកសារបន្ថែមទៀត ៖

- លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលនៅមានសុពលភាព
- ទិដ្ឋាការ ឬប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅមានសុពលភាព។
- ករណីឯកសារណាមួយខាងលើនេះបាត់បង់ ត្រូវមានលិខិតស្នាមនានាដែលបញ្ជាក់ពីអត្តសញ្ញាណទាក់ទងនឹងអ្នកស្លាប់ ។

| |
|---|
| **បញ្ជាក់** ៖ បើលិខិតស្នាមណាមួយមានការសង្ស័យ មន្ត្រីអត្រានុកូលដ្ឋានត្រូវទំនាក់ទំនងជាមួយនឹងសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងលិខិតស្នាមនោះ។ |

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសព ៖

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ឬ
- <u>លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ</u>
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

### ខ). ករណីការចុះអត្រានុកូលដ្ឋានមរណភាព ហួសរយៈពេលកំណត់១៥ថ្ងៃ ក្នុងឆ្នាំ

☞ អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមន្ត្រីអត្រា-នុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួន ដូចខាងក្រោម ៖

លិខិតជូនដំណឹងមរណភាព ៖

  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ បើស្លាប់ក្នុងមន្ទីរពេទ្យ ឬ
  - លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើស្លាប់ដោយរោគឆ្លង ឬ

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព បើស្លាប់នៅក្នុងក្រសួង ស្ថាប័ន ឬអង្គភាព។

• សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)។
• សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)។
• សៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកមកប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសព ៖

• ពាក្យប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពរបស់គ្រួសារនៃអ្នកស្លាប់
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ ឬ
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ឬ
• លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិ ឬ
• លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់មួយផ្សេងទៀត ករណីអ្នកស្លាប់ ទៅស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
• លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួង ស្ថាប័ន ឬអង្គភាព ឬ
• លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ករណីអ្នកទោសស្លាប់ក្នុងមណ្ឌលអប់រំកែប្រែ

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក។

**គ). ករណីការចុះអត្រានុកូលដ្ឋានមរណភាពទុកឱ្យហួសឆ្នាំ**

បើមានអ្នកស្លាប់ទុកឱ្យហួសឆ្នាំ ហើយពុំបានរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសាលក្រមពីតុលាការរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន។

**អ្នកប្ដឹងសុំត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម៖**

- សៀវភៅគ្រួសារ ឬសេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកប្ដឹងសុំ
- សាលក្រមបញ្ជាក់ពីមរណភាពរបស់តុលាការរាជធានី ខេត្តសាមី
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់ (ប្រសិនបើមាន) ឬ
- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់អ្នកប្ដឹងសុំ (ប្រសិនបើមាន) ។

☞ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងសព ៖

- សាលក្រមបញ្ជាក់ពីមរណភាពរបស់សាលាដំបូងរាជធានី ខេត្ត សាមី

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់លិខិតស្នាមដែលពាក់ព័ន្ធនឹងសពឱ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ដែលត្រូវរក្សាទុក ។

### ៤.២.២. ការសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសព

☞ ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្ដាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ច នៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជាសព ឬបញ្ចុះសពក្នុងករណីអ្នកស្លាប់ដោយជំងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ ។

☞ បើអ្នកស្លាប់ដោយជំងឺឆ្លងរាតត្បាតដែលអាចបណ្ដាលឱ្យគ្រោះថ្នាក់ដល់សង្គម មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយ-ការណ៍ទៅមន្ទីពេទ្យ ឬផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពតាមការសម្រេចនោះ ។

☞ បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យពីអំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណាដែលបានឃើញ ឬដឹងព្រឹត្តិហេតុការណ៍នោះ ត្រូវរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ភ្លាម ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន ។

☞ បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលអ្នកស្លាប់បានរស់នៅមុនពេលស្លាប់ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់នោះ ឱ្យទៅយកសពមកធ្វើបុណ្យ និងចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំ សង្កាត់ដែលអ្នកស្លាប់នោះបានរស់នៅជាប់លាប់មុនពេលស្លាប់ ។

- ☞ បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវចាត់ចែងបូជា ឬបញ្ចុះសពនោះ និងចុះសៀវភៅមរណភាពក្នុងឃុំ សង្កាត់នោះ។
- ☞ នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព ដើម្បីសុំលិខិតអនុញ្ញាតធ្វើបុណ្យបូជា ឬបញ្ចុះសព សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសុំសំបុត្រមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យមើលលិខិតស្នាម (ដូចមានបរិយាយនៅចំណុច ៤.២.១) ឱ្យបានច្បាស់លាស់ បើឃើញត្រឹមត្រូវទៅតាមការកំណត់ហើយ ត្រូវសរសេរលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពទៅតាមលក្ខណៈនៃការស្លាប់នោះ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំបូជាសព ឬបញ្ចុះសព

ខ្ញុំបាទ នាងខ្ញុំឈ្មោះ----------------------- ភេទ------ អាយុ------ឆ្នាំ សញ្ជាតិ---------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ----------- ផ្លូវលេខ----------- ក្រុមទី-------- ភូមិ------------------------ ឃុំ សង្កាត់-------------------- ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត -----------។

**គោរពជូន**

**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់**---------------------

**<u>កម្មវត្ថុ</u>** ÷ សំណើសុំអនុញ្ញាត------------------ ។

យោង ៖ (សំបុត្រចេញដោយមន្ទីរពេទ្យ ឬលិខិតជូនស្តីពីមរណភាពចេញដោយមេភូមិ ឬកំណត់ហេតុ របស់សមត្ថកិច្ចជំនាញ....) ។

តាមកម្មវត្ថុខាងលើ សូមជំរាបលោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋាន មេត្តាជ្រាបថា ឈ្មោះ----------- ភេទ------ អាយុ------ឆ្នាំ សញ្ជាតិ--------------- មានទីលំនៅមុនស្លាប់ ផ្ទះលេខ--------- ផ្លូវលេខ-------- ក្រុមទី-------- ភូមិ------------------ ឃុំ សង្កាត់--------------------- ក្រុង ស្រុក ខណ្ឌ---------------- រាជធានី ខេត្ត --------------- ដែលត្រូវជា------------របស់ខ្ញុំបាទ នាងខ្ញុំ បានទទួលមរណភាពកាលពីថ្ងៃ-------- ទី----- ខែ--------- ឆ្នាំ------ វេលាម៉ោង------------------- ដោយមូលហេតុ-------------------------------- នៅ-------------------------------------ហើយសពនេះ ត្រូវយកទៅបូជា ឬបញ្ចុះនៅ------------------------- ថ្ងៃទី----- ខែ---------- ឆ្នាំ------ វេលាម៉ោង-------------។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋាន មេត្តាអនុញ្ញាតឱ្យខ្ញុំបាទ នាងខ្ញុំបានធ្វើបុណ្យបូជាសព ឬបញ្ចុះសព ដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី------ ខែ---------- ឆ្នាំ-------

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ៖---------------

ក្រុង ស្រុក ខណ្ឌ ៖---------------

ឃុំ សង្កាត់ ៖---------------

ភូមិ ៖--------------- ថ្ងៃទី------ ខែ--------- ឆ្នាំ------

## លិខិតជូនដំណឹងស្តីពីមរណភាព

យើង-------------------- ជាមេភូមិ-------------------- នៃឃុំ សង្កាត់-------------------- ក្រុង ស្រុក ខណ្ឌ----------------- រាជធានី ខេត្ត ----------------- សូមបញ្ជាក់ថា ឈ្មោះ------------------- ភេទ----- កើតនៅថ្ងៃទី----- ខែ--------- ឆ្នាំ------ នៅផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុម-------- ភូមិ------------- ឃុំ សង្កាត់------------- ក្រុង ស្រុក ខណ្ឌ--------------- រាជធានី ខេត្ត ------------- ឪពុកឈ្មោះ---------------- កើតនៅថ្ងៃទី----- ខែ-------- ឆ្នាំ------ ម្តាយឈ្មោះ--------------- កើតនៅថ្ងៃទី------ ខែ---------- ឆ្នាំ-------- មានទីលំនៅបច្ចុប្បន្ន នៅភូមិ-------------- ឃុំ សង្កាត់---------------- ក្រុង ស្រុក ខណ្ឌ----------------- រាជធានី ខេត្ត ------------- បានទទួលមរណភាព នៅថ្ងៃ------ ទី----- ខែ------- ឆ្នាំ------ វេលាម៉ោង---------- នៅផ្ទះលេខ----------- ផ្លូវលេខ---------- ក្រុម--------- ភូមិ--------------- ឃុំ សង្កាត់---------------- រាជធានី ស្រុក ខណ្ឌ-------------- រាជធានី ខេត្ត --------------ដោយមូលហេតុ----------------------------------- ស្ថានភាពសព ៖ នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ។

**មេភូមិ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យប្តឹងសុំសំបុត្រអត្រានុកូលដ្ឋានមរណភាព

ខ្ញុំបាទ នាងខ្ញុំឈ្មោះ-------------------------- សញ្ជាតិ---------- ឆ្នាំកំណើត----------- មុខរបរបច្ចុប្បន្ន-------------------------------------------------------------------------------------------- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ---------- ផ្លូវលេខ--------- ក្រុម-------- ភូមិ----------- ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ------------- ។

**គោរពជូន**
**មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់---------------------**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ឱ្យឈ្មោះ-------------------- ។

**<u>យោង</u>** ៖ លិខិត------------------------------------- លេខ---------- ចុះថ្ងៃទី------ ខែ---------
ឆ្នាំ--------- របស់------------------------------------------------------------------ ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមជម្រាបជូន លោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋាន មេត្តាជ្រាបថា ឈ្មោះ-------------------------- ត្រូវជា------------- ពុំទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឡើយ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមន្ត្រីអត្រានុកូលដ្ឋានមេត្តាចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព តាមសំណើខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។

ធ្វើនៅថ្ងៃទី------- ខែ----------- ឆ្នាំ--------
**ស្នាមមេដៃស្តាំអ្នកប្តឹង**

<u>សូមជូនភ្ជាប់មកជាមួយនូវ</u> ៖

– --------------------------
– --------------------------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ............................
ក្រុង ស្រុក ខណ្ឌ ............................
ឃុំ សង្កាត់ ............................
លេខ ---------------                                   ថ្ងៃទី......... ខែ........................ ឆ្នាំ..........

## លិខិតអនុញ្ញាតបូជាសព ឬបញ្ចុះសព

– យោងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ។
– យោងលិខិតចុះថ្ងៃទី------ ខែ--------ឆ្នាំ------ ស្តីពីសំណើសុំអនុញ្ញាតបូជា ឬបញ្ចុះសព ។
– យោងលិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយ------------------------------------------- ។

**យើងមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់**-------------------

អនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពឈ្មោះ--------------------- ភេទ------- អាយុ-------ឆ្នាំ សញ្ជាតិ----------- មានទីលំនៅមុនស្លាប់ ផ្ទះលេខ----- ផ្លូវលេខ----- ក្រុមទី----- ភូមិ---------------ឃុំ សង្កាត់----------------- ក្រុង ស្រុក ខណ្ឌ------------ រាជធានី ខេត្ត ----------------- ដែលបានទទួល មរណភាពកាលពីថ្ងៃ------ ទី------ ខែ------------- ឆ្នាំ-------- វេលាម៉ោង------------------ ដោយ មូលហេតុ -------------------------------- នៅ-----------------------------------------ដើម្បីយកទៅបូជា ឬបញ្ចុះ នៅ---------------------------------- ----------------------------------------------------------------------- ថ្ងៃទី----- ខែ----------- ឆ្នាំ------ វេលាម៉ោង------------ ។

សូមបណ្តាអង្គភាពមានសមត្ថកិច្ច មេត្តាទទួលស្គាល់ និងជួយសហការ ។

**មន្ត្រីអត្រានុកូលដ្ឋាន**
**មេឃុំ ចៅសង្កាត់**

### ៤.២.៣. ការសរសេរចុះបញ្ជីមរណភាព

#### ក). សម្រាប់ប្រជាពលរដ្ឋខ្មែរ

☞ នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព និង បន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីមរណភាពចំនួន០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពភ្លោះ។

☞ របៀបសរសេរចុះបញ្ជីមរណភាព នៃសៀវភៅអត្រានុកូលដ្ឋានមរណភាពដែលបានចុះលេខ និងចុះឆ្នាំរួចហើយ មានដូចខាងក្រោម ៖

១). រាជធានី ខេត្ត ៖ ត្រូវសរសេរដូចក្របខាងមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាព។

២). ក្រុង ស្រុក ខណ្ឌ ៖ ត្រូវសរសេរដូចក្របខាងមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាព។

៣). ឃុំ សង្កាត់ ៖ ត្រូវសរសេរដូចក្របខាងមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាព។

៤). លេខ ៖ ត្រូវសរសេរលេខរៀងបញ្ជីមរណភាព។ លេខរៀងបញ្ជីមរណភាពដែលត្រូវសរសេរចុះ គឺសរសេរ ២ខ្ទង់ ចាប់ផ្តើមពីលេខ ០១ ដោយសរសេរជាលេខខ្មែរ។

៥). សៀវភៅមរណភាពលេខ ៖ ត្រូវសរសេរលេខសៀវភៅដូចលេខដែលចុះនៅក្របមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាពដែលកំពុងសរសេរ។

៦). ឆ្នាំ ៖ ត្រូវសរសេរឆ្នាំដែលចុះនៅក្របមុខនៃសៀវភៅអត្រានុកូលដ្ឋានមរណភាពដែលកំពុងសរសេរ។

៧). នាមត្រកូល ៖ ត្រូវសរសេរនាមត្រកូលរបស់អ្នកស្លាប់។
បញ្ជាក់ ៖ បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន នៅត្រង់ខ្ទង់ "នាមត្រកូល" ទុកចំហចោល ដូច្នេះ នៅត្រង់ខ្ទង់ "នាមត្រកូល" នៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវទុកចំហចោលដែរ។

៨). នាមខ្លួនសព ៖ ត្រូវសរសេរនាមខ្លួនរបស់អ្នកស្លាប់។

៩). ភេទ ៖ ត្រូវសរសេរភេទរបស់អ្នកស្លាប់។

១០). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់អ្នកស្លាប់។

១១). ជាអក្សរឡាតាំង ៖

- នាមត្រកូល ៖ ត្រូវសរសេរនាមត្រកូលអ្នកស្លាប់ជាអក្សរឡាតាំង។
- នាមខ្លួន ៖ ត្រូវសរសេរនាមខ្លួនអ្នកស្លាប់ជាអក្សរឡាតាំង។

បញ្ជាក់ ៖ បើពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកឱ្យនៅទំនេរពុំចាំបាច់សរសេរក៏បាន

១២). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ត្រូវសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកស្លាប់ ដោយសរសេរថ្ងៃជាអក្សរ ខ្មែរទីជាលេខខ្មែរ ខែជាអក្សរខ្មែរ តាមសុរិយគតិ និងឆ្នាំជាលេខខ្មែរ តាមគ្រិស្តសករាជ។

១៣). ទីកន្លែងកំណើត ៖ ត្រូវសរសេរឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និងប្រទេសរបស់អ្នកស្លាប់។

១៤). ស្ថានភាពសព: ត្រូវបញ្ជាក់អំពីអ្នកស្លាប់ បើនៅលីវត្រូវសរសេរ "លីវ" បើមានប្តី ត្រូវសរសេរ "មានប្តី" បើមានប្រពន្ធ ត្រូវសរសេរ "មានប្រពន្ធ" បើពោះម៉ាយ ត្រូវសរសេរ "ពោះម៉ាយ" បើមេម៉ាយ ត្រូវសរសេរ "មេម៉ាយ" ។

១៥). មុខរបររបស់សពមុនពេលស្លាប់ ៖ ត្រូវសរសេរតែមុខរបររបស់អ្នកស្លាប់មុនពេលស្លាប់ប៉ុណ្ណោះ ។

១៦). ទីលំនៅរបស់សពមុនពេលស្លាប់ ៖ ត្រូវសរសេរតែទីលំនៅរបស់អ្នកស្លាប់មុនពេលស្លាប់ប៉ុណ្ណោះ អំពី លេខផ្ទះ លេខផ្លូវ (បើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ខេត្ត និង ប្រទេស ។

១៧). លេខអត្តសញ្ញាណប័ណ្ណ ៖ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណនៃអ្នកស្លាប់ (ប្រសិនបើមាន) ។

១៨). ថ្ងៃ ខែ ឆ្នាំដែលស្លាប់ ៖ ត្រូវសរសេរថ្ងៃជាអក្សរខ្មែរ ទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរ តាមគ្រិស្តសករាជ ។ **ឧទាហរណ៍:** ថ្ងៃអង្គារ ទី២៧ ខែមិថុនា ឆ្នាំ២០១២ ។

១៩). ទីកន្លែងដែលស្លាប់ ៖ ត្រូវសរសេរពីទីកន្លែងដែលអ្នកស្លាប់បានស្លាប់នៅទីនោះ ត្រូវសរសេរឈ្មោះ ភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេសកម្ពុជា ។

**ឧទាហរណ៍** ÷ ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល ។

២០). មូលហេតុដែលស្លាប់តាមបណ្តឹងអ្នករាយការណ៍ ៖ ត្រូវសរសេរអំពីមូលហេតុលម្អិតច្បាស់លាស់ ពិតប្រាកដនៃអ្នកស្លាប់ តាមការផ្តល់ព័ត៌មានពីអ្នករាយការណ៍ ។ (បើស្លាប់ដោយជំងឺ ត្រូវសរសេរ បញ្ជាក់ឱ្យបានច្បាស់អំពីប្រភេទជំងឺ )

**ឪពុកសព**

**បញ្ជាក់** ៖

- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ពុំមានសរសេរអ្វីនៅផ្នែកឪពុក ដូច្នេះ នៅផ្នែកឪពុកនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវទុកឱ្យនៅទំនេរដែរ (មិនសរសេរ អ្វីទាំងអស់) ។
- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន សរសេរ "មិនស្គាល់" នៅផ្នែកឪពុក ដូច្នេះនៅផ្នែកឪពុកនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវសរសេរ "មិនស្គាល់" ដែរ ។

២១). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនរបស់ឪពុកនៃអ្នកស្លាប់

២២). សញ្ជាតិ ៖ ត្រូវសរសេរអំពីសញ្ជាតិរបស់ឪពុកនៃអ្នកស្លាប់ ។

២៣). រស់ ឬស្លាប់ ៖ បើនៅរស់ត្រូវឆូតចោល "ស្លាប់" បើស្លាប់ត្រូវឆូតចោល "រស់" ។

២៤). ជាអក្សរឡាតាំង ៖ សរសេរជាអក្សរឡាតាំងនូវនាមត្រកូល និងនាមខ្លួនរបស់ឪពុកនៃអ្នកស្លាប់ ។ បើពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកទំនេរពុំចាំបាច់សរសេរក៏បានដែរ ។

២៥). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរអំពីថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុកនៃអ្នកស្លាប់ ។

**ឧទាហរណ៍** ÷ ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩១០ ។

**ម្តាយសព**

**បញ្ជាក់** ៖

- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ពុំមានសរសេរអ្វីនៅផ្នែកម្ដាយ ដូច្នេះ នៅផ្នែកម្ដាយនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវទុកឱ្យនៅទំនេរដែរ (មិនសរសេរ អ្វីទាំងអស់) ។
- បើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន សរសេរ "មិនស្គាល់" នៅផ្នែកម្ដាយ ដូច្នេះ នៅផ្នែកម្ដាយនៃបញ្ជីមរណភាព និងសំបុត្រមរណភាព ក៏ត្រូវសរសេរ "មិនស្គាល់" ដែរ ។

២៦). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនរបស់ម្ដាយនៃអ្នកស្លាប់ ។

២៧). សញ្ជាតិ ៖ ត្រូវសរសេរពីសញ្ជាតិរបស់ម្ដាយនៃអ្នកស្លាប់ ។

២៨). រស់ ឬស្លាប់ ៖ បើនៅរស់ត្រូវឆូតចោល "ស្លាប់" បើស្លាប់ត្រូវឆូតចោល "រស់" ។

២៩). ជាអក្សរឡាតាំង ៖ ត្រូវសរសេរជាអក្សរឡាតាំងនូវនាមត្រកូល និងនាមខ្លួនរបស់ម្ដាយនៃអ្នកស្លាប់ ។ បើពុំអាចសរសេរជាអក្សរឡាតាំងបាន អាចទុកឱ្យនៅទំនេរ ពុំចាំបាច់សរសេរក៏បាន ។

៣០). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរអំពីថ្ងៃ ខែ ឆ្នាំកំណើតរបស់ម្ដាយនៃអ្នកស្លាប់ ។

**ឧទាហរណ៍** ÷ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩១២ ។

**អ្នករាយការណ៍អំពីសព**

៣១). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួននៃអ្នកមករាយការណ៍អំពីអ្នកស្លាប់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និង សំបុត្រមរណភាព ។

៣២). ភេទ ៖ ត្រូវសរសេរភេទរបស់អ្នករាយការណ៍ ។

៣៣). សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិរបស់អ្នករាយការណ៍ ។

៣៤). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ត្រូវសរសេរអំពីថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នករាយការណ៍ពីអ្នកស្លាប់ ។

៣៥). ត្រូវជាអ្វីនឹងសព ៖ ត្រូវសរសេរពីការពាក់ព័ន្ធ ជាឪពុក ម្ដាយ ឬកូន ឬសាច់ញាតិសន្ដាន ឬ អ្នកជិតខាងនៃអ្នកស្លាប់ ។

**ឧទាហរណ៍** ÷ បើជាកូនបង្កើតត្រូវសរសេរ "កូនបង្កើត" បើជាប្រពន្ធត្រូវសរសេរ "ប្រពន្ធ" បើជាមាបង្កើតត្រូវសរសេរ "មាបង្កើត" ។

៣៦). មុខរបរបច្ចុប្បន្ន ៖ ត្រូវសរសេរអំពីមុខរបរបច្ចុប្បន្នរបស់អ្នករាយការណ៍ពីអ្នកស្លាប់ ។

៣៧). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរអំពីទីលំនៅបច្ចុប្បន្នរបស់អ្នករាយការណ៍ពីអ្នកស្លាប់ អំពីលេខផ្ទះ លេខផ្លូវ (ប្រសិនបើមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស ។

៣៨). លេខអត្តសញ្ញាណប័ណ្ណ ៖ ត្រូវសរសេរលេខអត្តសញ្ញាណប័ណ្ណរបស់អ្នករាយការណ៍ពីអ្នកស្លាប់ (ប្រសិនបើមាន) ។

**បញ្ជាក់:** ពេលដែលសរសេរបំពេញក្នុងខ្ទង់ខាងលើនេះចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍ពិនិត្យមើល។ ក្នុងករណីអ្នកមករាយការណ៍មិនចេះអក្សរ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវអានឱ្យអ្នកមករាយការណ៍ស្តាប់គ្រប់ចំណុចទាំងអស់ ហើយបើឃើញថាត្រឹមត្រូវ និងឯកភាពហើយ មន្ត្រីអត្រានុ-កូលដ្ឋានត្រូវអនុវត្តដូចខាងក្រោម ៖

៣៩). ស្នាមមេដៃស្តាំរបស់អ្នករាយការណ៍ ៖ ត្រូវផ្តិតមេដៃស្តាំរបស់អ្នករាយការណ៍អំពីមរណភាពទុកជាភស្តុតាង ក្រោយពេលឯកភាពថាត្រឹមត្រូវ។ បន្ទាប់មកសរសេរឈ្មោះរបស់អ្នករាយការណ៍ ពីក្រោមស្នាមមេដៃ។

៤០). ធ្វើនៅ-----ថ្ងៃទី--- ខែ----- ឆ្នាំ----- ៖ ត្រូវសរសេរឈ្មោះនៃឃុំ ឬសង្កាត់ ទីកន្លែងដែលសុំចុះសៀវភៅអត្រានុកូលដ្ឋាន និង ចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរ តាមសុរិយគតិ និងឆ្នាំជាលេខខ្មែរតាមគ្រិស្តសករាជ។ **ឧទាហរណ៍:** ធ្វើនៅកោះកែរ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

៤១). មន្ត្រីអត្រានុកូលដ្ឋាន ៖ ត្រូវសរសេរពីក្រោមពាក្យមន្ត្រីអត្រានុកូលដ្ឋានថា មេឃុំ ឬចៅសង្កាត់ បើមេឃុំ ឬចៅសង្កាត់អវត្តមាន ជំទប់ ចៅសង្កាត់រង និងទទួលសិទ្ធិតាមឋានានុក្រម តាមរយៈលិខិតប្រគល់សិទ្ធិជាលាយល័ក្ខណ៍អក្សរពីមេឃុំ ចៅសង្កាត់។ ក្នុងករណីនេះ ត្រូវសរសេរពីក្រោមពាក្យ "មន្ត្រីអត្រានុកូលដ្ឋាន" ដាក់ថា "មេឃុំស្តីទី" ឬ "ចៅសង្កាត់ស្តីទី"។

៤២). ហត្ថលេខា និងត្រា ៖ ត្រូវចុះហត្ថលេខាមន្ត្រីអត្រានុកូលដ្ឋាន (ក្រោមពាក្យមេឃុំ ចៅសង្កាត់ ឬមេឃុំ ចៅសង្កាត់ស្តីទី) សរសេរឈ្មោះ ឬបោះត្រាឈ្មោះអ្នកចុះហត្ថលេខាពីក្រោមហត្ថលេខា រួចបោះត្រាឃុំ ឬសង្កាត់ ពីលើផ្នែកខាងឆ្វេងមួយភាគបីនៃហត្ថលេខា និងបោះត្រាឱ្យត្រង់តួអក្សរ (ត្រាប្រើទឹកពណ៌ក្រហម)។

**បញ្ជាក់** ÷ ចំពោះពិរុទ្ធជន ឬទណ្ឌិតដែលស្លាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ

- ☞ ករណីមានពិរុទ្ធជន ឬអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ អ្នកទទួលខុសត្រូវនៃពន្ធនាគារ និងមណ្ឌលអប់រំកែប្រែនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅមន្ត្រីអត្រានុកូលដ្ឋាន នៃលំនៅឋានអចិន្ត្រៃយ៍របស់ពិរុទ្ធជន ឬទណ្ឌិតនោះ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព។
- ☞ មុខរបរ ត្រូវដាក់មុខរបរមុនពេលជាប់ជាពិរុទ្ធជន ឬទណ្ឌិត។
- ☞ ទីកន្លែងស្លាប់ ត្រូវដាក់ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេសដែល ពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែតាំងនៅ។ **ឧទាហរណ៍:** បើស្លាប់នៅពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែម១ ត្រូវសរសេរថា ៖ ភូមិកំរៀង សង្កាត់ព្រៃវែង ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**បញ្ជាក់** ÷ សាកសពដែលមិនស្គាល់

ចំពោះសាកសពដែលមិនស្គាល់ មន្ត្រីអត្រានុកូលដ្ឋាន ក៏ត្រូវសរសេរចុះក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពដែរ ដោយសរសេរយោងកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ចនៅរឹមទំព័រខាងឆ្វេងនៃបញ្ជីមរណភាព ហើយសរសេរចុះនៅក្នុងបញ្ជីមរណភាព តាមខ្លឹមសារនៃកំណត់ហេតុរបស់សមត្ថកិច្ច ដូចជា ៖

- ភេទ
- ទីកន្លែងស្លាប់ ៖ យកកន្លែងដែលឃើញសាកសព
- មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍ ៖ យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច
- ថ្ងៃ ខែ ឆ្នាំ ស្លាប់ ៖ យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ចច្បាប់ចម្លង០១ច្បាប់ ជាឯកសារនៅសាលាឃុំ សង្កាត់។

**ឧទាហរណ៍ ៤.១** ÷ ការសរសេរចុះបញ្ជីមរណភាព លេខ ០៣ តាមអត្ថបទឧទាហរណ៍ខាងក្រោម ៖

ថ្ងៃពុធ ទី២១ ខែមករា ឆ្នាំ២០១២ លោក សោម សារី បានទៅជួបមន្ត្រីអត្រាកូលដ្ឋាន ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល ដើម្បីសុំច្បាប់ធ្វើបុណ្យបូជាសព និងចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពជូនម្តាយបង្កើតរបស់គាត់ដែលស្លាប់ពីថ្ងៃអង្គារ ទី២០ ខែមករា ឆ្នាំ២០១២ នៅផ្ទះរបស់គាត់។

ប្រវត្តិតួអង្គទាក់ទងនឹងមរណភាព

១). លោក សោម សារី ៖

លោក សោម សារី មានសញ្ជាតិខ្មែរ កើតថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៤៩ នៅភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង។ គាត់ជាកសិករគ្មានអត្តសញ្ញាណប័ណ្ណ ហើយមានទីលំនៅបច្ចុប្បន្ន នៅភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល។

២). លោកយាយ ស៊ឹម វណ្ណា ជាម្តាយលោក សោម សារី ៖

លោកយាយ ស៊ឹម វណ្ណា មានសញ្ជាតិខ្មែរ កើតថ្ងៃច័ន្ទ ទី២៦ ខែតុលា ឆ្នាំ១៩៣១ នៅភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង មុនពេលស្លាប់គាត់ជាកសិករ រស់នៅជាមួយកូនឈ្មោះ សោម សារី។ គាត់ស្លាប់នៅថ្ងៃអង្គារ ទី២០ ខែមករា ឆ្នាំ២០១២ ដោយជរាពាធ។ រីឯចំណែកប្តីរបស់គាត់នៅរស់នៅឡើយ។

៣). លោក ស៊ឹម សារឿន ជាឪពុកលោកយាយ ស៊ឹម វណ្ណា ៖

លោក ស៊ឹម សារឿន មានសញ្ជាតិខ្មែរ កើតថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩១០ គាត់ស្លាប់ក្នុងឆ្នាំ១៩៧៧។

៤). លោកយាយ ស្រី នាង ជាម្តាយលោកយាយ ស៊ឹម វណ្ណា ៖

លោកយាយ ស្រី នាង មានសញ្ជាតិខ្មែរ កើតថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩១២ គាត់ស្លាប់ក្នុងឆ្នាំ១៩៧៧។

ផ្អែកតាមខ្លឹមសារខាងលើនេះ ចូរសរសេរចុះបញ្ជីមរណភាព។

ខេត្ត ~~ក្រុង~~ (១)........... *កណ្ដាល* .........
ស្រុក ~~ខណ្ឌ~~ (២)........ *ល្វាឯម* .........
ឃុំ ~~សង្កាត់~~ (៣)......... *កោះកែវ* ...........

លេខ (៤)............ *០៣* ...............................
សៀវភៅមរណភាពលេខ (៥)....០១/២០១២....
ឆ្នាំ (៦)....... *២០១២* .....................................

# បញ្ជីមរណភាព

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | *ស៊ីម* | ភេទ (៩) | សញ្ជាតិ (១០) |
| នាមខ្លួនសព (៨) | | *វណ្ណា* | *ស្រី* | *ខ្មែរ* |
| ជាអក្សរឡាតាំង (១១) | នាមត្រកូល | SIM | | |
| | នាមខ្លួនសព | VANNA | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១* | | |
| ទីកន្លែងកំណើត (១៣) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ........... *ភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា* ................. | | |
| ស្ថានភាពសព (១៤) នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *មានប្ដី* | | |
| មុខរបររបស់សពមុនពេលស្លាប់ (១៥) | | *កសិករ* | | |
| ទីលំនៅរបស់សពមុនពេលស្លាប់ (១៦) | | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | |
| លេខអត្តសញ្ញាណប័ណ្ណ (១៧) | | *គ្មាន* | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៨) | | *ថ្ងៃ អង្គារ ទី ២០ ខែ មករា ឆ្នាំ ២០១២* | | |
| ទីកន្លែងស្លាប់ (១៩) | | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | |
| មូលហេតុស្លាប់តាមបណ្ដឹងរបស់អ្នករាយការណ៍ (២០) | | *ជរាពាធ* | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (២១) | | *ស៊ីម សារឿន* | សញ្ជាតិ *ខ្មែរ* (២២) | |
| ជាអក្សរឡាតាំង (២៤) | | SIM SAROEUN | ~~រស់~~ ឬ ស្លាប់ (២៣) | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៥) | | *ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០* | | |
| នាមត្រកូល និង នាមខ្លួនម្ដាយសព (២៦) | | *ស្រី នាង* | សញ្ជាតិ *ខ្មែរ* (២៧) | |
| ជាអក្សរឡាតាំង (២៩) | | SREY NEANG | ~~រស់~~ ឬ ស្លាប់ (២៨) | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣០) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២* | | |
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍អំពីសព (៣១) | | *សោម សារី* | ភេទ (៣២) | សញ្ជាតិ (៣៣) |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៤) | | *ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៤៩* | *ប្រុស* | *ខ្មែរ* |
| ត្រូវជាអ្វីនឹងសព (៣៥) | | *កូនបង្កើត* | | |
| មុខរបរបច្ចុប្បន្ន (៣៦) | | *កសិករ* | | |
| ទីលំនៅបច្ចុប្បន្ន (៣៧) | | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | |
| លេខអត្តសញ្ញាណប័ណ្ណ (៣៨) | | *គ្មាន* | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

(៤០) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *២១* ខែ *មករា* ឆ្នាំ *២០១២*

(៣៩) **ស្នាមមេដៃស្ដាំអ្នករាយការណ៍**

*សោម សារី*

(៤១) **មន្ត្រីអត្រានុកូលដ្ឋាន**
*មេឃុំ*
(៤២) *ហត្ថលេខា និងត្រា*
*ប៊ុត ប៊ុន*

**ខ). សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា**

☞ ជនបរទេស និងជនអន្តោប្រវេសន្តរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលស្លាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ ឬអាជ្ញាធរមានសមត្ថកិច្ច អាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅសាលាឃុំ សង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់មុនពេលស្លាប់ ឬអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន។

☞ បើចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅសាលាឃុំ សង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង។

☞ របៀបសរសេរចុះបញ្ជីមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន្ត ត្រូវអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីមរណភាពរបស់ពលរដ្ឋខ្មែរដែរ លើកលែងតែចំណុចមួយចំនួន ខាងក្រោម ៖

- សញ្ជាតិ ៖ ត្រូវសរសេរសញ្ជាតិជនបរទេស និងជនអន្តោប្រវេសន្តដែលស្លាប់ (តាមលិខិតឆ្លងដែន)។
- ទីលំនៅឯបរទេស ៖ ត្រូវសរសេរទីលំនៅ នៅប្រទេសដើមរបស់អ្នកស្លាប់ជាអក្សរខ្មែរ ដោយបញ្ជាក់ពីលេខផ្ទះ ទីលំនៅនៅឯបរទេសឱ្យបានពិតប្រាកដ។
- លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃទី ខែ ឆ្នាំ ៖ ត្រូវសរសេរលេខលិខិតឆ្លងដែនរបស់អ្នក ស្លាប់ និង ថ្ងៃ ខែ ឆ្នាំ ដែលមានសុពលភាព។
- ទិដ្ឋាការ ឬបញ្ជី ប១ ឬបង្កាន់ដៃ ប៣ អនុញ្ញាតឱ្យស្នាក់នៅកម្ពុជាលេខ ថ្ងៃ ខែ ឆ្នាំ ៖ ត្រូវសរសេរលេខទិដ្ឋាការ ឬអនុញ្ញាតឱ្យស្នាក់នៅកម្ពុជា និង ថ្ងៃ ខែ ឆ្នាំដែលមានសុពលភាព។

**បញ្ជាក់** ÷ បើលិខិតឆ្លងដែន ឬទិដ្ឋាការ ឬ បញ្ជី ប១ ឬបង្កាន់ដៃ ប៣ អនុញ្ញាតឱ្យស្នាក់នៅកម្ពុជាហួសពេលកំណត់ គឺមិនអនុញ្ញាតឱ្យចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ហើយទន្ទឹមនេះមន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ ទៅមន្ត្រីមានសមត្ថកិច្ចភ្លាម។

**ខេត្ត ក្រុង** (១)................................... **លេខ** (៤)...............................................

**ស្រុក ខណ្ឌ** (២)................................... **សៀវភៅមរណភាពលេខ** (៥)....................

**ឃុំ សង្កាត់** (៣)................................... **ឆ្នាំ** (៦)...............................................

# បញ្ជីមរណភាព សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់

| | | | |
|---|---|---|---|
| នាមត្រកូល(៧) | | | ភេទ(៩) |
| នាមខ្លួនសព(៨) | | | |
| ជាអក្សរឡាតាំង(១០) | នាមត្រកូល | | |
| | នាមខ្លួនសព | | |
| សញ្ជាតិ(១១) | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត(១២) | | | |
| ទីកន្លែងកំណើត (១៣) | | | |
| ស្ថានភាពសព(នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ) (១៤) | | | |
| មុខរបរមុនពេលស្លាប់ (១៥) | | | |
| ទីលំនៅមុនពេលស្លាប់ (១៦) | | | |
| ទីលំនៅឯបរទេស (១៧) | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (១៨) | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតឱ្យស្នាក់នៅកម្ពុជាលេខ ថ្ងៃខែឆ្នាំ(១៩) | | | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (២០) | | | |
| ទីកន្លែងស្លាប់ (២១) | | | |
| មូលហេតុស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍(២២) | | | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (២៣) | | | ថ្ងៃ ខែ ឆ្នាំកំណើត (២៤) |
| ជាអក្សរឡាតាំង (២៥) | | | |
| សញ្ជាតិ(២៦) | | | |
| ទីលំនៅបច្ចុប្បន្នរបស់ឪពុកសព (២៧) | | | |
| នាមត្រកូល និង នាមខ្លួនម្តាយសព (២៨) | | | ថ្ងៃ ខែ ឆ្នាំកំណើត (២៩) |
| ជាអក្សរឡាតាំង (៣០) | | | |
| សញ្ជាតិ(៣១) | | | |
| ទីលំនៅបច្ចុប្បន្នរបស់ម្តាយសព (៣២) | | | |
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍អំពីសព(៣៣) | | ភេទ(៣៤) | សញ្ជាតិ(៣៥) |
| ជាអក្សរឡាតាំង (៣៦) | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (៣៧) | | | |
| ត្រូវជាអ្វីនឹងសព (៣៨) | | | |
| មុខរបរបច្ចុប្បន្ន (៣៩) | | | |
| ទីលំនៅបច្ចុប្បន្ន (៤០) | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹមថ្ងៃ ខែ ឆ្នាំ (៤១) | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៤២) | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យអ្នកដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះ នឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៤៤) ធ្វើនៅ................. ថ្ងៃទី......... ខែ............... ឆ្នាំ..........

(៤៣) **ស្នាមមេដៃស្តាំអ្នករាយការណ៍** (៤៥) **មន្ត្រីអត្រានុកូលដ្ឋាន**

(៤៦) ហត្ថលេខា និងត្រា

### ៤.២.៤. ការសរសេរសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានមរណភាពទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចូលទៅក្នុងសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្ន កុំឱ្យខុសពីខ្លឹមសារនៅក្នុងបញ្ជីមរណភាព ដោយដកស្រង់យកចំណុចសំខាន់ៗ ពីបញ្ជីមរណភាព ដូចខាងក្រោម ៖

ក). សម្រាប់ប្រជាពលរដ្ឋខ្មែរ

១). ខេត្ត ក្រុង ៖ ចម្លងយកចំណុចទី១ នៃបញ្ជីមរណភាព។

២). ស្រុក ខណ្ឌ ៖ ចម្លងយកចំណុចទី២ នៃបញ្ជីមរណភាព។

៣). ឃុំ សង្កាត់ ៖ ចម្លងយកចំណុចទី៣ នៃបញ្ជីមរណភាព។

៤). លេខ ៖ ចម្លងយកចំណុចទី៤ នៃបញ្ជីមរណភាព។

៥). សៀវភៅមរណភាពលេខ ៖ ចម្លងយកចំណុចទី៥ នៃបញ្ជីមរណភាព។

៦). ឆ្នាំ ៖ ចម្លងយកចំណុចទី៦ នៃបញ្ជីមរណភាព។

៧). នាមត្រកូល ៖ ចម្លងយកចំណុចទី៧ នៃបញ្ជីមរណភាព។

៨). នាមខ្លួនសព ៖ ចម្លងយកចំណុចទី៨ នៃបញ្ជីមរណភាព។

៩). ភេទ ៖ ចម្លងយកចំណុចទី៩ នៃបញ្ជីមរណភាព។

១០)). នាមត្រកូល និងនាមខ្លួនសពជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១១ នៃបញ្ជីមរណភាព។

១១). សញ្ជាតិ ៖ ចម្លងយកចំណុចទី១០ នៃបញ្ជីមរណភាព។

១២). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ចម្លងយកចំណុចទី១២ នៃបញ្ជីមរណភាព។

១៣). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី១៣ នៃបញ្ជីមរណភាព។

១៤). ស្ថានភាពសព ៖ ចម្លងយកចំណុចទី១៤ នៃបញ្ជីមរណភាព។

១៥). ថ្ងៃ ខែ ឆ្នាំ ដែលស្លាប់ ៖ ចម្លងយកចំណុចទី១៨ នៃបញ្ជីមរណភាព។

**ឪពុកសព**

១៦). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកចំណុចទី២១ នៃបញ្ជីមរណភាព។

១៧). សញ្ជាតិ ៖ ចម្លងយកចំណុចទី២២ នៃបញ្ជីមរណភាព។

១៨). ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី២៤ នៃបញ្ជីមរណភាព។

១៩). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី២៥ នៃបញ្ជីមរណភាព។

**ម្ដាយសព**

២០). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកចំណុចទី២៦ នៃបញ្ជីមរណភាព។

២១). សញ្ជាតិ ៖ ចម្លងយកចំណុចទី២៧ នៃបញ្ជីមរណភាព។

២២). ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី២៩ នៃបញ្ជីមរណភាព។

២៣). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី៣០ នៃបញ្ជីមរណភាព។

២៤). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ មើលចំណុចទី៤០ នៃបញ្ជីមរណភាព។

២៥). មន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចទី៤១ នៃបញ្ជីមរណភាព។

២៦). ហត្ថលេខា និងត្រា ៖ មើលចំណុចទី៤២ នៃបញ្ជីមរណភាព។

ខ). សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ ក្នុងព្រះរាជាណាចក្រកម្ពុជា

១). ខេត្ត ក្រុង ៖ ចម្លងយកចំណុចទី១ នៃបញ្ជីមរណភាព។

២). ស្រុក ខណ្ឌ ៖ ចម្លងយកចំណុចទី២ នៃបញ្ជីមរណភាព។

៣). ឃុំ សង្កាត់ ៖ ចម្លងយកចំណុចទី៣ នៃបញ្ជីមរណភាព។

៤). លេខ ៖ ចម្លងយកចំណុចទី៤ នៃបញ្ជីមរណភាព។

៥). សៀវភៅមរណភាពលេខ ៖ ចម្លងយកចំណុចទី៥ នៃបញ្ជីមរណភាព។

៦). ឆ្នាំ ៖ ចម្លងយកចំណុចទី៦ នៃបញ្ជីមរណភាព។

៧). នាមត្រកូល ៖ ចម្លងយកចំណុចទី៧ នៃបញ្ជីមរណភាព។

៨). នាមខ្លួនសព ៖ ចម្លងយកចំណុចទី៨ នៃបញ្ជីមរណភាព។

៩). ភេទ ៖ ចម្លងយកចំណុចទី៩ នៃបញ្ជីមរណភាព។

១០)). នាមត្រកូល និងនាមខ្លួនសពជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី១០ នៃបញ្ជីមរណភាព។

១១). សញ្ជាតិ ៖ ចម្លងយកចំណុចទី១១ នៃបញ្ជីមរណភាព។

១២). ថ្ងៃ ខែ ឆ្នាំ កំណើត ៖ ចម្លងយកចំណុចទី១២ នៃបញ្ជីមរណភាព។

១៣). ទីកន្លែងកំណើត ៖ ចម្លងយកចំណុចទី១៣ នៃបញ្ជីមរណភាព។

១៤). ស្ថានភាពសព ៖ ចម្លងយកចំណុចទី១៤ នៃបញ្ជីមរណភាព។

១៥). ថ្ងៃ ខែ ឆ្នាំ ដែលស្លាប់ ៖ ចម្លងយកចំណុចទី២០ នៃបញ្ជីមរណភាព។

**ឪពុកសព**

១៦). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកចំណុចទី២៣ នៃបញ្ជីមរណភាព។

១៧). សញ្ជាតិ ៖ ចម្លងយកចំណុចទី២៦ នៃបញ្ជីមរណភាព។

១៨). ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី២៥នៃបញ្ជីមរណភាព។

១៩). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី២៤ នៃបញ្ជីមរណភាព។

**ម្តាយសព**

២០). នាមត្រកូល និងនាមខ្លួន ៖ ចម្លងយកចំណុចទី២៨ នៃបញ្ជីមរណភាព។

២១). សញ្ជាតិ ៖ ចម្លងយកចំណុចទី៣១ នៃបញ្ជីមរណភាព។

២២). ជាអក្សរឡាតាំង ៖ ចម្លងយកចំណុចទី៣០ នៃបញ្ជីមរណភាព។

២៣). ថ្ងៃ ខែ ឆ្នាំកំណើត ៖ ចម្លងយកចំណុចទី២៩ នៃបញ្ជីមរណភាព។

២៤). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ មើលចំណុចទី៤៤ នៃបញ្ជីមរណភាព។

២៥). មន្ត្រីអត្រានុកូលដ្ឋាន ៖ មើលចំណុចទី៤៥ នៃបញ្ជីមរណភាព។

២៦). ហត្ថលេខា និងត្រា ៖ មើលចំណុចទី៤៦ នៃបញ្ជីមរណភាព។

**បញ្ជាក់ ÷**

☞ ការប្រគល់សំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក

ក្រោយពីសរសេរ ចុះហត្ថលេខា និងបោះត្រាលើបញ្ជីទាំងពីរ និងសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹករួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រមរណភាពច្បាប់ដើមនេះ ទៅឱ្យអ្នកមករាយការណ៍អំពីមរណភាពដែលសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ដោយមិនបង់ថ្លៃអ្វីឡើយ និងណែនាំឱ្យរក្សាទុកដាក់ឱ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រមរណភាពច្បាប់ដើម ជូនជាលើកទីពីរបានទេ។

☞ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រមរណភាពច្បាប់ដើម គឺជាឯកសារដែលមានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ដូច្នេះគួរធ្វើសេចក្តីចម្លងសំបុត្រមរណភាពឱ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់។

☞ នៅពេលចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងធ្វើសំបុត្រមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរដោយផ្អែកតាមខ្លឹមសារនៃសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍។

ឧទាហរណ៍៖ នៅផ្នែកឪពុកត្រង់ខ្ទង់ “នាមត្រកូល និងនាមខ្លួន” នៃសំបុត្រកំណើតបានសរសេរថា “មិនស្គាល់” ត្រូវសរសេរថា “មិនស្គាល់” ដូចគ្នានេះដែរ នៅផ្នែកឪពុករបស់សាមីខ្លួនត្រង់ខ្ទង់ “នាមត្រកូល និងនាមខ្លួន” នៃបញ្ជីមរណភាព និងសំបុត្រមរណភាព។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| | |
|---|---|
| **ខេត្ត** ~~**ក្រុង**~~ (១) ---- *កណ្តាល* ------ | **លេខ** (៤)--------- *០៣* -------------------- |
| **ស្រុក** ~~**ខណ្ឌ**~~ (២) ----- *ល្វាឯម* ------ | **សៀវភៅមរណភាពលេខ** (៥)--០១/២០១២-- |
| **ឃុំ** ~~**សង្កាត់**~~ (៣) ----- *កោះកែវ* ------ | **ឆ្នាំ** (៦)----------- *២០១២* ------------------ |

## សំបុត្រមរណភាព

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | *ស៊ីម* | ភេទ (៨) |
| នាមខ្លួនសព (៨) | | *វណ្ណា* | *ស្រី* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | SIM | |
| | នាមខ្លួនសព | VANNA | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | .........ភូមិបឹង *ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា* ...................................................... | |
| ស្ថានភាពសព (១៤)<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *មានប្តី* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៥) | | *ថ្ងៃ អង្គារ ទី ២០ ខែ មករា ឆ្នាំ ២០១២* | |
| នាមត្រកូល និង នាមខ្លួនឪពុកសព (១៦) | | *ស៊ីម សារឿន* | សញ្ជាតិ (១៧) |
| ជាអក្សរឡាតាំង (១៨) | | *SIM SAROEUN* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | *ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០* | |
| នាមត្រកូល និង នាមខ្លួនម្តាយសព (២០) | | *ស្រី នាង* | សញ្ជាតិ (២១) |
| ជាអក្សរឡាតាំង (២២) | | *SREY NEANG* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៣) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២* | |

(២៤) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *២១* ខែ *មករា* ឆ្នាំ *២០១២*

(២៥) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២៦) *ហត្ថលេខា និងត្រា*

*ប៊ុត ប៊ុន*

## ៤.៣. សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព

☞ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព ក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ សង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ហើយត្រូវបោះត្រាផង ។

☞ ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាក្រុង ស្រុក ខណ្ឌ

- បើសុំចម្លង ឬសម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុ-កូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះដោយអភិបាលក្រុង ស្រុក ខណ្ឌ និងបោះត្រាផង ។

☞ ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ៖

- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ (ភារធារី) ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង ។
- ការសុំចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្រមរណភាព ត្រូវយកសំបុត្រមរណភាពច្បាប់ដើមមកជាមួយ ។

☞ អ្នកមកសុំចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ត្រូវយកសំបុត្របញ្ជាក់មរណភាពច្បាប់ដើមមកជាមួយ ។
**បញ្ជាក់** ៖ ករណីបាត់បង់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម អ្នកមកសុំអាចមកសុំចម្លងបាន ត្រូវមានល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

- រាយការណ៍ជាលាយលក្ខអក្សរឱ្យបានច្បាស់សាល់ អំពីមូលហេតុនៃការបាត់បង់

- បញ្ជាក់ពីឃុំ ឬសង្កាត់ លេខសៀវភៅ ឬលេខបញ្ជី និង ឆ្នាំដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន ដើម្បីមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅងាយស្រួលក្នុងការស្វែងរក ។

### ៤.៣.១. ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព

☞ មន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ដែលអ្នកមកសុំចម្លងយកមក ដោយធ្វើការ ៖

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពនោះ ពិតជាត្រឹមត្រូវដែលចេញដោយក្រសួងមហាផ្ទៃ មែនដែរឬទេ?
- ផ្ទៀងផ្ទាត់សំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពនោះ ជាមួយបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាព ឬក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព នូវចំណុចមួយចំនួនដូចខាងក្រោម:
  – ឆ្នាំដែលអនុវត្តនៃសៀវភៅអត្រានុកូលដ្ឋាន
  – លេខសៀវភៅអត្រានុកូលដ្ឋាន

– លេខបញ្ជីអត្រានុកូលដ្ឋាន

☞ នៅពេលពិនិត្យសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព ឃើញថាជាសំបុត្រច្បាប់ដើមពិតប្រាកដហើយ ទើបមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្តើមសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព។

☞ ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព ដោយចម្លងចេញពី ៖

- សៀវភៅអត្រានុកូលដ្ឋានមរណភាព បើសុំចម្លងសំបុត្រមរណភាព។
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព បើសុំចម្លងសំបុត្របញ្ជាក់មរណភាព។

☞ របៀបសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព ដូចខាងក្រោម ៖

១). លេខរៀង ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពីលេខ០១។

២). ថ្ងៃខែឆ្នាំចេញសេចក្តីចម្លងៈ ត្រូវចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខខ្មែរ តាមគ្រិស្តសករាជ គឺជាថ្ងៃ ខែ ឆ្នាំ ដែលមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ចុះហត្ថលេខា លើសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព។

៣). ចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព ៖

- បើចម្លងសំបុត្រមរណភាព ត្រូវសរសេរក្នុងខ្ទង់នេះថា "ចម្លងសំបុត្រមរណភាព"។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវសរសេរក្នុងខ្ទង់នេះថា "ចម្លងសំបុត្របញ្ជាក់មរណភាព"

**សៀវភៅ**

៤). លេខ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី៥ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី៥ នៃបញ្ជីបញ្ជាក់មរណភាព។

៥). ឃុំ សង្កាត់ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី៣ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី៣ នៃបញ្ជីបញ្ជាក់មរណភាព។

**សំបុត្រ**

៦). លេខ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី៤ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី៤ នៃបញ្ជីបញ្ជាក់មរណភាព។

៧). ចុះថ្ងៃ ខែ ឆ្នាំ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី៤០ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី៤៥ នៃបញ្ជីបញ្ជាក់មរណភាព។

**សព**

៨). នាមត្រកូល និងនាមខ្លួន ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី៧ និងទី៨ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី៧-៨ នៃបញ្ជីបញ្ជាក់មរណភាព។

៩). ភេទ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី៩ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី៩ នៃបញ្ជីបញ្ជាក់មរណភាព។

១០). សញ្ជាតិ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី១០ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី១០ នៃបញ្ជីបញ្ជាក់មរណភាព។

១១). ថ្ងៃ ខែ ឆ្នាំកំណើត ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី១២ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី១២ នៃបញ្ជីបញ្ជាក់មរណភាព។

១២). ថ្ងៃ ខែ ឆ្នាំស្លាប់ ៖

- បើចម្លងសំបុត្រមរណភាព ត្រូវចម្លងយកពីចំណុចទី១៨ នៃបញ្ជីមរណភាព។
- បើចម្លងសំបុត្របញ្ជាក់មរណភាព ត្រូវចម្លងយកពីចំណុចទី១៨ នៃបញ្ជីបញ្ជាក់មរណភាព។

**អ្នកសុំចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព**

១៣). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួន របស់អ្នកមកសុំចម្លងសំបុត្រមរណភាព ឬអ្នកមកសុំចម្លងសំបុត្របញ្ជាក់មរណភាព។

១៤). ទីលំនៅបច្ចុប្បន្ន ៖ ត្រូវសរសេរទីលំនៅបច្ចុប្បន្ន របស់អ្នកមកសុំចម្លងសំបុត្រមរណភាព ឬអ្នកមកសុំចម្លងសំបុត្របញ្ជាក់មរណភាព ដោយសរសេរលេខផ្ទះ លេខផ្លូវ (បើសិនជាមាន) ឈ្មោះភូមិ ឃុំ ឬសង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត និង ប្រទេស។

១៥). ត្រូវជាអ្វីនឹងសព ៖ ត្រូវសរសេរពីការពាក់ព័ន្ធ ជាឪពុក ម្តាយ កូន សាច់ញាតិសន្តាន ឬអ្នកជិតខាងនៃអ្នកស្លាប់។ **ឧទាហរណ៍:** បើជាកូនបង្កើតសរសេរ "កូនបង្កើត" បើជាប្រពន្ធសរសេរ "ប្រពន្ធ"។

១៦). ស្នាមមេដៃស្តាំ ៖ ក្រោយពីសរសេរបំពេញគ្រប់ខ្ទង់រួចហើយ ត្រូវឱ្យអ្នកមកសុំចម្លង ផ្តិតមេដៃស្តាំ។

**មន្ត្រីចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព**

១៧). នាមត្រកូល និងនាមខ្លួន ៖ ត្រូវសរសេរនាមត្រកូល និងនាមខ្លួនអ្នកដែលចុះហត្ថលេខាលើសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព។

១៨). មុខងារ ៖ ត្រូវសរសេរមុខងាររបស់មន្ត្រីដែលមានឈ្មោះនៅចំណុច១៧ ៖

- អាចសរសេរ"មេឃុំ" ឬ "ចៅសង្កាត់" បើគាត់ជាមេឃុំ ឬចៅសង្កាត់។ អាចសរសេរ "ជំទប់ទី១" ឬ "ចៅសង្កាត់រងទី១" បើគាត់បានទទួលការផ្ទេរសិទ្ធិ។

- អាចសរសេរ "ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ" បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុ-កូលដ្ឋាននៅសាលាក្រុង ស្រុក ខណ្ឌ។
- អាចសរសេរ "ប្រធានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន" បើគាត់ជាមន្ត្រីរក្សាសៀវភៅអត្រានុ-កូលដ្ឋាននៅសាលារាជធានី ខេត្ត ។

១៩). ចំនួនសន្លឹកចម្លង ៖ ត្រូវសរសេរចំនួនសន្លឹកនៃសេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព ដែលបានចម្លង ដោយសរសេរជាលេខខ្មែរ។

២០). សេចក្តីផ្សេងៗ ៖ បើមានករណីពិសេសដែលគ្មានរៀបរាប់ក្នុងចំណុចទាំង១៩នោះទេ ត្រូវសរសេរក្នុងសេចក្តីផ្សេងៗនេះ។ បើគ្មានករណីពិសេសទេ មិនត្រូវសរសេរអ្វីឡើយ ដោយទុកឱ្យនៅទំនេរ។

**ឧទាហរណ៍** ÷ ការចម្លងលើកទី២ ស្នាមមេដៃឆ្វេង (បើអ្នកមកសុំចម្លងពុំមានមេដៃស្តាំ)។ល។

**ឧទាហរណ៍ ៤.៣** ÷ ការសរសេរសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព នៅសាលាឃុំ សង្កាត់ តាមឧទាហរណ៍ ដូចខាងក្រោម ៖

ថ្ងៃច័ន្ទ ទី១៥ ខែមីនា ឆ្នាំ២០១២ លោក សោម សារី បានទៅសុំចម្លងសំបុត្រមរណភាពរបស់ម្តាយគាត់ឈ្មោះ ស៊ឹម វណ្ណា ចំនួន០៥សន្លឹក ដោយកាន់យកទៅជាមួយនូវសំបុត្រមរណភាពច្បាប់ដើមរបស់ម្តាយគាត់ លេខ ០៣ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១២ ក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពលេខ ០១/២០១២ ដើម្បីបង្ហាញមន្ត្រីអត្រានុកូលដ្ឋាន ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល។

លោក សោម សារី បច្ចុប្បន្នរស់នៅភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល។

មន្ត្រីអត្រានុកូលដ្ឋានឃុំកោះកែវ ប៊ុត ប៊ុន។

**ឧទាហរណ៍ ៤.៤** ÷ ការសរសេរចូលក្នុងសៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព នៅសាលាក្រុង ស្រុក ខណ្ឌ តាមឧទាហរណ៍ដូចខាងក្រោម ៖

ថ្ងៃអង្គារ ទី១៣ ខែមករា ឆ្នាំ២០១២ លោក ម៉ែន សាមឿន បានទៅសុំចម្លងសំបុត្របញ្ជាក់មរណភាពរបស់ឪពុកគាត់ ចំនួន១០សន្លឹក នៅសាលាស្រុកកោះធំ ខេត្តកណ្តាល ដោយបានកាន់យកទៅជាមួយនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើមរបស់ឪពុកគាត់ លេខ០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ក្នុងសៀវភៅអត្រានុកូល-ដ្ឋានបញ្ជាក់មរណភាពលេខ០១/២០១១ ដើម្បីបង្ហាញមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន នៅស្រុកកោះធំ។

លោក ម៉ែន សាមឿន បច្ចុប្បន្នរស់នៅភូមិចុងព្រែក ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល។

មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុកកោះធំ ឈ្មោះ អ៊ូច ប៊ុនគីម។

លេខ ថ្ងៃខែឆ្នាំបញ្ជាក់លើសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពនេះ របស់ស្រុកកោះធំ ៖ ០១ ក.ធ.ប.ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២។

អភិបាលស្រុកកោះធំឈ្មោះ ខៀវ សំអាត។

# សៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព (នៅសាលាឃុំ សង្កាត់)

| លេខរៀង | ថ្ងៃ ខែ ឆ្នាំ ចេញសេចក្តីចម្លង | ចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | សៀវភៅ | | សំបុត្រ | | សព | | | | | អ្នកសុំចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | | មន្ត្រីចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃ ខែ ឆ្នាំ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃ ខែ ឆ្នាំស្លាប់ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងសព | ស្នាមមេដៃ ស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២* | *ចម្លងសំបុត្រមរណភាព* | *០១/ ២០១២* | *កោះកែវ* | *០៣* | *ថ្ងៃទី២១ ខែមករា ឆ្នាំ២០១២* | *ស៊ឹម វណ្ណា* | *ស្រី* | *ខ្មែរ* | *ថ្ងៃច័ន្ទ ទី២៦ ខែតុលា ឆ្នាំ១៩៣១* | *ថ្ងៃអង្គារ ទី២០ ខែមករា ឆ្នាំ២០១២* | *សោម សារី* | *ភូមិពោធិ៍ជ្រៃ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្តាល ប្រទេសកម្ពុជា* | *កូនបង្កើត* | | *ប៊ុត ប៊ុន* | *មេឃុំ* | *០៥ សន្លឹក* | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

## សៀវភៅចម្លងសំបុត្រមរណភាព និងចម្លងសំបុត្របញ្ជាក់មរណភាព (នៅសាលាក្រុង ស្រុក ខណ្ឌ)

| លេខរៀង | ថ្ងៃ ខែ ឆ្នាំ ចេញសេចក្តីចម្លង | ចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | សៀវភៅ | | សំបុត្រ | | សព | | | | | អ្នកសុំចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | | មន្ត្រីចម្លងសំបុត្រមរណភាព ឬបញ្ជាក់មរណភាព | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លេខ | ឃុំ សង្កាត់ | លេខ | ចុះថ្ងៃ ខែ ឆ្នាំ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃ ខែ ឆ្នាំស្លាប់ | នាមត្រកូល និងនាមខ្លួន | ទីលំនៅបច្ចុប្បន្ន | ត្រូវជាអ្វីនឹងសព | ស្នាមមេដៃ ស្តាំ | នាមត្រកូល និងនាមខ្លួន | មុខងារ | ចំនួនសន្លឹកចម្លង | សេចក្តីផ្សេងៗ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) | (១២) | (១៣) | (១៤) | (១៥) | (១៦) | (១៧) | (១៨) | (១៩) | (២០) |
| *០១* | *ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២* | *ចម្លងសំបុត្រ បញ្ជាក់ មរណភាព* | *០១/ ២០០៥* | *ព្រែកស្តី* | *០៥* | *ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥* | *ម៉ែន សាម៉ន* | *ប្រុស* | *ខ្មែរ* | *ថ្ងៃសុក្រ ទី០៣ ខែមីនា ឆ្នាំ១៩៣១* | *ថ្ងៃច័ន្ទ ទី១៥ ខែមករា ឆ្នាំ១៩៩៧* | *ម៉ែន សាមឿន* | *ភូមិចុងព្រែក ឃុំព្រែកស្តី ស្រុកកោះកែវ ខេត្តកណ្តាល ប្រទេសកម្ពុជា* | *កូនបង្កើត* | | *អ៊ូច ប៊ុនគីម* | *ប្រធានការិយាល័យរដ្ឋបាលទូទៅ* | *១០ សន្លឹក* | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | |

### ៤.៣.២. របៀបសរសេរសេចក្ដីចម្លងសំបុត្រមរណភាព និងសេចក្ដីចម្លងសំបុត្របញ្ជាក់មរណភាព

☞ នៅពេលសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសៀវភៅចម្លងសំបុត្របញ្ជាក់មរណភាពចប់សព្វ គ្រប់ ហើយមន្ត្រីអត្រានុកូលដ្ឋាន ឬមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវសរសេរចម្លងសំបុត្រមរណភាព ឬ ចម្លងសំបុត្របញ្ជាក់មរណភាព។

☞ របៀបសរសេរសេចក្ដីចម្លងសំបុត្រមរណភាព ឬចម្លងសំបុត្របញ្ជាក់មរណភាព អនុវត្តដូចគ្នានឹងការសរសេរសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាពច្បាប់ដើមដែរ។

☞ ចំពោះការសុំចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព នៅក្នុងឆ្នាំដែលកន្លងផុតទៅ ត្រូវមានការបញ្ជាក់មួយចំនួន ដូចខាងក្រោម ៖

| |
|---|
| លេខ (ក)...................... |
| យើង (ខ)........................................................... |
| បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្ដាំនេះ ជាហត្ថលេខា |
| របស់លោក (គ)........................... ជាមន្ត្រីរក្សាសៀវភៅ |
| អត្រានុកូលដ្ឋាន (ឃ).............................ពិតប្រាកដមែន។ |
| (ង) ធ្វើនៅ............... ថ្ងៃទី........ ខែ.............. ឆ្នាំ....... |
| (ច) ហត្ថលេខា និងត្រា |

ក). លេខ ៖ ត្រូវសរសេរលេខរៀងជាលេខខ្មែរ ដោយចាប់ពី០១ រហូតដល់ដំណាច់ឆ្នាំ។ នៅឆ្នាំថ្មី ត្រូវអនុវត្តចុះលេខថ្មី ចាប់ពីលេខ០១ដដែល។ នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានសៀវភៅចុះលេខ ចេញដោយឡែក សម្រាប់សេចក្ដីចម្លងសំបុត្រអត្រានុកូលដ្ឋាន។

ខ). ត្រូវសរសេរ “អភិបាលក្រុង ស្រុក ខណ្ឌ.......(ឈ្មោះក្រុង ស្រុក ខណ្ឌ).........” ។

គ). ឈ្មោះមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន។

ឃ). ត្រូវសរសេរ “ក្រុង ស្រុក ខណ្ឌ............(ឈ្មោះក្រុង ស្រុក ខណ្ឌ)...........” ។

ង). ធ្វើនៅ------- ថ្ងៃទី---- ខែ------ ឆ្នាំ------ ៖ ត្រូវសរសេរឈ្មោះក្រុង ស្រុក ខណ្ឌ និងចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរតាមសុរិយគតិ ឆ្នាំជាលេខ ខ្មែរតាម គ្រិស្តសករាជ។

ច). ហត្ថលេខា និងត្រា ៖ ហត្ថលេខារបស់អភិបាលក្រុង ស្រុក ខណ្ឌ និង បោះត្រា។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ~~ក្រុង~~** (១) ---- *កណ្តាល* ------
**ស្រុក ~~ខណ្ឌ~~** (២) ----- *ល្វាឯម* ------
**ឃុំ ~~សង្កាត់~~** (៣) ----- *កោះកែវ*------

# សេចក្តីចម្លងសំបុត្រមរណភាព

<table>
<tr><td colspan="2">ចម្លងសំបុត្រមរណភាពចេញពី</td><td>(៤) សៀវភៅមរណភាព<br>លេខ ៖ ០១/២០១២</td><td colspan="2">(៥) សំបុត្រមរណភាព<br>លេខ ០៣ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១២</td></tr>
<tr><td colspan="2">នាមត្រកូល (៦)</td><td colspan="2">ស៊ីម</td><td rowspan="2">ភេទ (៨)<br>ស្រី</td></tr>
<tr><td colspan="2">នាមខ្លួនសព (៧)</td><td colspan="2">វណ្ណា</td></tr>
<tr><td rowspan="2">ជាអក្សរឡាតាំង (៩)</td><td>នាមត្រកូល</td><td colspan="3">SIM</td></tr>
<tr><td>នាមខ្លួនសព</td><td colspan="3">VANNA</td></tr>
<tr><td colspan="2">សញ្ជាតិ (១០)</td><td colspan="3">ខ្មែរ</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត (១១)</td><td colspan="3">ថ្ងៃ ច័ន្ទ ទី ២៦ ខែ តុលា ឆ្នាំ ១៩៣១</td></tr>
<tr><td colspan="2">ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស</td><td colspan="3">.........ភូមិបឹង ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា<br>..............................................................................................</td></tr>
<tr><td colspan="2">ស្ថានភាពសព (១៣)<br>នៅលីវ មានប្តី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ</td><td colspan="3">មានប្តី</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤)</td><td colspan="3">ថ្ងៃ អង្គារ៍ ទី ២០ ខែ មករា ឆ្នាំ ២០១២</td></tr>
<tr><td colspan="2">នាមត្រកូល និងនាមខ្លួនឪពុកសព (១៥)</td><td colspan="2">ស៊ីម សារឿន</td><td rowspan="2">សញ្ជាតិ (១៦)<br>ខ្មែរ</td></tr>
<tr><td colspan="2">ជាអក្សរឡាតាំង (១៧)</td><td colspan="2">SIM SAROEUN</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត (១៨)</td><td colspan="3">ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩១០</td></tr>
<tr><td colspan="2">នាមត្រកូល និងនាមខ្លួនម្តាយសព (១៩)</td><td colspan="2">ស្រី នាង</td><td rowspan="2">សញ្ជាតិ (២០)<br>ខ្មែរ</td></tr>
<tr><td colspan="2">ជាអក្សរឡាតាំង (២១)</td><td colspan="2">SREY NEANG</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត (២២)</td><td colspan="3">ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១២</td></tr>
</table>

(២៣) ធ្វើនៅ...កោះកែវ..... ថ្ងៃទី *១៥* ខែ *មីនា* ឆ្នាំ *២០១២*

(២៤) **មន្ត្រីអត្រានុកូលដ្ឋាន**

*មេឃុំ*

(២៥) *ហត្ថលេខា និងត្រា*

*ប៊ុត ប៊ុន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ~~ក្រុង~~** (១) ----- *កណ្ដាល* -----
**ស្រុក ~~ខណ្ឌ~~** (២) ----- *កោះធំ* ------
**ឃុំ ~~សង្កាត់~~** (៣) --------------------

## សេចក្ដីចម្លងសំបុត្របញ្ជាក់មរណភាព

| ចម្លងសំបុត្របញ្ជាក់មរណភាពចេញពី | | (៤) សៀវភៅបញ្ជាក់មរណភាព លេខ៖ *០១/២០០៥* | (៥) សំបុត្របញ្ជាក់មរណភាព លេខ០៥ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ |
|---|---|---|---|
| នាមត្រកូល (៦) | | *ម៉ែន* | ភេទ(៨) |
| នាមខ្លួនសព (៧) | | *សាម៉ន* | *ប្រុស* |
| ជាអក្សរឡាតាំង(៩) | នាមត្រកូល | *MEN* | |
| | នាមខ្លួនសព | *SAMAN* | |
| សញ្ជាតិ (១០) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១១) | | *ថ្ងៃ សុក្រ ទី ០៣ ខែ មីនា ឆ្នាំ ១៩៣១* | |
| ទីកន្លែងកំណើត (១២) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | *.... ភូមិវាលស្បូវ ឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ប្រទេសកម្ពុជា* | |
| ស្ថានភាពសព (១៣) នៅលីវ មានប្ដី មានប្រពន្ធ ពោះម៉ាយ មេម៉ាយ | | *ពោះម៉ាយ* | |
| ថ្ងៃ ខែ ឆ្នាំស្លាប់ (១៤) | | *ថ្ងៃ ច័ន្ទ ទី ១៥ ខែ មករា ឆ្នាំ ១៩៩៧* | |
| នាមត្រកូល និងនាមខ្លួនឪពុកសព (១៥) | | *ម៉ែន សាម៉ែន* | សញ្ជាតិ(១៦) |
| ជាអក្សរឡាតាំង (១៧) | | *MEN SAMEN* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៨) | | *ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩១០* | |
| នាមត្រកូល និងនាមខ្លួនម្ដាយសព (១៩) | | *សួន ប្រាថ្នា* | សញ្ជាតិ(២០) |
| ជាអក្សរឡាតាំង (២១) | | *SUON PRATHNA* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២២) | | *ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩១២* | |

លេខ(ក)..... *០១ ក.ធ.ប.ក* ...........
យើង(ខ).... *អភិបាលស្រុកកោះធំ* .................................
បានឃើញ និងបញ្ជាក់ថា ហត្ថលេខាខាងស្ដាំនេះ ជាហត្ថលេខា
របស់លោក(គ)..... *អ៊ូច ប៊ុនគីម*....... ជាមន្ត្រីរក្សាសៀវភៅ
អត្រានុកូលដ្ឋាន(ឃ).........ស្រុកកោះធំ........ពិតប្រាកដមែន។
(ង) ធ្វើនៅកោះធំ..... ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២
(ច) *ហត្ថលេខា និងត្រា*
*ខៀវ សំអាត*

(២៤) ធ្វើនៅ...កោះធំ.... ថ្ងៃទី *១៣* ខែ *មករា* ឆ្នាំ *២០១២*
**(២៥) មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន**---
*ហត្ថលេខា*
*អ៊ូច ប៊ុន គីម*

### ៤.៣.៣. សេចក្តីសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព

☞ សម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព ត្រូវស្រង់ចេញពីសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាពដែលតម្កល់ទុក ដោយស្រង់យកតែខ្លឹមសារតាមសំណើរបស់អ្នកមកសុំស្រង់ប៉ុណ្ណោះ ។